ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១០ លេខ ៤៥ សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១០

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

០៨-៦-២០១០ -ព្រះរាជក្រម នស/រកម/០៦១០/០០៧ ស្ដីពី ការប្រកាសឱ្យប្រើ ច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្ដួចផ្ដើមឈៀងម៉ៃ ៤៦៦១

២~ព្រះរាជក្រឹត្យ

២៤-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤០៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម ចំនួន ០៤ រូប ៤៧៣៥

២៥-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១៦ ស្ដីពី ការបញ្ចប់មុខតំណែង ឯកឧត្ដម **ចាន់ រ៉ាស៊ី** ពីទីប្រឹក្សាផ្ទាល់ ឯកឧត្ដម **ឯត សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ រដ្ឋលេខាធិការ និង ត្រូវបានតែងតាំងឯកឧត្ដម **ផាត់ ពៅស៊ាន** ជំនួសវិញ មានឋានៈស្មើ រដ្ឋលេខាធិការ ៤៧៣៦

២៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៤០ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ជុងប៉ែក** (LEE JUNG BAEK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៤៧៣៧

២៩-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៤៣ ស្ដីពី ការតែងតាំងឯកឧត្ដម **មឹន សាន** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជ្រើសតាំងដោយរដ្ឋសភាសម្រាប់អាណត្តិថ្មី ៤៧៣៨

០២-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៦៥ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជូ ណាមហាន** (CHO NAM HAN) ជនជាតិកូរ៉េ សញ្ជាតិអាមេរិក កើតនៅ ក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៤៧៣៩

០៨-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៨៥ ស្ដីពី :
១-ការបញ្ចប់មុខតំណែងឯកឧត្ដម **អ៊ិត សារិ** ពីទីប្រឹក្សា ឯកឧត្ដម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី និង ឯកឧត្ដម **រស់ ឆេង** ពីទីប្រឹក្សារាជរដ្ឋាភិបាល
២-ត្រូវបានតែងតាំងឯកឧត្ដម **អ៊ិត សារិ** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើរដ្ឋលេខាធិការ និង ឯកឧត្ដម **រស់ ឆេង** ជាទីប្រឹក្សា ឯកឧត្ដម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ ៤៧៤០

១០-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៨៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្ដម,អស់លោក និង លោកស្រី ចំនួន ១៧ រូប ៤៧៤១

១០-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៤៩០ ស្តីពី ការដាក់មន្ត្រីរាជការឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយរក្សាក្របខ័ណ្ឌនយោបាយដដែលរហូត មាន ការ សម្រេចជាថ្មីពីរាជរដ្ឋាភិបាលចំនួន ០៣ រូប ៤៧៤២

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១៧-៦-២០១០ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.០០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល័ង្គ ខេត្តកំពង់ធំ ៤៧៤៤

១៤-៦-២០១០ -អនុក្រឹត្យលេខ ៦៣៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៧៤៧

១៤-៦-២០១០ -អនុក្រឹត្យលេខ ៦៣៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៧៤៨

១៥-៦-២០១០ -អនុក្រឹត្យលេខ ៦៣៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៧៤៩

១៥-៦-២០១០ -អនុក្រឹត្យលេខ ៦៤០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៧៥០

១៥-៦-២០១០ -អនុក្រឹត្យលេខ ៦៤១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៧៥២

១៥-៦-២០១០ -អនុក្រឹត្យលេខ ៦៤២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤៧៥៣

១៦-៦-២០១០ -អនុក្រឹត្យលេខ ៦៤៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤៧៥៤

១៦-៦-២០១០ -អនុក្រឹត្យលេខ ៦៤៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៧៥៦

២. សារាចរណែនាំ

២៨-៥-២០១០ -សារាចរណែនាំលេខ ០៥ សរណន ស្តីពី ការរៀបចំខួបលើកទី ៦១ ទិវាកុមារ អន្តរជាតិ ១ មិថុនា និង ខួបលើកទី ៩ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ ២០១០ ៤៧៥៨

III. ការងារបណ្ដាក្រសួង

ទីស្តីការអគ្គមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤១៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេខេន ស៊ូម៉ា ខនស្ត្រាក់សិន** ៤៧៦១

១៩-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤១៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ហាយត្រេស ស៊ីលូសិន** ៤៧៦៣

១៩-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤១៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុនអ៊ី & ឌី អ៊ិនធើណេសិនណល គ្រុប លីមីធីត ៤៧៦៥

១៩-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤១៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌី.អិន.ឌី ៤៧៦៧

២០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤២០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អែបខេស្គ ៤៧៦៩

២០-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤២១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប្ញូរ ណាគ ខូ អិលធីឌី ៤៧៧១

២១-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤៣៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន គីរីរម្យ អេគូឡូរីសឹម អ៊ិន ខេសមេន ៤៧៧៣

២១-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤៣៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេស.ខេ.ខេ.អេច ខន ស្ត្រាក់សិន ៤៧៧៥

២១-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤៣៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អ៊ិនធើប្រ៊ែន ៤៧៧៧

២១-៨-២០០៩ -លិខិតបញ្ជាក់លេខ ៣៤៣៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្វូង ឬទ្ធី អ៊ិមផត អិចផត ៤៧៧៩

ព្រះរាជក្រម

នស/រកម/០៦១០/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុនីយកម្ម
គំនិតផ្តួចផ្តើមឈៀងម៉ៃ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខា នាថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៩ នៅរាជធានីភ្នំពេញ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

មាត្រា ៣.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ចរល.១០០៦.៤៩២

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ៤៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ចិនកេន

7/2

កិច្ចព្រមព្រៀង
ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ

កិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ(កិច្ចព្រមព្រៀង CMIM នេះ) ត្រូវបានធ្វើឡើងដោយភាគីដូចខាងក្រោម និងត្រូវចូលជាធរមានស្របតាមមាត្រា១៩:

ប្រ៊ុយណេដារុសសាឡាំ

(១) ក្រសួងហិរញ្ញវត្ថុ

(២) គណៈកម្មាធិការរូបិយវត្ថុ និងរូបិយប័ណ្ណប្រ៊ុយណេ ដែលដើរតួនាទីជាភ្នាក់ងារមួយសម្រាប់រដ្ឋាភិបាលនៃព្រះករុណា The Sultan និង Yang Di-Pertuan នៃប្រទេសប្រ៊ុយណេដារុសសាឡាំ តំណាងដោយក្រសួងហិរញ្ញវត្ថុ

កម្ពុជា

(១) ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

(២) ធនាគារជាតិនៃកម្ពុជា

ឥណ្ឌូនេស៊ី

(១) ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋឥណ្ឌូនេស៊ី

(២) ធនាគារឥណ្ឌូនេស៊ី

សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

(១) ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

(២) ធនាគារនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ

ម៉ាឡេស៊ី

(១) រដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី តំណាងដោយក្រសួងហិរញ្ញវត្ថុ

(២) ធនាគារណេហ្គារ៉ាម៉ាឡេស៊ី

មីយ៉ាន់ម៉ា

(១) ក្រសួងហិរញ្ញវត្ថុ និងចំណូល

(២) ធនាគារកណ្តាលនៃមីយ៉ាន់ម៉ា

ហ្វីលីពីន

(១) ក្រសួងហិរញ្ញវត្ថុ

(២) ធនាគារកណ្តាលហ្វីលីពីន (BANGKO SENTRAL NG PILIPINAS)

<u>សិង្ហបុរី</u>

(១) ក្រសួងហិរញ្ញវត្ថុ សម្រាប់ និងក្នុងនាមរដ្ឋាភិបាលសិង្ហបុរី

(២) អាជ្ញាធររូបិយវត្ថុសិង្ហបុរី

<u>ថៃឡង់ដ៍</u>

(១) ក្រសួងហិរញ្ញវត្ថុ

(២) ធនាគារថៃឡង់ដ៍

<u>វៀតណាម</u>

(១) ក្រសួងហិរញ្ញវត្ថុ

(២) ធនាគាររដ្ឋវៀតណាម

<u>សាធារណរដ្ឋប្រជាមានិតចិន</u>

(១) ក្រសួងហិរញ្ញវត្ថុ

(២) ធនាគារប្រជាជនចិន

<u>ហុងកុង (ប្រទេសចិន)</u>

អាជ្ញាធររូបិយវត្ថុហុងកុង (ប្រទេសចិន) សម្រាប់ការគ្រប់គ្រងមូលនិធិរូបិយប័ណ្ណ ("អាជ្ញាធររូបិយវត្ថុហុងកុង")

<u>ជប៉ុន</u>

(១) ក្រសួងហិរញ្ញវត្ថុ

(២) ធនាគារជប៉ុន ដើរតួជាភ្នាក់ងាររបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន

<u>សាធារណរដ្ឋកូរ៉េ</u>

(១) ក្រសួងយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ

(២) ធនាគារកូរ៉េ

ដោយហេតុថា អ្នកចូលរួមក្នុងគំនិតផ្តួចផ្តើមឈៀងម៉ៃ (ភាគីចូលរួម CMI) បានយល់ព្រមគ្នា និង មើលឃើញពីផលប្រយោជន៍ទៅវិញទៅមកក្នុងការបង្កើតឱ្យមានយន្តការគាំទ្រនិងភាពសាច់ប្រាក់ពហុភាគី ដែលនៅក្រោមឈ្មោះថា ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)

ដោយហេតុថា អ្នកចូលរួម CMI មានបំណងឱ្យពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ស្ថិតក្នុងទម្រង់នៃយន្តការពហុភាគីក្នុងចំណោមអ្នកចូលរួម CMI និងអាជ្ញាធររូបិយវត្ថុហុងកុង ("ការរៀបចំ CMIM") ដែលត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងមានលក្ខណៈជាកិច្ចសន្យាតែមួយគត់ ក្នុងគោលបំណងដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុជារូបិយប័ណ្ណដុល្លារអាមេរិក តាមរយៈការចរចាដោះដូររូបិយប័ណ្ណ (currency swap transaction) ដល់បណ្តាប្រទេសសមាជិកនៃកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ដែលស្ថិតនៅក្រោមគោលដៅសំខាន់ៗពីរនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ គឺ (១) ដើម្បីដោះស្រាយបញ្ហាលំបាកនៃជញ្ជីងទូទាត់ និង កង្វះសាច់ប្រាក់ក្នុងតំបន់រយៈពេលខ្លី និង (២) ដើម្បីបំពេញបន្ថែមទៅលើយន្តការអន្តរជាតិដែលមានស្រាប់ និង

ដោយហេតុថា អ្នកចូលរួម CMI បានសម្រេចគ្នាជាឯកច្ឆន្ទកំណត់ទំហំទឹកប្រាក់សរុបនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ គឺ ១២០,០០០,០០០,០០០ដុល្លារអាមេរិក (មួយរយម្ភៃពាន់លានដុល្លារអាមេរិក) ដែលមានសមាមាត្រនៃការចូលរួមទុន "២០:៨០" រវាងបណ្តារដ្ឋជាសមាជិកអាស៊ាន និងប្រទេសបូកបី។

ហេតុនេះ បណ្តាភាគីដែលមានរាយឈ្មោះខាងលើ (ទាំងអស់គ្នាហៅថា "បណ្តាភាគីនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ" ហើយភាគីមួយៗហៅថា "ភាគីនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ") នៅក្នុងកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ បានព្រមព្រៀងដូចខាងក្រោមៈ

មាត្រា ១.- គោលដៅគ្រឹះ

គោលដៅគ្រឹះនៃកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ គឺដើម្បីកំណត់ និងធ្វើឱ្យមានលក្ខណៈជាផ្លូវការនៃការព្រមព្រៀងរវាងបណ្តាភាគីនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ពាក់ព័ន្ធនឹងៈ (i) ការបង្កើតនូវយន្តការតំបន់និងពហុភាគី ដើម្បីឱ្យបណ្តាភាគីនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ អាចមានរូបិយប័ណ្ណដុល្លារអាមេរិក សម្រាប់ប្រើប្រាស់ តាមរយៈការដោះដូររូបិយប័ណ្ណ ក្នុងគោលបំណងផ្តល់ការគាំទ្រសាច់ប្រាក់ដុល្លារអាមេរិកនៅក្នុងតំបន់ និងឆ្លើយតបទៅនឹងការលំបាកផ្នែកសាច់ប្រាក់ដុល្លារអាមេរិករយៈពេលខ្លី និង/ឬ ការលំបាកនៃជញ្ជីងទូទាត់ ដែលភាគីមួយ ឬបណ្តាភាគីនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃអាចជួបប្រទះពីពេលមួយទៅពេលមួយ និង (ii) លក្ខខណ្ឌជាក់លាក់សម្រាប់អនុវត្តត្រូវតែគោរពភាពប្រើប្រាស់ឱ្យជាប្រយោជន៍នៃការដោះដូររូបិយប័ណ្ណដុល្លារអាមេរិក ដើម្បីផ្តល់ការគាំទ្រសាច់ប្រាក់ដល់ភាគីស្នើសុំធ្វើការដោះដូររូបិយប័ណ្ណណាមួយ ដែលស្នើឱ្យមានការគាំទ្រនេះ ដោយសារតែកាលៈទេសៈ ដូចបានចែងក្នុងចំណុច(i)។

មាត្រា ២.. និយមន័យ និងការបកស្រាយ

២.១ និយមន័យ

បន្ថែមលើពាក្យស័ព្ទផ្សេងទៀតដូចបានកំណត់ក្នុងកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃនេះ និយមន័យខាងក្រោមត្រូវអនុវត្តចំពោះពាក្យស័ព្ទពាក់ព័ន្ធដែលត្រូវបានប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃនេះ។

AFDM+3 សំដៅដល់កិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាលនៃរដ្ឋជាសមាជិកអាស៊ានបូកបី។

រដ្ឋសមាជិកអាស៊ាន សំដៅដល់បណ្តាប្រទេសដែលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍("អាស៊ាន")ដែលមានប្រទេសប្រ៊ុយណេដារុស្សាឡាំ កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និងវៀតណាម។

ប្រទេសអាស៊ានបូកបី សំដៅដល់ក្រុមប្រទេសដែលរួមមានទាំងរដ្ឋជាសមាជិកអាស៊ាន និងប្រទេសបូកបី។

ទូរគមនាគមន៍យថាភូត (Authenticated Telecommunication) មានន័យដូចកំណត់នៅក្នុងមាត្រា ៧.៣.១។

ថ្ងៃធ្វើការ (ទាក់ទងនឹងការចូលរួមរបស់ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្នុងប្រតិបត្តិការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ នៅក្រោមកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ) គឺសំដៅដល់ថ្ងៃនៃសប្តាហ៍លើកលែងតែថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកជាសាធារណៈ ដែលនៅថ្ងៃនោះគ្រឹះស្ថានធនាគារនៅទីក្រុងញូយ៉ក ព្រមទាំងនៅប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ និងប្រទេស/តំបន់ ស្នើសុំការដោះដូររូបិយប័ណ្ណបើកទ្វា ដល់សាធារណៈជនសម្រាប់ការអនុវត្តសកម្មភាពធនាគារជាប្រក្រតីរបស់ខ្លួនក្នុងអំឡុងម៉ោងធ្វើការធម្មតា។

ធនាគារកណ្តាល (ចំពោះប្រទេសអាស៊ានបូកបីនីមួយៗនិងហុងកុងប្រទេសចិន) សំដៅដល់ភាគីមួយនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ដែលជាធនាគារកណ្តាល ឬ ប្រសិនបើអាចអនុវត្តបាន ជាអាជ្ញាធរផ្សេងៗទៀត ដែលទទួលខុសត្រូវលើទុនបំរុងអន្តរជាតិរបស់ប្រទេសអាស៊ានបូកបី ឬហុងកុងប្រទេសចិន ហើយដើម្បីចៀសវាងការមន្ទិលសង្ស័យនៅក្នុងករណីប្រទេសជប៉ុន ធនាគារកណ្តាលគឺសំដៅលើធនាគារជប៉ុនដែលជាភ្នាក់ងាររបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន (ដែលគ្រប់សកម្មភាពទាំងអស់ដែលត្រូវអនុវត្តដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន ក្រោមកិច្ចព្រមព្រៀងឈៀងម៉ៃពហុភាគីនេះ អាចត្រូវបានអនុវត្តដោយធនាគារជប៉ុន ក្នុងនាមជាភ្នាក់ងាររបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន។ ប្រសិនបើធនាគារជប៉ុនក្នុងនាមជាភ្នាក់ងាររបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុ

ជប៉ុន អនុវត្តកាតព្វកិច្ចណាមួយ ឬសកម្មភាពដែលត្រូវអនុវត្តដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន ការអនុវត្តទាំងនោះនឹងត្រូវបានចាត់ទុកថាជាសកម្មភាពរបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន។ ធនាគារជប៉ុនមិនត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវចំពោះបណ្តាភាគីណាមួយនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ទាក់ទងនឹងសកម្មភាពណាមួយដែលត្រូវបានអនុវត្តក្នុងនាមជាភ្នាក់ងាររបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុន ក្រោមកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃនេះ ឬពាក់ព័ន្ធនឹងកាតព្វកិច្ចណាមួយរបស់រដ្ឋមន្ត្រីហិរញ្ញវត្ថុជប៉ុនឡើយ)។ ក្នុងករណីហុងកុងប្រទេសចិនវិញ ធនាគារកណ្តាល គឺសំដៅដល់អាជ្ញាធររូបិយវត្ថុហុងកុង។ ក្នុងករណីប្រទេសប្រ៊ុយណេដារុសសាឡាំ ធនាគារកណ្តាលសំដៅដល់គណៈកម្មាធិការរូបិយប័ណ្ណ និង រូបិយវត្ថុប្រ៊ុយណេ (BCMB) ដែលដើរតួនាទីជាភ្នាក់ងាររបស់រដ្ឋាភិបាលនៃព្រះករុណា The Sultan និង Yang Di-Pertuan នៃប្រទេសប្រ៊ុយណេដារុសសាឡាំ ដែលតំណាងដោយក្រសួងហិរញ្ញវត្ថុនៃប្រទេសប្រ៊ុយណេដារុសសាឡាំ (ដែលគ្រប់សកម្មភាពទាំងអស់ដែលត្រូវអនុវត្តដោយក្រសួងហិរញ្ញវត្ថុប្រ៊ុយណេ ក្រោមកិច្ចព្រមព្រៀងនេះអាចត្រូវបានអនុវត្តដោយគណៈកម្មាធិការ BCMB ក្នុងនាមជាភ្នាក់ងាររបស់ក្រសួងហិរញ្ញវត្ថុប្រ៊ុយណេ។ ប្រសិនបើ BCMB ក្នុងនាមជាភ្នាក់ងាររបស់ក្រសួងហិរញ្ញវត្ថុប្រ៊ុយណេអនុវត្តកាតព្វកិច្ចណាមួយ ឬសកម្មភាពដែលត្រូវអនុវត្តដោយក្រសួងហិរញ្ញវត្ថុប្រ៊ុយណេ ការអនុវត្តទាំងនោះនឹងត្រូវបានចាត់ទុកថា ជាសកម្មភាពរបស់ក្រសួងហិរញ្ញវត្ថុប្រ៊ុយណេ។ គណៈកម្មាធិការ BCMB មិនត្រូវមានកាតព្វកិច្ច និងការទទួលខុសត្រូវចំពោះបណ្តាភាគីណាមួយនៃពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃទាក់ទងនឹងសកម្មភាពណាមួយ ដែលត្រូវបានអនុវត្តក្នុងនាមជាភ្នាក់ងាររបស់ក្រសួងហិរញ្ញវត្ថុប្រ៊ុយណេ ក្រោមកិច្ចព្រមព្រៀងនេះ ឬពាក់ព័ន្ធនឹងកាតព្វកិច្ចណាមួយរបស់ក្រសួងហិរញ្ញវត្ថុប្រ៊ុយណេឡើយ)។

CMIM (ពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ) មានអត្ថន័យដូចការពន្យល់នៅកថាខ័ណ្ឌទី១ នៃផ្នែកលំនាំដើមខាងលើ។

ការរៀបចំ CMIM មានអត្ថន័យដូចការពន្យល់នៅកថាខ័ណ្ឌទី២ នៃលំនាំដើមខាងលើ។

ការចូលវិភាគទាន CMIM ចំពោះភាគីនីមួយៗនៃ CMIM គឺសំដៅដល់វិភាគទានដែលភាគី CMIM បានរួមចំណែករៀបចំយន្តការ CMIM ស្របតាមបទបញ្ញត្តិនៃមាត្រា៣ និងតារាងកម្មវិធីទី១ (schedule 1)។

ថ្នាក់ធ្វើសេចក្តីសម្រេចលើ CMIM សំដៅដល់ក្រុមអ្នកធ្វើការសម្រេច ដូចបានកំណត់ក្នុងមាត្រា ៤.១។

គោលការណ៍នៃការធ្វើសេចក្តីសម្រេចលើ CMIM សំដៅដល់គោលការណ៍ និងវិធានគ្រឹះដែលក្រុមអ្នកធ្វើការសម្រេចរបស់ CMIM ត្រូវអនុវត្តតាម ដូចបានពន្យល់ពេញលេញ និង

មានចែងក្នុងមាត្រា៤ និងតារាងកម្មវិធីទី២ ទាក់ទងនឹងការសម្រេច ដែលត្រូវធ្វើឡើងដោយក្រុមអ្នកធ្វើការសម្រេចរបស់ CMIM ស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង CMIM នេះ។

អ្នកចូលរួម CMI មានអត្ថន័យដូចមានចែងក្នុងកថាខ័ណ្ឌទី៤ នៃផ្នែកលំនាំដើមខាងលើ។

ភាគី CMIM មានអត្ថន័យដូចបានកំណត់ក្នុងកថាខ័ណ្ឌទី៤ នៃផ្នែកលំនាំដើមខាងលើ។

អង្គភាពឃ្លាំមើលរបស់ CMIM សំដៅដល់អង្គភាពឃ្លាំមើល ដែលត្រូវបង្កើតឡើងស្របតាមមាត្រា១៨ នៃកិច្ចព្រមព្រៀង CMIM នេះ។

ការសន្យា របស់ភាគីនីមួយៗនៃ CMIM គឺសំដៅដល់កាតព្វកិច្ចនៃភាគី CMIM ក្នុងការរួមវិភាគទានរបស់ខ្លួនដល់ការរៀបចំយន្តការ CMIM ដោយផ្អែកលើលិខិតសន្យារបស់ខ្លួន និង លក្ខខណ្ឌតម្រូវនៃកិច្ចព្រមព្រៀង CMIM នេះ។

លិខិតសន្យា របស់ធនាគារកណ្តាលនីមួយៗ គឺសំដៅដល់ការសន្យាផ្លូវការ និងការសន្យាសារឡើងវិញទាំងឡាយណាដែលត្រូវបានអនុវត្ត និងប្រគល់ឱ្យដោយធនាគារកណ្តាលមួយដែលបានផ្ញើរទៅធនាគារចំនួន ១៣ ផ្សេងទៀត ក្នុងទម្រង់លិខិតសន្យាដូចមានចែងក្នុងតារាងកម្មវិធីទី៣ ទៅតាមចំនួនវិភាគទាន CMIM របស់ធនាគារកណ្តាលនោះ។

ការអនុម័តជាឯកច្ឆ័ន្ទ សំដៅដល់ការអនុម័តជាឯកច្ឆ័ន្ទដោយតំណាងពាក់ព័ន្ធរបស់ MLDMB លើគោលការណ៍សំខាន់ៗណាមួយ។

ប្រទេសសម្របសម្រួល មានន័យដូចបានចែងនៅក្នុងមាត្រា ៥.១។

ការដកប្រាក់ សំដៅដល់ការដកប្រាក់ទាំងឡាយណាដែលធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ស្របតាមបទបញ្ញត្តិនៃមាត្រា៧.៣។

ការទិញយកវិញមុនពេលកំណត់ មានន័យដូចបានកំណត់ក្នុងមាត្រា ៧.៣.៣។

សម្លេងមានប្រសិទ្ធិភាព ចំពោះបញ្ហាទាំងឡាយណាដែលត្រូវធ្វើការបោះឆ្នោតដោយ ELDMB ស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង CMIM នេះ គឺសំដៅដល់ចំនួនសម្លេងសរុបដូចមានចែងក្នុងតារាងកម្មវិធីទី១ សម្រាប់បណ្តាប្រទេសអាស៊ានបូកបី និងហុងកុងប្រទេសចិន ដកចំនួនសម្លេងនៃ (i) ភាគីណាមួយដែលដកខ្លួនពី CMIM (ii) ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដែលពាក់ព័ន្ធនឹងការស្នើសុំដោះដូររូបិយប័ណ្ណនោះ ត្រូវដាក់ឱ្យគេបោះឆ្នោត និង (iii) ភាគីណាមួយនៃ CMIM ដែលមានចែងក្នុងមាត្រា ៧.១.៤។

ក្រុមអ្នកធ្វើការសម្រេចកម្រិតប្រតិបត្តិ (ELDMB) : សំដៅដល់ក្រុមអ្នកធ្វើការសម្រេចរបស់ CMIM ដែលត្រូវទទួលខុសត្រូវ លើការធ្វើការសម្រេចចំពោះបញ្ហាកម្រិតប្រតិបត្តិ និងទទួលខុសត្រូវលើការពិភាក្សាពេញលេញចំពោះគោលការណ៍សំខាន់ៗណាមួយ មុនការបោះឆ្នោតរបស់ក្រុមអ្នកធ្វើការសម្រេចកម្រិតថ្នាក់រដ្ឋមន្ត្រី (MLDMB) លើគោលការណ៍សំខាន់ៗទាំងនោះ

ហើយត្រូវមានសមាសភាពថ្នាក់អនុរដ្ឋមន្ត្រី និងទេសាភិបាលរង (i) តំណាងក្រសួងហិរញ្ញវត្ថុទាំង១៣ នៃបណ្តាប្រទេសអាស៊ានបូកបី និង (ii) តំណាងធនាគារកណ្តាលទាំង១៤នៃបណ្តាប្រទេសអាស៊ានបូកបី និងហុងកុងនៃប្រទេសចិន។

ភាគីដកខ្លួនមួយរយៈចេញពីការចូលរួមក្នុង CMIM សំដៅដល់ភាគីណាមួយនៃ CMIM ដែលសម្រេចដកខ្លួនចេញពីការចូលរួមក្នុង CMIM សម្រាប់ករណីសំណើនៃការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ ដូចមានចែងក្នុងមាត្រា៨។

ភាពខកខាន មានន័យដូចមានចែងក្នុងមាត្រាទី ១២.២.១។

បញ្ហាកម្រិតប្រតិបត្តិ សំដៅដល់បញ្ហាដែលពាក់ព័ន្ធនឹង: (i)ការអនុម័តលើការដកប្រាក់សម្រាប់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM និងរៀបចំ CMIM នេះ (ii)ការអនុម័តលើការបន្តកិច្ចសន្យាដកប្រាក់ (iii)ការលើកលែងនៃលក្ខខណ្ឌដែលមានពីមុនស្របតាមមាត្រា១០.៤ និងការលើកលែងពីការសន្យាណាមួយក្រោមមាត្រាទី១១ (iv)ការប្រកាសអំពីភាពខកខាន ស្របតាមមាត្រា១២.២.២ (v)ការលើកលែងនៃភាពខកខាន ស្របតាមមាត្រា១២.២.៣ និង (vi)ការអនុម័តលើការដកខ្លួនចេញស្របតាមមាត្រា៨.១ ដូចបានរៀបរាប់យ៉ាងលម្អិត និងមានចែងក្នុងកថាខ័ណ្ឌ(១)(ខ) នៃតារាងកម្មវិធីទី២ ប្រសិនបើការបោះឆ្នោតសម្រាប់បញ្ហានៅក្នុងចំណុច (i) ឬ (ii) (តាមករណីជាក់ស្តែង) និង (vi) ត្រូវបានធ្វើឡើងនៅពេលដំណាលគ្នា ប៉ុន្តែទោះយ៉ាងណាក៏ដោយ គឺត្រូវធ្វើបន្ទាប់ពីការបោះឆ្នោតសម្រាប់បញ្ហានៅក្នុងចំណុច (iii) ដូចបានរៀបរាប់យ៉ាងលម្អិត និង មានចែងក្នុងកថាខ័ណ្ឌ (១)(ខ) នៃតារាងកម្មវិធីទី២។

ការពិនិត្យឡើងវិញរយៈពេលប្រាំឆ្នាំ មានន័យដូចមានចែងក្នុងមាត្រា១៧។

បញ្ហាគោលការណ៍សំខាន់ៗ សំដៅដល់បញ្ហាកម្រិតនយោបាយថ្នាក់រដ្ឋមន្ត្រី ពោលគឺរាល់បញ្ហាទាំងអស់ពាក់ព័ន្ធនឹងការរៀបចំ CMIM ក្រៅពីបញ្ហាកម្រិតប្រតិបត្តិ ដូចដែលបានរៀបរាប់យ៉ាងលម្អិត និងមានចែងក្នុងកថាខ័ណ្ឌ (១)(ក) នៃតារាងកម្មវិធីទី២។

រដ្ឋាភិបាល មានន័យថា (i) ចំពោះភាគីស្នើសុំការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ (លើកលែងអាជ្ញាធររូបិយវត្ថុហុងកុង) គឺសំដៅដល់រដ្ឋាភិបាលនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង(ii) ចំពោះអាជ្ញាធររូបិយវត្ថុហុងកុងដែលជាភាគីស្នើសុំការដោះដូររូបិយប័ណ្ណ គឺសំដៅដល់រដ្ឋាភិបាលហុងកុងប្រទេសចិន។

ហុងកុងប្រទេសចិន សំដៅដល់តំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណៈរដ្ឋប្រជាមានិតចិន។

IMF សំដៅដល់មូលនិធិរូបិយវត្ថុអន្តរជាតិ។

ទំហំទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌរបស់ IMF ដល់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ គឺសំដៅដល់ចំនួនទឹកប្រាក់អតិបរមា (មិនគិតបញ្ចូលការប្រាក់នៅក្នុងនោះទេ) ស្មើនឹង ២០% នៃចំនួនទឹកប្រាក់អតិបរមានៃការដោះដូររូបិយប័ណ្ណ (បានន័យថាស្មើនឹងមេគុណនៃការខ្ចី គុណនឹងវិភាគទាន CMIM របស់ភាគីពាក់ព័ន្ធនោះ ដូចបានចែងក្នុងតារាងកម្មវិធីទី១) បើមិនដូច្នោះទេ នឹងអនុវត្តចំពោះចំនួនទឹកប្រាក់សរុបដែលបានដក ដែលបានធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ តែនៅមិនទាន់ទូទាត់សងវិញនាពេលណាមួយ ក្នុងកាលៈទេសៈដែលគ្មានកម្មវិធីរបស់ IMF ទាក់ទងនឹងប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និងបើតាមការវិនិច្ឆ័យរបស់ ELDMB កម្មវិធី IMF នោះ នឹងមិនត្រូវបានរំពឹងទុកថានឹងចាប់ផ្តើមនៅពេលអនាគតដ៏ខ្លីឡើយ។

កម្មវិធី IMF គឺសំដៅដល់ប្រទេសនៃភាគី CMIM ដែលបានរៀបចំកម្មវិធីសេដ្ឋកិច្ចសម្រាប់ជំនួយហិរញ្ញវត្ថុដែលបានព្រមព្រៀងគ្នារវាង IMF និងរដ្ឋាភិបាលនៃភាគី CMIM នោះ។

ការប្រាក់ចំពោះការទូទាត់សងយឺត មានន័យដូចមានចែងក្នុងមាត្រា ៧.២.៦។

LIBOR មានន័យដូចមានចែងក្នុងមាត្រា ៧.២.៤ (ក)។

រូបិយវត្ថុក្នុងស្រុក របស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ គឺសំដៅលើប្រភេទរូបិយវត្ថុដែលត្រូវចេញផ្សាយ និងប្រើប្រាស់ជាប្រាក់កាស ស្របតាមច្បាប់នៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ហើយរូបិយប័ណ្ណនោះត្រូវបានប្រើប្រាស់ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណនៅក្នុងប្រតិបត្តិការទាំងឡាយដែលតម្រូវឱ្យប្រើរូបិយវត្ថុក្នុងស្រុកធ្វើជាលក្ខខណ្ឌសម្រាប់ការទិញរូបិយប័ណ្ណដុល្លារអាមេរិក ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោមយន្តការ CMIM ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ។

បរិមាណរូបិយវត្ថុក្នុងស្រុក មានន័យដូចកំណត់ក្នុងមាត្រា ៧.២.២ (ខ)។

ចំនួនទឹកប្រាក់អតិបរមានៃការដោះដូររូបិយប័ណ្ណ របស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗ គឺសំដៅដល់ចំនួនទឹកប្រាក់**អតិបរមា** ដែលអាចត្រូវបានទិញដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ហើយនៅពេលណាក៏ដោយចំនួនទឹកប្រាក់នោះនៅតែមានសុពលភាព ពោលគឺសំដៅលើវិភាគទាន CMIM របស់ភាគី CMIM នោះ គុណនឹង "មេគុណនៃការទិញ" ដូចដែលមានចែងសម្រាប់ភាគី CMIM នោះ នៅក្នុងតារាងកម្មវិធីទី១។

ក្រុមអ្នកធ្វើការសម្រេចកម្រិតរដ្ឋមន្ត្រី (MLDMB) សំដៅដល់ក្រុមអ្នកធ្វើការសម្រេចកម្រិតនយោបាយថ្នាក់រដ្ឋមន្ត្រីនៅក្នុងយន្តការនៃការធ្វើការសម្រេចរបស់ CMIM។ ក្រុមនេះមាន

សមាសភាពជារដ្ឋមន្ត្រីហិរញ្ញវត្ថុទាំង ១៣ ដែលជាតំណាងរបស់ប្រទេសអាស៊ានបូកបី និងជាអ្នកទទួលខុសត្រូវក្នុងការធ្វើការសម្រេចពាក់ព័ន្ធនឹងបញ្ហាគោលការណ៍សំខាន់ៗ។

ទុនបម្រុងអន្តរជាតិដុលផ្លូវការ មានន័យដូចមានចែងក្នុងមាត្រា ១១.៤.២។

ចំនួនទឹកប្រាក់មិនបានទូទាត់តាមពេលកំណត់ មានន័យដូចមានចែងក្នុងមាត្រា៧.២.៦។

ប្រទេសបូកបី សំដៅដល់ (i) សាធារណរដ្ឋប្រជាមានិតចិន "ចិន" (ii) ជប៉ុន និង (iii) សាធារណរដ្ឋកូរ៉េ "កូរ៉េ"។

ការទិញ សំដៅដល់ការទិញរូបិយប័ណ្ណដុល្លារអាមេរិកដោយភាគីស្នើសុំការដោះដូររូបិយ-ប័ណ្ណ ជាការដោះដូរដោយលក់រូបិយវត្ថុក្នុងស្រុករបស់ខ្លួនទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណ។

ការបន្តកិច្ចសន្យាដកប្រាក់ មានន័យដូចកំណត់ក្នុងមាត្រា ៧.៣.២។

ការលក់ សំដៅដល់ការលក់រូបិយប័ណ្ណដុល្លារអាមេរិក ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណទល់នឹងការទិញរូបិយវត្ថុក្នុងស្រុកពីភាគីស្នើសុំការដោះដូររូបិយប័ណ្ណ។

ប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ (i) ចំពោះភាគីផ្តល់ការដោះដូររូបិយប័ណ្ណ (លើកលែងតែអាជ្ញាធររូបិយវត្ថុហុងកុង) គឺសំដៅដល់ប្រទេសម្ចាស់ផ្ទះនៃភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និង (ii) ចំពោះអាជ្ញាធររូបិយវត្ថុហុងកុង ប្រទេសផ្តល់ការដោះដូររូបិយប័ណ្ណ គឺសំដៅដល់ហុងកុងនៃប្រទេសចិន។ ផ្អែកតាមបរិបទជាក់ស្តែង ប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ គឺអាចសំដៅលើរដ្ឋាភិបាល។

ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ សំដៅដល់ភាគីមួយនៃ CMIM (ជាធនាគារកណ្តាល ហើយក្នុងករណីប្រទេសជប៉ុន និងប្រ៊ុយណេ គឺក្រសួងហិរញ្ញវត្ថុក៏ពាក់ព័ន្ធដែរ) ដែលលក់រូបិយប័ណ្ណដុល្លារអាមេរិកទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ក្នុងប្រតិបត្តិការដោះដូររូបិយប័ណ្ណ នៅក្រោមយន្តការ CMIM ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM ដោយផ្អែកលើមូលដ្ឋាននៃការរួមវិភាគទាន CMIM ដោយភាគី CMIM នៅក្នុងយន្តការ CMIM នេះ។

សំណើសុំដោះដូររូបិយប័ណ្ណ សំដៅដល់សំណើជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ ដើម្បីទិញរូបិយប័ណ្ណដុល្លារអាមេរិក នៅក្រោមយន្តការ CMIM និងរាប់បញ្ចូលទាំងសំណើបន្តកិច្ចសន្យាដកប្រាក់ផងដែរ។

ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ (i) ចំពោះភាគីស្នើសុំការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ (លើកលែងអាជ្ញាធររូបិយវត្ថុហុងកុង) គឺប្រទេសម្ចាស់ផ្ទះនៃភាគីស្នើសុំការដោះដូររូបិយប័ណ្ណនោះ និង(ii) ចំពោះអាជ្ញាធររូបិយវត្ថុហុងកុងដែលជាភាគីស្នើសុំការដោះដូរ

រូបិយប័ណ្ណ គឺហុងកុងប្រទេសចិន។ ផ្អែកតាមបរិបទជាក់ស្តែងប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ គឺអាចសំដៅលើរដ្ឋាភិបាល។

លិខិតស្នើសុំដោះដូររូបិយប័ណ្ណ មានន័យដូចកំណត់ក្នុងមាត្រា ៥.២.១។

ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ សំដៅដល់ភាគីមួយនៃ CMIM (ជាធនាគារកណ្តាល ហើយក្នុងករណីប្រទេសជប៉ុន និងប្រ៊ុយណេ គឺក្រសួងហិរញ្ញវត្ថុក៏ពាក់ព័ន្ធដែរ) ដែលជាអ្នកធ្វើសំណើសុំទិញរូបិយប័ណ្ណដុល្លារអាមេរិកនៅក្រោមយន្តការ CMIM តាមរបៀបយបប្រតិបត្តិការដោះដូររូបិយប័ណ្ណ ស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ។

បំណុលរយៈពេលខ្លីបីខែ មានន័យដូចមានចែងក្នុងមាត្រា ១១.៤.៣។

ចំនួនទឹកប្រាក់ទុនបម្រុងកម្រិតអប្បបរមា មានន័យដូចមានចែងក្នុងមាត្រា១១.៤.២។

ទុនបម្រុងអន្តរជាតិអាចប្រើប្រាស់បាន មានន័យដូចមានចែងក្នុងមាត្រា១១.៤.២។

រូបិយប័ណ្ណដុល្លារអាមេរិក មានន័យដូចមានចែងក្នុងមាត្រា១។

បរិមាណរូបិយប័ណ្ណដុល្លារអាមេរិក មានន័យដូចមានចែងក្នុងមាត្រា៧.២.២(ខ)។

កាលបរិច្ឆេទកំណត់ការប្រាក់ មានន័យដូចមានចែងក្នុងមាត្រា ៧.២.៤។

២.២ ការបកស្រាយ

លើកលែងតែមានការបញ្ជាក់យ៉ាងច្បាស់ នៅក្នុងសេចក្តីយោងនៃមាត្រាណាមួយ ត្រូវជាសេចក្តីយោងរបស់មាត្រានៃកិច្ចព្រមព្រៀង CMIM នេះ និងសេចក្តីយោងរបស់តារាងកម្មវិធីណាមួយ ត្រូវជាសេចក្តីយោងរបស់តារាងកម្មវិធីភ្ជាប់នឹងកិច្ចព្រមព្រៀង CMIM នេះ។ តារាងកម្មវិធី និងសេចក្តីពន្យល់បន្ថែមនៃជើងទំព័រ បង្កើតជាផ្នែកនៃកិច្ចព្រមព្រៀង CMIM នេះ។ ផ្អែកលើបរិបទដែលសមស្របនៃកិច្ចព្រមព្រៀងនេះ វាក្យស័ព្ទដែលត្រូវបានកំណត់និយមន័យនិងប្រើប្រាស់នៅក្នុងកិច្ចព្រមព្រៀង CMIM នេះ ជាទម្រង់ក្នុងនាមឯកវចនៈ អាចត្រូវបានប្រើជាទម្រង់ពហុវចនៈ និងផ្ទុយទៅវិញ។

សេចក្តីយោងណាមួយនៅក្នុងកិច្ចព្រមព្រៀង CMIM នេះ ចំពោះកិរិយាស័ព្ទមួយនឹងត្រូវបានយល់ន័យដោយយោងតាមនាមដែលប្រើជាមួយគ្នានោះ និងផ្ទុយទៅវិញ។

ចំណងជើង និងចំណងជើងរងដែលត្រូវបានប្រើនៅក្នុងមាត្រាទាំងឡាយនៃកិច្ចព្រមព្រៀង CMIM នេះ គឺសម្រាប់សម្រួលដល់ការធ្វើសេចក្តីយោងតែប៉ុណ្ណោះ និងមិនប៉ះពាល់ដល់ការបកស្រាយខ្លឹមសារនៃបទបញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀង CMIM នេះ។

មាត្រា ៣.- ការបង្កើតពហុភាគីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ CMIM

យន្តការ CMIM ដែលបានបង្កើតដោយកិច្ចព្រមព្រៀង CMIM បង្កើតបានជាប្រព័ន្ធសម្របសម្រួលសម្រាប់ការអនុវត្តប្រតិបត្តិការដោះដូររូបិយប័ណ្ណ ក្នុងចំណោមបណ្តាភាគីនៃ

CMIM (និងជាពិសេសធនាគារកណ្តាល) ក្នុងគោលបំណងដើម្បីសម្រេចឱ្យបានតាមគោលដៅ ដែលបានចែងនៅក្នុងមាត្រា១។ ទំហំទឹកប្រាក់សរុបនៃយន្តការ CMIM មានចំនួន ១២០,០០០,០០០,០០០ដុល្លារអាមេរិក (មួយរយម្ភៃពាន់លានដុល្លារអាមេរិក) ដែលទំហំទឹកប្រាក់សរុបនេះរួមមាន វិភាគទាន CMIM របស់បណ្តាភាគី CMIM ដូចមានចែង និងយោងក្នុងមាត្រា៣ និងតារាងកម្មវិធីទី១។

៣.១. វិភាគទានហិរញ្ញវត្ថុ

បណ្តាភាគី CMIM មានកាតព្វកិច្ចដាក់វិភាគទានសរុបនៅក្នុងយន្តការ CMIM នូវចំនួនដែលបានកំណត់នៅក្នុងតារាងកម្មវិធីទី១ ស្របតាមកិច្ចព្រមព្រៀង CMIM នេះ។ សម្រាប់គោលបំណងនៃមាត្រា៣ រូបិយប័ណ្ណដុល្លារអាមេរិកក្នុងចំនួនណាមួយ ដែលត្រូវទទួលមកវិញរបស់ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ដោយសារតែការទិញយកវិញនូវរូបិយវត្ថុក្នុងស្រុក ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវដាក់បញ្ចូលទៅក្នុងការគណនានៃវិភាគទាន CMIM ដែលមានសម្រាប់សំណើសុំដោះដូររូបិយប័ណ្ណ ក្នុងពេលណាមួយ។

៣.២ ភស្តុតាងនៃការសន្យា

ភស្តុតាងនៃកាសន្យារបស់ខ្លួននៅក្នុងយន្តការ CMIM ធនាគារកណ្តាលនីមួយៗត្រូវប្រតិបត្តិ និងប្រគល់លិខិតសន្យាដូចមានចែងនៅក្នុងតារាងកម្មវិធីទី៣ ទៅឱ្យធនាគារកណ្តាលទាំង ១៣ ផ្សេងទៀត ក្នុងពេលដំណាលគ្នានឹងកាលបរិច្ឆេទអនុវត្តកិច្ចព្រមព្រៀង CMIM នេះ។

៣.៣ សិទ្ធិ និងកាតព្វកិច្ច

កាតព្វកិច្ចនៃភាគី CMIM នីមួយៗ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ មានច្រើន ប៉ុន្តែមិនមែនជាកាតព្វកិច្ចរួមគ្នានោះទេ។ ការខកខានរបស់ភាគីមួយនៃ CMIM ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀង CMIM នេះ មិនប៉ះពាល់ដល់កាតព្វកិច្ចរបស់ភាគីមួយផ្សេងទៀតនៃ CMIM ក្រោមកិច្ចព្រមព្រៀង CMIM នេះទេ។ គ្មានភាគី CMIM ណាមួយទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ភាគី CMIM ផ្សេងទៀត ក្រោមកិច្ចព្រមព្រៀង CMIM នេះទេ (ដើម្បីជៀសវាងការមន្ទិលកាតព្វកិច្ចនៅទីនេះ គឺជាកម្មវត្ថុនៃយន្តការវិភាជន៍ស្របមាត្រា៧.១.១)។ ដូចគ្នានេះដែរ ទោះក្នុងករណីណាក៏ដោយ ក្រសួងហិរញ្ញវត្ថុចិន និង ធនាគារប្រជាជនចិន មិនត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់អាជ្ញាធររូបិយវត្ថុហុងកុងទេ។ សិទ្ធិរបស់ភាគីCMIM នីមួយៗក្រោម ឬពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង CMIMនេះ គឺជាសិទ្ធិដាច់ដោយឡែកនិងឯករាជ្យពីគ្នា ហើយកាតព្វកិច្ចដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ពីភាគីមួយនៃCMIM ដល់ភាគីមួយទៀតនៃ CMIM គឺជាកាតព្វកិច្ចដាច់ដោយឡែក និងឯករាជ្យពីគ្នា។ ភាគីមួយនៃ CMIM

អាចប្រតិបត្តិដាច់ដោយឡែកនូវសិទ្ធិរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេះ លើកលែងតែមានចែងផ្សេងក្នុងកិច្ចព្រមព្រៀង CMIM នេះ។

មាត្រា ៤.- ថ្នាក់ធ្វើសេចក្តីសម្រេចលើ CMIM

៤.១ ក្រុមអ្នកធ្វើការសម្រេចរបស់ CMIM

ការធ្វើការសម្រេចពាក់ព័ន្ធនឹងយន្តការ CMIM ត្រូវធ្វើឡើងដោយក្រុមអ្នកធ្វើការសម្រេចរបស់ CMIM និងស្របតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀង CMIM នេះ។ សមាមាសភាពនៃក្រុមអ្នកធ្វើការសម្រេចរបស់ CMIM មានចែងនៅក្នុងតារាងកម្មវិធីទី២។

៤.២ គោលការណ៍នៃការធ្វើសេចក្តីសម្រេចរបស់ CMIM

វិសាលភាពនៃអំណាចធ្វើការសម្រេច និងលក្ខខណ្ឌនៃប្រតិបត្តិការរបស់ក្រុមអ្នកធ្វើការសម្រេចកម្រិតនយោបាយថ្នាក់រដ្ឋមន្ត្រី (MLDMB) និង ក្រុមអ្នកធ្វើការសម្រេចកម្រិតប្រតិបត្តិ (ELDMB) មានចែងនៅក្នុងតារាងកម្មវិធីទី២។

មាត្រា ៥.- ប្រទេសសម្របសម្រួល

៥.១ ប្រទេសសម្របសម្រួល

ប្រទេសសម្របសម្រួលចំនួនពីរ (រួមគ្នាហៅថា"បណ្តាប្រទេសសម្របសម្រួល" ហើយប្រទេសមួយៗហៅថា "ប្រទេសសម្របសម្រួលមួយ") ត្រូវបានជ្រើសតាំងដូចខាងក្រោមៈ

៥.១.១ ប្រទេសសម្របសម្រួល គឺប្រទេសទាំងពីរដែលធ្វើជាសហប្រធាននៃកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលរងធនាគារកណ្តាលអាស៊ានបូកបីៈ ប្រទេសសម្របសម្រួលមួយត្រូវមកពីរដ្ឋជាសមាជិកអាស៊ាន និងប្រទេសមួយទៀត ត្រូវមកពីប្រទេសមួយក្នុងចំណោមប្រទេសបូកបី។

៥.១.២ ប្រសិនបើប្រទេសសម្របសម្រួលមួយដែលត្រូវបានតែងតាំងជាមុន បានដាក់សំណើសុំការដោះដូររូបិយប័ណ្ណ ដែលត្រូវសុំការសម្រេច ឬប្រតិបត្តិការដោះដូររូបិយប័ណ្ណពាក់ព័ន្ធនឹងសំណើនេះបានកើតឡើង នោះសហប្រធានដែលត្រូវដល់វេនបន្ទាប់នៃកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាលអាស៊ានបូកបី ត្រូវដើរតួនាទីជាប្រទេសសម្របសម្រួល។ ដើម្បីចៀសវាងការមន្ទិល ភាគី CMIM ណាមួយដែលបានដកខ្លួន មិនមានសិទ្ធិធ្វើជាប្រទេសសម្របសម្រួលបានទេ ស្របតាមបទបញ្ញត្តិនៃមាត្រា៥.១។

៥.១.៣ ការប្តូរវេនវិលជុំប្រព្រឹត្តទៅជាបន្តតាមលំដាប់លំដោយ ដូចខាងក្រោមៈ "បច្ចុប្បន្ន" "បន្ទាប់" "ពីមុន" "២ឆ្នាំក្រោយ" "២ឆ្នាំមុន" "៣ឆ្នាំក្រោយ" និង"៣ឆ្នាំមុន"។

៥.២ ដំណើរការសម្របសម្រួល និង ភារកិច្ចទទួលខុសត្រូវរបស់ប្រទេសសម្របសម្រួល

ដំណើរការសម្របសម្រួលសម្រាប់សំណើសុំការដោះដូររូបិយប័ណ្ណណាមួយ ត្រូវធ្វើដូចខាងក្រោម ហើយតួនាទី និងការទទួលខុសត្រូវរួមគ្នារបស់បណ្តាប្រទេសសម្របសម្រួល និងមានដូចខាងក្រោម៖

៥.២.១ ប្រកាសសំណើសុំការដោះដូររូបិយប័ណ្ណ និងកិច្ចចាប់ផ្តើមដំណើរការសម្រាប់ការកោះប្រជុំ ELDMB: ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវដាក់លិខិតស្នើសុំការដោះដូររូបិយប័ណ្ណ ("ប្រកាសសំណើសុំការដោះដូររូបិយប័ណ្ណ") ទៅប្រទេសសម្របសម្រួលនីមួយៗ។ នៅពេលទទួលបានលិខិតស្នើសុំការដោះដូររូបិយប័ណ្ណ ប្រទេសសម្របសម្រួលត្រូវបញ្ជូនលិខិតនេះ ទៅសមាជិកផ្សេងទៀតនៃ ELDMB ក្នុងរយៈពេល ២ ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលលិខិតសំណើសុំការដោះដូររូបិយប័ណ្ណ ត្រូវបានប្រគល់ឱ្យទៅបណ្តាប្រទេសសម្របសម្រួល និងកោះប្រជុំ ELDMB ស្របតាមគោលការណ៍នៃការធ្វើការសម្រេចរបស់ CMIM ដូចមានចែងក្នុងតារាងកម្មវិធីទី២។ នៅក្នុងមាត្រា៥.២.១"ថ្ងៃធ្វើការ" សំដៅដល់ថ្ងៃនៃសប្តាហ៍ លើកលែងតែថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកជាសាធារណៈ ដែលថ្ងៃនោះគ្រឹះស្ថានធនាគារនៅបណ្តាប្រទេសសម្របសម្រួលបើកទ្វារដល់សាធារណៈ សម្រាប់ការអនុវត្តសកម្មភាពធនាគារជាប្រក្រតីរបស់ខ្លួនក្នុងអំឡុងម៉ោងធ្វើការធម្មតា។ បន្ថែមលើការកំណត់របៀបវារៈ កាលវិភាគ និងទម្រង់ដែលស្នើឡើងដោយបណ្តាប្រទេសសម្របសម្រួល ដើម្បីកោះប្រជុំ ELDMB លិខិតស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវបង្ហាញនូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការស្នើសុំការដោះដូររូបិយប័ណ្ណ មានជាអាទិ៍ អត្តសញ្ញាណរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ចំនួនទឹកប្រាក់នៃសំណើសុំការដោះដូរ ហេតុផលរបស់ភាគីស្នើសុំធ្វើការដោះដូររូបិយប័ណ្ណ វិភាជន៍នៃចំនួនទឹកប្រាក់នៃសំណើសុំការដោះដូររូបិយប័ណ្ណក្នុងចំណោមបណ្តាភាគី CMIM ដែលមានសិទ្ធិក្នុងការធ្វើការសម្រេច និងលក្ខខណ្ឌពិសេសផ្សេងទៀតដែលបណ្តាប្រទេសសម្របសម្រួលកំណត់ថាមានការពាក់ព័ន្ធ។

៥.២.២ ដំណាក់កាលសម្របសម្រួលមុនពេលបោះឆ្នោតដោយ ELDMB: បន្ទាប់ពីការប្រគល់លិខិតស្នើសុំការដោះដូររូបិយប័ណ្ណ ស្របតាមមាត្រា ៥.២.១ ខាងលើ បណ្តាប្រទេសសម្របសម្រួលត្រូវទទួលខុសត្រូវក្នុងការប្រើចំណាត់ការ ជាជំហានដំបូងដូចខាងក្រោម មុននឹងធ្វើការកោះប្រជុំបោះឆ្នោតស្របតាមមាត្រា ៥.២.៣៖

<u>(ក) រៀបចំកិច្ចពិភាក្សាអំពីរបាយការណ៍ឃ្លាំមើល</u>

បណ្តាប្រទេសសម្របសម្រួលត្រូវចែករបាយការណ៍ស្តីពីម៉ាក្រូសេដ្ឋកិច្ចក្នុងពេលថ្មីៗ ដែលទទួលបានពីភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដូចមានចែងក្នុងមាត្រា១០.១.៤។ របាយការណ៍នោះ ត្រូវមានព័ត៌មានពាក់ព័ន្ធនានា ស្តីពីមូលហេតុដែលនាំឱ្យមានបញ្ហាជញ្ជីងទូទាត់ និង/ឬ

ស្ថានភាពសាច់ប្រាក់ និងការចាត់វិធានការ ដើម្បីដោះស្រាយស្ថានភាពនេះ។ បណ្តាប្រទេសសម្របសម្រួលត្រូវអញ្ជើញភាគីស្នើសុំការដោះដូរប្តូរបិយប័ណ្ណ ឱ្យធ្វើការពន្យល់ប្រាប់ដល់សមាជិកនៃ ELDMB។ បណ្តាប្រទេសសម្របសម្រួលក៏ត្រូវចែករចាយការណ៍របស់ភាគីទីបី ដែលពាក់ព័ន្ធផងដែរ (ស្របតាមមាត្រា១០.១.៥(ខ)) សម្រាប់សមាជិកធ្វើការពិចារណា និងពិភាក្សា។

(ខ) ការទទួលធាតុចូលដំហានដំបូងពីសមាជិក ELDMB

បន្ទាប់ពីទទួលបានលិខិតស្នើសុំការដោះដូរប្តូរបិយប័ណ្ណ ពីបណ្តាប្រទេសសម្របសម្រួល សមាជិកនីមួយៗនៃ ELDMB ត្រូវផ្តល់ព័ត៌មានទៅបណ្តាប្រទេសសម្របសម្រួល អំពីបញ្ហាដូចខាងក្រោម៖

(i) ថាតើខ្លួនអាចចូលរួមក្នុងកិច្ចប្រជុំ ELDMB ដែលបានស្នើឡើងដែរឬទេ ដោយអនុលោមតាមកាលវិភាគកំណត់ក្នុងលិខិតស្នើសុំការដោះដូរប្តូរបិយប័ណ្ណ

(ii) ថាតើខ្លួនមានការបារម្ភ ឬទស្សនៈពិសេសណាមួយឬទេ ពាក់ព័ន្ធនឹងលទ្ធភាពរបស់ភាគីស្នើសុំការដោះដូរប្តូរបិយប័ណ្ណ ក្នុងការបំពេញតាមលក្ខខណ្ឌពាក់ព័ន្ធដែលមានពីមុន ដូចមានចែងក្នុងមាត្រា១០

(iii) ថាតើខ្លួនមានបំណងដកខ្លួនចេញពីការចូលរួមឬទេ ទាក់ទងនឹងសំណើសុំការដោះដូរប្តូរបិយប័ណ្ណនេះ ស្របតាមបទបញ្ញត្តិនៃមាត្រា៨ (ដើម្បីចៀសវាងការមន្ទិល ករណីនេះនឹងមិនចាំបាច់មានលិខិតសម្រាប់ការដកខ្លួន ដែលតម្រូវនៅក្រោមមាត្រា៨.២ ទេ) និង

(iv) ថាតើខ្លួនមានការបារម្ភ ទស្សនៈ ឬការជំទាស់ជាក់លាក់ណាមួយឬទេ ពាក់ព័ន្ធនឹងរបៀបវារៈ កាលវិភាគ និងទម្រង់ និងបញ្ហាដែលបានស្នើឡើងសម្រាប់កិច្ចប្រជុំ ELDMB នៅក្នុងលិខិតស្នើសុំការដោះដូរប្តូរបិយប័ណ្ណ ឬក៏មានការបារម្ភផ្សេងទៀតឬទេពាក់ព័ន្ធនឹងកិច្ចប្រជុំ និង/ឬការបោះឆ្នោត ដែលស្នើឡើងទាក់ទិននឹងសំណើសុំការដោះដូរប្តូរបិយប័ណ្ណនោះ។

បន្ទាប់ពីទទួលបានធាតុចូលណាមួយពីសមាជិកនៃ ELDMB ដោយផ្អែកលើលក្ខខណ្ឌដែលមានសង្គតិភាពជាមួយនឹងសភាពការណ៍ និងភាពបន្ទាន់នៃសំណើសុំដោះដូរប្តូរបិយប័ណ្ណនោះ បណ្តាប្រទេសសម្របសម្រួល តាមរយៈការពិគ្រោះយោបល់ជាមួយ ELDMB ត្រូវធ្វើការពិចារណាលើធាតុចូល ការបារម្ភ និងទស្សនៈដំហានដំបូង ដែលបានផ្តល់ដោយសមាជិកនៃ ELDMB ហើយត្រូវធ្វើការកែសម្រួលឱ្យទាន់ពេលនិងត្រឹមត្រូវ ចំពោះរបៀបវារៈកាលវិភាគ និងទម្រង់ដែលបានស្នើឡើងសម្រាប់កិច្ចប្រជុំ ELDMB ប្រសិនបើបណ្តាប្រទេសសម្របសម្រួលគិតថាត្រឹមត្រូវ ហើយប្រសិនបើពិនិត្យឃើញថា នៅមានកង្វះព័ត៌មានចាំបាច់ជាក់លាក់ណាមួយ មុននឹងធ្វើការបោះឆ្នោត (រួមទាំងព័ត៌មានដែលបានចែងក្នុងមាត្រា ១០.១.៥) និងដោយ

មានសំណើរបស់សមាជិកណាមួយ បណ្ដាប្រទេសសម្របសម្រួលអាចស្នើសុំឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ផ្ដល់នូវពត៌មានចាំបាច់ទាំងនោះ។

៥.២.៣ ដំណើរការប្រព្រឹត្តទៅនៃការបោះឆ្នោត/ប្រតិបត្តិការដោះដូររូបិយប័ណ្ណៈ

បន្ទាប់ពីបំពេញចំណាត់ការជំហានដំបូងយោងតាមមាត្រា៥.២.១ និង៥.២.២ ខាងលើ ពាក់ព័ន្ធនឹងសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ បណ្ដាប្រទេសសម្របសម្រួលនឹងកោះឱ្យមានការប្រជុំនៃ ELDMB តាមកាលវិភាគដូចបានចែងក្នុងមាត្រា៧.១.៣ ដើម្បីបោះឆ្នោតសម្រេចចំពោះការងារពាក់ព័ន្ធទាំងអស់ ស្របតាមបទបញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀង CMIM នេះ រួមទាំងការអនុម័តលើសំណើពាក់ព័ន្ធនឹងការដកខ្លួនចេញ ដោយអនុលោមតាមមាត្រា៨.១ និងការអនុម័តលើសំណើសុំការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធ។ បណ្ដាប្រទេសសម្របសម្រួលនឹងជូនដំណឹងភ្លាម ដល់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណអំពីលទ្ធផលនៃការបោះឆ្នោតទាំងអស់។ លើសពីនេះទៀត ប្រសិនបើ ELDMB ផ្ដល់ការអនុម័តលើសំណើសុំការដោះដូររូបិយប័ណ្ណ នោះបណ្ដាប្រទេសសម្របសម្រួលនឹងជូនដំណឹងភ្លាមទៅបណ្ដាភាគីនៃ CMIM ដែលមានសន្លឹកឆ្នោតមានប្រសិទ្ធិភាព អំពីលទ្ធផលវិភាជន៍ស្របតាមមាត្រា ៧.១.២ និងណែនាំបណ្ដាភាគីទាំងនោះ (ដោយមិនគិតថាតើភាគីណាមួយក្នុងចំណោមភាគីទាំងនោះបានបោះឆ្នោតគាំទ្រ ឬបោះឆ្នោតជំទាស់ចំពោះសំណើសុំការដោះដូររូបិយប័ណ្ណនោះឡើយ) ឱ្យបន្តដំណើរការអនុវត្តប្រតិបត្តិការនៃការដោះដូររូបិយប័ណ្ណទ្វេភាគី រវាងភាគីផ្ដល់ការដោះដូររូបិយប័ណ្ណនីមួយៗ ជាមួយនឹងភាគីស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធឱ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន ហើយទោះក្នុងព្រឹត្តិការណ៍ណាមួយ គឺមិនត្រូវយឺតជាងមួយសប្ដាហ៍គិតចាប់ពីកាលបរិច្ឆេទដែល ELDMB បានផ្ដល់ការអនុម័តលើសំណើសុំការដោះដូររូបិយប័ណ្ណ ហើយដែលកាលបរិច្ឆេទនៃប្រតិបត្តិការដោះដូររូបិយប័ណ្ណទ្វេភាគីមិនត្រូវតិចជាង ៩០ថ្ងៃឡើយ ដូចបានចែងក្នុងមាត្រា៧.២.៣ ស្របតាមបទបញ្ញត្តិនៃមាត្រា៧ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀតនៃកិច្ចព្រមព្រៀង CMIM នេះ។

៥.២.៤ តារាងសង្ខេបកិច្ចដំណើរការ

ក្នុងគោលបំណងសម្រាប់ភាពងាយស្រួលនៃការយោង និងការបញ្ជាក់ តារាងកម្មវិធីទី៨ កំណត់អំពីសេចក្ដីសង្ខេបក្នុងទម្រង់ជាគំនូសបំព្រួញនៃកិច្ចដំណើរការ ដែលមានចែងក្នុងកិច្ចព្រមព្រៀងCMIM នេះ រួមទាំងការទទួលខុសត្រូវរបស់បណ្ដាប្រទេសសម្របសម្រួល។

<u>មាត្រា៦ .. ការចូលរួមរបស់ហុងកុងប្រទេសចិន</u>

បន្ថែមលើបទបញ្ញត្តិ និងលក្ខខណ្ឌផ្សេងទៀត ដែលអាចអនុវត្តបានដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង CMIMនេះ ការចូលរួមរបស់ហុងកុងតាមរយៈប្រទេសចិននៅក្នុងកិច្ចព្រមព្រៀង

CMIM នេះ និងយន្តការពាក់ព័ន្ធផ្សេងទៀតស្របតាម CMIM នេះ ត្រូវមានព្រមទទួលយកដោយឈរលើមូលដ្ឋាន និងជាកម្មវត្ថុនៃលក្ខខណ្ឌដូចខាងក្រោម៖

(a) ហុងកុងប្រទេសចិន នឹងមិនស្វះស្វែងដើម្បីក្លាយខ្លួនជាសមាជិកនៃប្រទេសអាស៊ានបូកបីទេ។

(b) វិភាគទាន CMIM របស់ហុងកុងប្រទេសចិនត្រូវមានប្រភពចេញពីទុនបំរុងអន្តរជាតិរបស់ខ្លួនផ្ទាល់។

(c) ហុងកុងប្រទេសចិន អាចទិញរូបិយប័ណ្ណដុល្លារអាមេរិកដោយផ្ទាល់ពីយន្តការ CMIM ដែលប្រតិបត្តិដោយបណ្តាភាគី CMIM នៅពេលដែលខ្លួនត្រូវការជំនួយពីបណ្តាភាគី CMIM ហើយសំណើសុំជំនួយ (ពោលគឺ សំណើសុំការដោះដូររូបិយប័ណ្ណ) របស់ហុងកុងប្រទេសចិន គឺត្រូវបានធ្វើឡើងតាមរយៈប្រទេសចិន។ ចំនួនទឹកប្រាក់អតិបរមានៃការដោះដូររូបិយប័ណ្ណរបស់ហុងកុងប្រទេសចិន នៅក្រោមយន្តការ CMIM នេះ ត្រូវកំណត់ត្រឹមចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌរបស់ IMF ដែលអនុវត្តចំពោះហុងកុងប្រទេសចិនពីព្រោះហុងកុងប្រទេសចិនខ្លួនឯង មិនមែនជាសមាជិករបស់ IMF ទេ។

(d) សិទ្ធិរបស់ហុងកុងប្រទេសចិន ក្នុងការបោះឆ្នោតចំពោះការធ្វើការសម្រេចនានាដោយក្រុមអ្នកធ្វើការសម្រេចរបស់ CMIM ត្រូវបានដាក់កំហិតត្រឹមតម្រិតប្រតិបត្តិប៉ុណ្ណោះ ដើម្បីចៀសវាងការមន្ទិល សម្លេងឆ្នោតរបស់ហុងកុងប្រទេសចិនមិនត្រូវបានរាប់ និងមិនត្រូវបានចាត់ទុកជាផ្នែកមួយនៃការអនុម័តជាឯកច្ឆន្ទរបស់ MLDMB ទេ។

មាត្រា៧ .. មធ្យោបាយនៃការដោះដូររូបិយប័ណ្ណពហុភាគី

៧.១ របនាសម្ព័ន្ធពហុភាគី និងការចាត់ចែងសំណើសុំការដោះដូររូបិយប័ណ្ណ

៧.១.១ របនាសម្ព័ន្ធគ្រឹះពហុភាគី: កិច្ចព្រមព្រៀង CMIM នេះ បង្កើតនូវមធ្យោបាយនៃការដោះដូររូបិយប័ណ្ណពហុភាគី ក្នុងការរៀបចំទម្រង់ CMIM ក្នុងចំណោមបណ្តាភាគី CMIM ដែល (a) រៀបចំបង្កើត CMIM ដោយអនុលោមតាមកិច្ចព្រមព្រៀង CMIM នេះ បង្កើតជាប្រភពមូលនិធិសម្រាប់គាំទ្រផ្នែកហិរញ្ញវត្ថុដែលត្រូវការចាំបាច់ ដោយធ្វើឡើងក្រោមការរៀបចំ CMIM និង (b) តម្រូវឱ្យបណ្តាភាគី CMIM ធ្វើកិច្ចសហប្រតិបត្តិការក្នុងការផ្តល់មូលនិធិជារូបិយប័ណ្ណដុល្លារអាមេរិកដែលពួកគេមានក្រោមការរៀបចំ CMIM ទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណណាមួយ នៅពេលដែលភាគីស្នើសុំការដោះដូររូបិយប័ណ្ណត្រូវការបន្ទាប់ពីបានដាក់សំណើសុំការដោះដូររូបិយប័ណ្ណ ដែលមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការគាំទ្រ និងស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ។ ចំនួនទឹកប្រាក់រូបិយប័ណ្ណដុល្លារអាមេរិក ដែលត្រូវលក់ទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធត្រូវធ្វើវិភាជន៍

ដោយផ្អែកលើមូលដ្ឋានសមាមាត្រក្នុងចំណោមបណ្តាភាគី CMIM ហើយការធ្វើវិភាជន៍តាមសមាមាត្រនេះត្រូវធ្វើឡើងដោយយោងទៅលើស្ថានភាពរូបិយប័ណ្ណដុល្លារអាមេរិក (ដូចមានចែងខាងក្រោម) ដែលត្រូវបានលក់ឱ្យដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណ។ តារាងកម្មវិធីទី៨កំណត់អំពីសេចក្តីសង្ខេបក្នុងទម្រង់តារាងបំព្រួញនូវបទបញ្ញត្តិ អំពីមធ្យោបាយនៃការដោះដូររូបិយប័ណ្ណពហុភាគី នៅក្រោមវិសាលភាពនៃមាត្រា៧ ដែលមានគោលបំណងធ្វើអោយងាយស្រួលនៃការធ្វើសេចក្តីយោង និងការបញ្ជាក់តែប៉ុណ្ណោះ។

៧.១.២ ការចាត់ចែងសំណើសុំការដោះដូររូបិយប័ណ្ណ

យោងតាមរចនាសម្ព័ន្ធពហុភាគីនៃការរៀបចំ CMIM ដែលបានបង្កើតឡើងនេះ រាល់លិខិតស្នើសុំការដោះដូររូបិយប័ណ្ណ ដែលត្រូវបានដាក់ជូនបណ្តាប្រទេសសម្របសម្រួល នឹងត្រូវបញ្ជូនដោយបណ្តាប្រទេសសម្របសម្រួលទាំងនោះទៅឱ្យ ELDMB ដូចមានចែងក្នុងមាត្រា ៥.២.១។ បន្ទាប់មក ELDMB ត្រូវកំណត់ថាតើសំណើសុំការដោះដូររូបិយប័ណ្ណមានគុណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ ដែលត្រូវគោរព និង/ឬបំពេញតាមលក្ខខណ្ឌនៃមាត្រា១០។ ដោយអនុលោមតាមការបោះឆ្នោត ELDMB ក្នុងការអនុម័តលើសំណើសុំការដោះដូររូបិយប័ណ្ណមួយ ការទទួលខុសត្រូវក្នុងការផ្តល់ចំនួនសរុបនៃរូបិយប័ណ្ណដុល្លារអាមេរិក ដែលត្រូវលក់ទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធត្រូវបានធ្វើវិភាជន៍តាមសមាមាត្រក្នុងចំណោមភាគីCMIM (លើកលែងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ភាគីដែលដកខ្លួនចេញពី CMIM ប្រសិនបើមាននិងភាគីមួយនៃ CMIM ដូចបានលើកឡើងក្នុងមាត្រា៧.១.៤ ប្រសិនបើមាន) ដោយផ្អែកលើវិភាគទានរបស់ភាគី CMIM នីមួយនោះ។ បណ្តាភាគី CMIM នីមួយៗទាំងនោះ ត្រូវអនុវត្តការដកប្រាក់ឬការបន្តកិច្ចសន្យាដកប្រាក់ តាមសភាពដូចបានចែងក្នុងមាត្រា៧.៣ ខាងក្រោមឱ្យបានឆាប់តាមដែលអាចធ្វើបាន និងក្នុងករណីណាក៏ដោយ គឺមិនត្រូវយឺតជាងមួយសប្តាហ៍បន្ទាប់ពីកាលបរិច្ឆេទ ដែល ELDMB អនុម័តលើសំណើសុំការដោះដូររូបិយប័ណ្ណនោះ។ (ដើម្បីជៀសវាងការមន្ទិល រយៈពេលមួយសប្តាហ៍នេះ ត្រូវរាប់បញ្ចូលទាំងរយៈពេលធ្វើលិខិតដូចមានចែងក្នុងមាត្រា ៧.៣.១ និង ៧.៣.១) តួនាទីរបស់បណ្តាប្រទេសសម្របសម្រួល និងការអនុវត្តភារកិច្ចរបស់ពួកគេ ត្រូវប្រព្រឹត្តទៅស្របតាមបទបញ្ញត្តិពាក់ព័ន្ធក្នុងមាត្រា៥។

៧.១.៣ តារាងពេលវេលាសម្រាប់ដំណើរការស្នើសុំការដោះដូររូបិយប័ណ្ណ: ដោយមានភាពបន្ទាន់ ដែលត្រូវបានស្មានទុកជាមុនពាក់ព័ន្ធនឹងសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ នឹងតាមរយៈបណ្តាប្រទេសសម្របសម្រួល និង ELDMB បានឯកភាពគ្នា នឹងចាត់រាល់វិធានការចាំបាច់ដើម្បីធានាថាការសម្រេច ដែលត្រូវធ្វើឡើងឆ្លើយតបទៅនឹងសំណើសុំ

ការដោះដូររូបិយប័ណ្ណនឹងត្រូវបានធ្វើក្នុងរយៈពេលមួយសប្តាហ៍ បន្ទាប់ពីការប្រគល់លិខិតសំណើសុំការដោះដូររូបិយប័ណ្ណទៅឱ្យសមាជិកផ្សេងទៀតនៃ ELDMB តាមរយៈបណ្តាប្រទេសសម្របសម្រួលស្របតាមមាត្រា៩.២.១ ហើយក្នុងករណីណាក៏ដោយ គឺមិនត្រូវយឺតជាងពីរសប្តាហ៍បន្ទាប់ពីការប្រគល់លិខិតសំណើសុំការដោះដូររូបិយប័ណ្ណទៅឱ្យសមាជិកផ្សេងទៀតនៃ ELDMB តាមរយៈបណ្តាប្រទេសសម្របសម្រួល ស្របតាមមាត្រា៩.២.១។

៧.១.៤ ភាពគ្មានសិទ្ធិនៃភាគីស្នើសុំការដោះដូររូបិយប័ណ្ណក្នុងការធ្វើជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ: ភាគី CMIM ណាមួយ ដែលបានប្រគល់សំណើសុំការដោះដូររូបិយប័ណ្ណ ស្ថិតក្នុងការរង់ចាំ ឬដែលបានដកប្រាក់ ឬ បន្តកិច្ចសន្យាដកប្រាក់ដែលនៅមានសុពលភាព គឺមិនមានសិទ្ធិធ្វើជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណទេ រហូតដល់ពេលដែលសំណើសុំការដោះដូររូបិយប័ណ្ណ ឬការដកប្រាក់ ឬកាតព្វកិច្ចនៃការបន្តកិច្ចសន្យាដកប្រាក់លែងមានសុពលភាព។

៧.២ លក្ខខណ្ឌ និងកាលកំណត់សំខាន់ៗបានធ្វើឡើងក្នុងប្រតិបត្តិការដោះដូររូបិយប័ណ្ណនៅក្រោមមធ្យោបាយនៃការដោះដូរពហុភាគី

៧.២.១ ការលក់រូបិយប័ណ្ណ: ក្រោមការរៀបចំ CMIM រាល់ស្ថានភាពរូបិយប័ណ្ណទាំងអស់ ដែលបានលក់ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗ ស្របតាមលក្ខខណ្ឌ និងកាលកំណត់នៃកិច្ចព្រមព្រៀង CMIM នេះ ដែលត្រូវធ្វើឡើងជារូបិយប័ណ្ណដុល្លារអាមេរិក។

៧.២.២ របនាសម្ព័ន្ធនៃប្រតិបត្តិការដោះដូរ: រាល់ប្រតិបត្តិការលក់ និងទិញ ដែលបានធ្វើដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ និង ភាគីផ្តល់ការដោះដូររូបិយប័ណ្ណនីមួយៗ ស្របតាមសំណើសុំការដោះដូររូបិយប័ណ្ណមួយ ត្រូវបានអនុវត្តជាប្រតិបត្តិការដោះដូរ ដែលមានរចនាសម្ព័ន្ធដូចតទៅ :

រវាងភាគីផ្តល់ការដោះដូររូបិយប័ណ្ណនីមួយៗ និងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ:

(ក) ភាគីស្នើសុំការដោះដូររូបិយវត្ថុត្រូវប្រើប្រាស់រូបិយវត្ថុក្នុងស្រុករបស់ខ្លួន ដើម្បីទិញរូបិយប័ណ្ណដុល្លារអាមេរិក ដូចដែលត្រូវបានអនុម័តដោយការបោះឆ្នោតរបស់ ELDMB (ហៅថា ស្ថានភាពរូបិយប័ណ្ណដុល្លារអាមេរិក) ដែលត្រូវបានធ្វើវិភាជន៍ ដើម្បីលក់ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធនីមួយៗ។

(ខ) តម្លៃទិញរូបិយវត្ថុក្នុងស្រុក (ហៅថា បរិមាណរូបិយវត្ថុក្នុងស្រុក) ដែលត្រូវបានទូទាត់សម្រាប់បរិមាណរូបិយប័ណ្ណដុល្លារអាមេរិកស្របតាមកថាខ័ណ្ឌ(ក)ខាងលើ ត្រូវបានកំណត់ដោយការប្រើប្រាស់អត្រាប្តូរប្រាក់ដែលត្រូវយកមកប្រើ ដូចបានកំណត់តាមតារាងកម្មវិធីទី៤។

(c) យោងលើមាត្រា៧.២.៣ ៧.៣.៣ ១២.២.២ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងកិច្ចព្រមព្រៀង CMIM នេះ ភាគីស្នើសុំការដោះដូរ មានកាតព្វកិច្ចទិញយកវិញនូវបរិមាណរូបិយវត្ថុក្នុងស្រុកពីភាគីផ្តល់ការដោះដូរ ដោយធ្វើការទូទាត់ (រួមបញ្ចូលទាំងការប្រាក់) ជារូបិយប័ណ្ណដុល្លារអាមេរិក។ សម្រាប់គោលបំណងនេះ បរិមាណរូបិយវត្ថុក្នុងស្រុក ត្រូវបានគណនាផ្អែកលើមូលដ្ឋានអត្រាប្តូរប្រាក់រូបិយវត្ថុក្នុងស្រុកធៀបនឹងរូបិយប័ណ្ណដុល្លារអាមេរិក ដូចបានកំណត់ស្របតាមមាត្រា៧.២.២(b) នៅពេលដែលបរិមាណដុល្លារអាមេរិក បានលក់ទៅអោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណសម្រាប់ការដកប្រាក់ ឬ ការបន្តកិច្ចសន្យាដកប្រាក់នីមួយៗ។

៧.២.៣ ឥណប្រតិទាន រវាងភាគីផ្តល់ការដោះដូររូបិយប័ណ្ណពាក់ព័ន្ធនីមួយៗ និងភាគីស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធនីមួយៗ ជាគោលការណ៍ ការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់នីមួយៗ ត្រូវបានកំណត់ឥណប្រតិទានយ៉ាងតិច៩០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ (ក្នុងន័យនេះ ការប្រែប្រួលដែលលើសពី៩០ថ្ងៃនឹងត្រូវអនុញ្ញាតឱ្យបន្តកែសម្រួលកាលបរិច្ឆេទនៃការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ទៅជាថ្ងៃធ្វើការ) ហើយកាលបរិច្ឆេទឥណប្រតិទាននោះ ត្រូវកំណត់តាមរយៈការអនុម័តរបស់ ELDMB លើសំណើសុំការដោះដូររូបិយប័ណ្ណស្ថិតក្នុងរយៈពេល៩៧ថ្ងៃ បន្ទាប់ពីថ្ងៃដែល ELDMB អនុម័តសំណើសុំការដោះដូររូបិយប័ណ្ណ។ ប្រសិនបើកាលបរិច្ឆេទ ឥណប្រតិទានបែបនេះ ប៉ះចំកាលបរិច្ឆេទដែលមិនមែនជាថ្ងៃធ្វើការ កាលបរិច្ឆេទឥណប្រតិទាននោះ គឺជាថ្ងៃធ្វើការបន្ទាប់ ដោយគ្មានការកែសម្រួលការប្រាក់ពាក់ព័ន្ធនឹងការលើកថ្ងៃនេះទេ។ ចំពោះការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណត្រូវទិញយកវិញនូវរូបិយវត្ថុក្នុងស្រុកពីភាគីផ្តល់ការដោះដូររូបិយប័ណ្ណនៅកាលបរិច្ឆេទឥណប្រតិទាន ស្របតាមបទបញ្ញត្តិនៃមាត្រា៧.២.៥ខាងក្រោម ក្នុងលក្ខខណ្ឌដែលថា (i) ប្រសិនបើការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ត្រូវបន្តសុពលភាព នោះបទបញ្ញត្តិនៃមាត្រា៧.៣.២ ត្រូវអនុវត្តចំពោះការបន្តកិច្ចសន្យាដកប្រាក់នោះ និង (ii) ប្រសិនបើភាគីស្នើសុំការដោះដូររូបិយប័ណ្ណមានបំណងទិញយកវិញមុនកាលកំណត់ នោះបទបញ្ញត្តិនៃមាត្រា ៧.៣.៣ ត្រូវអនុវត្ត។

៧.២.៤ ការប្រាក់

(a) ការប្រាក់បង្គរដោយផ្អែកលើបរិមាណរូបិយប័ណ្ណជាដុល្លារអាមេរិក ដែលបានទិញនៅជំពាក់ បន្ទាប់ពីការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់នីមួយៗ តាមអត្រាការប្រាក់មួយស្មើនឹងអត្រា LIBOR សម្រាប់ប្រាក់បញ្ញើជាដុល្លារអាមេរិករយៈពេល៣ខែ ដែលបោះផ្សាយដោយ សមាគមនធនាគារិកចក្រភពអង់គ្លេស និងផ្សាយលើផ្ទាំងរបស់រ៉យទ័រ ទំព័រ LIBOR01 (LIBOR) នៅម៉ោង ១១:០០ ព្រឹក ម៉ោងនៅទីក្រុងឡុងដ៍ ក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃ

ធ្វើការនៅទីក្រុងឡុងដ៍ មុនកាលបរិច្ឆេទនៃការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ (ហៅថា កាលបរិច្ឆេទកំណត់អត្រាការប្រាក់) សម្រាប់ការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ដែលអាចអនុវត្តបាន បូកនឹងគម្លាត ដូចកំណត់ខាងក្រោម។

ការដកប្រាក់ /ការបន្តកិច្ចសន្យាដកប្រាក់	គម្លាត
ការដកប្រាក់ដំបូង+ ការបន្តកិច្ចសន្យាដកប្រាក់លើកទី១	១៥០ ចំណុចមូលដ្ឋាន
ការបន្តកិច្ចសន្យាដកប្រាក់លើកទី២ + លើកទី៣	២០០ ចំណុចមូលដ្ឋាន
ការបន្តកិច្ចសន្យាដកប្រាក់លើកទី៤ + លើកទី៥	២៥០ ចំណុចមូលដ្ឋាន
ការបន្តកិច្ចសន្យាដកប្រាក់លើកទី៦ + លើកទី៧	៣០០ ចំណុចមូលដ្ឋាន

(ខ) ការប្រាក់បង្គរគិតលើបរិមាណរូបិយប័ណ្ណជាដុល្លារអាមេរិកដែលបានទិញ និង នៅមានសុពលភាពក្រោមការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ណាមួយ ត្រូវបានគណនាដោយផ្អែកលើមូលដ្ឋានមួយឆ្នាំស្មើនឹង ៣៦០ថ្ងៃ និងផ្អែកលើចំនួនថ្ងៃពិតប្រាកដ គិតចាប់ពី (និងរាប់បញ្ចូលទាំង) កាលបរិច្ឆេទកំណត់អត្រាការប្រាក់នៃការដកប្រាក់ ឬ ការបន្តកិច្ចសន្យាដកប្រាក់ រហូតដល់ (ប៉ុន្តែមិនរាប់បញ្ចូលនូវ) កាលបរិច្ឆេទឥណប្រតិទាន ឬក្នុងករណីនៃការទិញយកវិញមុនកាលកំណត់ ចំនួនថ្ងៃគឺរាប់ត្រឹមកាលបរិច្ឆេទ នៃការទិញយកវិញមុនកាលកំណត់នោះ។

៧.២.៥ ការទូទាត់នៅឥណប្រតិទាន

(ក) កាលបរិច្ឆេទឥណប្រតិទាននៃការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ណាមួយដែលមិនត្រូវបានស្នើសុំពន្យាពេលៈ (i)ភាគីស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធត្រូវលក់ទៅវិញនូវស្ថានភាពរូបិយប័ណ្ណដុល្លារអាមេរិក ទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណវិញ ជាមួយនឹងចំនួនទឹកប្រាក់បន្ថែមជារូបិយប័ណ្ណដុល្លារអាមេរិក ស្មើនឹងការប្រាក់ ដែលត្រូវបានគណនាលើស្ថានភាពរូបិយប័ណ្ណដុល្លារអាមេរិក តាមអត្រាការប្រាក់ដែលត្រូវបានកំណត់ស្របតាមមាត្រា ៧.២.៤ (ii)ភាគីផ្តល់ការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធ ត្រូវលក់ទៅវិញនូវបរិមាណរូបិយវត្ថុក្នុងស្រុកទៅភាគីស្នើសុំការដោះដូររូបិយប័ណ្ណ (ដោយកែតម្រូវនូវការបន្តកិច្ចសន្យាដកប្រាក់ណាមួយ) ដោយគ្មានការប្រែប្រួលនៃចំនួនទឹកប្រាក់នោះទេ។ ដើម្បីចៀសវាងការមន្ទិល ការលក់វិញនូវបរិមាណរូបិយវត្ថុក្នុងស្រុកនោះ អាចត្រូវបានធ្វើឡើងនៅថ្ងៃធ្វើការបន្ទាប់ ដូចមានចែងក្នុងចំណុច (i) ត្រូវបានបញ្ចប់នៅកាលបរិច្ឆេទឥណប្រតិទានដោយគ្មានការពន្យាពេល។

ការទូទាត់ចំពោះប្រតិបត្តិការដោះដូររូបិយប័ណ្ណនីមួយៗ ត្រូវបានធ្វើឡើង និងទូទាត់ដាច់ដោយឡែកពីគ្នា ដោយគ្មានការកាត់កង ក្នុងលក្ខខណ្ឌដែលថា នៅពេលធ្វើការបន្តកិច្ចសន្យាដកប្រាក់ណាមួយ ចំនួនទឹកប្រាក់នៃបរិមាណរូបិយប័ណ្ណដុល្លារអាមេរិកដែលត្រូវបន្តមិនត្រូវបាន

ទិញយកវិញដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ដូចបានលើកឡើងខាងលើហើយនោះទេ នឹងត្រូវបានចាត់ទុកថាមានការកត់ត្រាខាងឥណទាននៅក្នុងគណនី ក្រោមឈ្មោះរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅថ្ងៃសុពលភាពសម្រាប់ការបន្តកិច្ចសន្យាដកប្រាក់នោះ ស្របតាមមាត្រា៧.២.៧។ បរិមាណរូបិយវត្ថុក្នុងស្រុកដែលត្រូវបន្តទៀតនោះ ត្រូវបានគណនាឡើងវិញដូចមានចែងក្នុងមាត្រា៧.៣.២ (ខ)ហើយបើមានលម្អៀង (ប្រសិនបើវិជ្ជមាន) នោះត្រូវកត់ត្រាខាងឥណទានបន្ថែមទៀត ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធ ឬ(ប្រសិនបើអវិជ្ជមាន) នោះត្រូវផ្តល់ត្រឡប់វិញ ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធ ទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណ។

(ខ) ក្នុងករណីនៃការទិញយកមកវិញនូវរូបិយវត្ថុក្នុងស្រុក នៅឥណប្រតិទាននៃការដកប្រាក់ដែលមិនបានពន្យារពេល តម្លៃនៃការទិញយកវិញត្រូវជារូបិយប័ណ្ណដុល្លារអាមេរិកដើមដែលត្រូវបានទូទាត់ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណ សម្រាប់បរិមាណរូបិយវត្ថុក្នុងស្រុកដែលពាក់ព័ន្ធពោលគឺ បរិមាណរូបិយប័ណ្ណដុល្លារអាមេរិក ដែលត្រូវបានគណនា ដោយផ្អែកលើមូលដ្ឋាននៃអត្រាប្តូរប្រាក់រូបិយវត្ថុក្នុងស្រុកធៀបនឹងដុល្លារអាមេរិកដែលបានអនុវត្ត ដូចមានកំណត់ស្របតាមមាត្រា៧.២.២ (ខ)នៅពេលដែលបរិមាណរូបិយប័ណ្ណដុល្លារអាមេរិកត្រូវបានលក់ដំបូងទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណបូកនឹងការប្រាក់គិតលើរូបិយប័ណ្ណដុល្លារអាមេរិកដែលបានគណនាស្របតាមមាត្រា៧.២.៤។

(គ) ក្នុងករណីនៃការទិញយកវិញនូវរូបិយវត្ថុក្នុងស្រុកនៅឥណប្រតិទាន៖ នៃការបន្តកិច្ចសន្យាដកប្រាក់ តម្លៃនៃការទិញយកវិញត្រូវជារូបិយប័ណ្ណដុល្លារអាមេរិក បានគណនាដោយផ្អែកលើមូលដ្ឋាននៃអត្រាប្តូរប្រាក់ថ្មីនៃរូបិយវត្ថុក្នុងស្រុកធៀបនឹងដុល្លារអាមេរិក ដែលអនុវត្តចំពោះការបន្តកិច្ចសន្យាដកប្រាក់ស្របតាមមាត្រា៧.៣.២(ខ) បូកនឹងការប្រាក់ដែលគិតតាមអត្រាការប្រាក់ថ្មី សម្រាប់ការបន្តកិច្ចសន្យាដកប្រាក់ ដែលកំណត់ស្របតាមមាត្រា៧.២.៤(ខ)។

៧.២.៦ ការប្រាក់បង់យឺត៖ នៅពេលដែលភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ការខកខានក្នុងការទូទាត់ចំពោះប្រតិបត្តិការដោះដូររូបិយប័ណ្ណណាមួយ រួមបញ្ចូលទាំងការទិញយកវិញនៃរូបិយវត្ថុក្នុងស្រុក ដែលពាក់ព័ន្ធចំពោះការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ រួមបញ្ចូលទាំងការទូទាត់នៃចំនួនទឹកប្រាក់បន្ថែមណាមួយស្មើនឹងការប្រាក់ ហើយការខកខានបានបន្តរយៈពេលចំនួន៣ថ្ងៃនៃថ្ងៃធ្វើការ បំណុលដែលមិនបានទូទាត់នោះ (គឺចំនួនទឹកប្រាក់សរុបនៃបំណុលនោះគឺជា "ចំនួនទឹកប្រាក់មិនបានទូទាត់តាមឥណប្រតិទាន") ត្រូវមានការប្រាក់កាន់តែខ្ពស់ (ហៅថា "ការប្រាក់បង់យឺត") ដោយអនុលោមតាមចំណុចដូចខាងក្រោម៖

(ក) ការប្រាក់បង់យឺតសម្រាប់ចំនួនទឹកប្រាក់មិនបានទូទាត់តាមឥណប្រតិទាន ត្រូវបង្គរ ដោយចាប់ផ្ដើមពី(និងរាប់បញ្ចូលទាំង)ថ្ងៃទី៤នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ ដែលបំណុល បានដល់ពេលកំណត់ និងត្រូវទូទាត់សងរហូតដល់កាលបរិច្ឆេទពិតប្រាកដ តែមិនរាប់បញ្ចូល ដែលបំណុលត្រូវបានទូទាត់សង។ ដើម្បីចៀសវាងការមន្ទិល សម្រាប់រយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើ ការ មុនថ្ងៃដែលការបង្គរការប្រាក់បង់យឺតចាប់ផ្ដើមពីកាលបរិច្ឆេទ ដែលបំណុលនេះត្រូវដល់ ពេលទូទាត់សង នោះការប្រាក់ត្រូវបន្តបង្គរលើចំនួនទឹកប្រាក់មិនបានទូទាត់តាមឥណប្រតិទាន តាមអត្រាការប្រាក់ដំបូងដែលអនុវត្តចំពោះបំណុលពាក់ព័ន្ធ នៅក្រោមបទបញ្ញត្តិនៃកិច្ច ព្រមព្រៀង CMIM នេះ។

(ខ) ការប្រាក់បង់យឺតត្រូវបង្គរតាមអត្រាមួយស្មើនឹង ២០០ ចំណុចមូលដ្ឋានលើស អត្រាការប្រាក់ដែលកំណត់ក្នុងមាត្រា៧.២.៤(ក)។ អត្រាការប្រាក់បង់យឺតនេះ នឹងកើនឡើង នៅរៀងរាល់៦ខែម្ដង គិតចាប់ពីកាលបរិច្ឆេទនៃការបង្គរ ដោយកើនម្ដងស្មើនឹង៥០ចំណុច មូលដ្ឋាន រហូតដល់ការទូទាត់សងគ្រប់ចំនួននៃចំនួនទឹកប្រាក់ មិនបានទូទាត់តាមឥណប្រតិទាន ត្រូវបានធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ប៉ុន្តែក្នុងលក្ខខណ្ឌដែលអត្រាការប្រាក់ បង់យឺតត្រូវមិនលើសពី ៥០០ ចំណុចមូលដ្ឋានលើសអត្រា LIBOR ដែលបានប្រើប្រាស់ដើម្បី កំណត់អត្រាការប្រាក់ ដែលអាចអនុវត្តបានចំពោះកាតព្វកិច្ចបំណុល ក្រោមមាត្រា៧.២.៤(ក)។ ការប្រាក់ និងការប្រាក់បង់យឺតត្រូវគណនាជាបែបការប្រាក់បញ្ចូលគ្នារៀងរាល់មួយខែម្ដង គិត ចាប់ពីកាលបរិច្ឆេទនៃការបង្គរ។

៧.២.៧ យន្តការនៃប្រតិបត្តិការដោះដូរ: រវាងភាគីផ្ដល់ការដោះដូររូបិយប័ណ្ណ និង ភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗ (ក) ភាគីផ្ដល់ការដោះដូររូបិយប័ណ្ណ ដែលបានទិញ រូបិយវត្ថុក្នុងស្រុក ត្រូវបានកត់ត្រាខាងឥណទានទៅក្នុងគណនីពិសេសមួយ ដែលមិនមាន ការប្រាក់ ដែលមានឈ្មោះថា "គណនីចរន្តរូបិយវត្ថុក្នុងស្រុក" ឬបើមិនដូច្នេះទេ ដោយមាន ការព្រមព្រៀងគ្នារវាងភាគីផ្ដល់ការដោះដូររូបិយប័ណ្ណ និងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវ កត់ត្រាក្រោមឈ្មោះរបស់ភាគីផ្ដល់ការដោះដូររូបិយប័ណ្ណ នៅក្នុងសៀវភៅរបស់ភាគីស្នើសុំការ ដោះដូររូបិយប័ណ្ណ (ខ)បរិមាណរូបិយប័ណ្ណដុល្លារអាមេរិក ដែលបានទិញដោយភាគីស្នើសុំការ ដោះដូររូបិយប័ណ្ណ ត្រូវបានកត់ត្រាខាងឥណទានទៅក្នុងគណនីទូទៅដែលកាន់កាប់ដោយធនាគារ សហព័ន្ធនៅញូយ៉ក ក្នុងនាមភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ឬគណនីផ្សេងទៀត ដែលភាគី ផ្ដល់ការដោះដូររូបិយប័ណ្ណអាចទទួលយកបាន ដែលត្រូវបានបញ្ជាក់ប្រាប់ដោយភាគីស្នើសុំការ ដោះដូររូបិយប័ណ្ណ នៅពេលស្នើសុំដកប្រាក់ដែលពាក់ព័ន្ធ។ ដើម្បីចៀសវាងការមន្ទិលការចុះ ឥណទាននៃបរិមាណរូបិយវត្ថុក្នុងស្រុកនិងបរិមាណដុល្លារអាមេរិក ត្រូវធ្វើឡើងនៅថ្ងៃសុពលភាព។

៧.៣ ការដកប្រាក់ក្រោមមធ្យោបាយដោះដូររូបិយប័ណ្ណ

៧.៣.១ ការដកប្រាក់: ការទាក់ទងរវាងភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និងភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗ ដែលកំណត់តាមលក្ខខណ្ឌមានពីមុន ដូចបានចែងក្នុងមាត្រា ១០ ត្រូវបានគោរព និងបានបំពេញដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ហើយលក្ខខណ្ឌ និងកាលកំណត់ផ្សេងទៀតនៅក្នុងកិច្ចព្រមព្រៀង CMIM នេះត្រូវបានបំពេញ ការសុំដកប្រាក់តាមមធ្យោបាយនៃការទិញរូបិយប័ណ្ណដុល្លារអាមេរិក ពីភាគីផ្តល់ការដោះដូររូបិយប័ណ្ណពាក់ព័ន្ធ ត្រូវជូនដំណឹងមិនឱ្យលើសពីម៉ោង ៣:០០ រសៀល ម៉ោងនៅប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ នៅថ្ងៃធ្វើការ ដែលយ៉ាងហោចណាស់ត្រូវផ្តល់ដំណឹងឱ្យបានបីថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទកំណត់អត្រាការប្រាក់តាមរយៈប្រព័ន្ធសារយថាភូត SWIFT (ឬក្នុងករណីដែលមធ្យោបាយនៃប្រព័ន្ធ SWIFT ត្រូវបានខូចខាត ឬមិនអាចដំណើរការ នោះប្រព័ន្ធទូរសារដែលបានធ្វើការសាកល្បង ត្រូវបានប្រើដោយយោងតាមលក្ខខណ្ឌដែលព្រមព្រៀងគ្នា រវាងបណ្តាភាគីនានា ដាច់ដោយឡែកពីកិច្ចព្រមព្រៀង CMIM នេះ និងបានទទួលការបញ្ជាក់តាមរយៈការហៅទូរស័ព្ទ ឬសារអេឡិចត្រូនិក នៅពេលដំណាលគ្នា) (មធ្យោបាយនីមួយៗហៅថា **"ទូរគមនាគមន៍យថាភូត"**) ទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណ។

៧.៣.២ ការបន្តកិច្ចសន្យាដកប្រាក់

(ន) ការទាក់ទងរវាងភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និង ភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗ និងតាមលក្ខខណ្ឌមានពីមុនដែលបានកំណត់ក្នុងមាត្រា១០ ត្រូវបានបំពេញ និងគោរពដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ និងដោយគ្រប់នីតិវិធីស្របតាមមាត្រា៥.២ និងមាត្រា៧.១ និងបទបញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ត្រូវបានបំពេញដើម្បីអនុម័តបន្តកិច្ចសន្យាដកប្រាក់ណាមួយ ដែលជាការដកទាំងអស់ ឬដកមួយផ្នែក (**"ការបន្តកិច្ចសន្យាដកប្រាក់"**) នោះការដកប្រាក់នីមួយៗ ដែលធ្វើឡើងដោយមិនមានជាប់ទាក់ទងទៅនឹងចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌរបស់ IMF អាចត្រូវបានពន្យារពេលសម្រាប់ចំនួនទឹកប្រាក់ទាំងអស់ ឬទឹកប្រាក់មួយផ្នែក រហូតដល់ចំនួន៧ដង តាមសំណើរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដោយការជូនដំណឹងអំពីសំណើនោះ ទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និងបណ្តាប្រទេសសម្របសម្រួល មិនឱ្យហួសពីម៉ោង ៣:០០ រសៀល ម៉ោងនៅប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ នៅថ្ងៃធ្វើការ ដែលយ៉ាងហោចណាស់មានរយៈពេលបីថ្ងៃ មុនកាលបរិច្ឆេទឥណប្រតិទាន តាមរយៈប្រព័ន្ធទូរគមនាគមន៍យថាភូត និងក្នុងលក្ខខណ្ឌដែលថា ចំនួនទឹកប្រាក់ដែលស្មើនឹងការប្រាក់បង្គរ លើរូបិយប័ណ្ណដុល្លារអាមេរិកស្របតាមមាត្រា៧.២.៤ ត្រូវបានទូទាត់គ្រប់ចំនួន ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ តាមកាលកំណត់សម្រាប់ការដកប្រាក់

ឬការបន្តកិច្ចសន្យាការដកប្រាក់ដែលនៅមានសុពលភាព។ ដើម្បីចៀសវាងការមន្ទិល រាល់បទបញ្ញត្តិដែលពាក់ព័ន្ធនឹងការដកប្រាក់ លើកលែងតែបទបញ្ញត្តិដែលអនុវត្តចំពោះការដកប្រាក់ជាធម្មតា ដូចជាបទបញ្ញត្តិសម្រាប់អត្រាការប្រាក់ គឺត្រូវអនុវត្តចំពោះការបន្តកិច្ចសន្យាការដកប្រាក់។ ក្នុងការអនុវត្តកថាខ័ណ្ឌ (ខ) នេះ ប្រសិនបើកម្មវិធី IMF ត្រូវបង្កើតឡើងសម្រាប់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ បន្ទាប់ពីការដកប្រាក់ ឬការបន្តកិច្ចសន្យាការដកប្រាក់នៃចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌ IMF នោះ ចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌ IMF ត្រូវបានចាត់ទុកថា ចំនួនទឹកប្រាក់នេះ មិនមែនជា ចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌ IMF ទេ (ហើយដោយអនុលោមតាមមាត្រា១០.៣ ត្រូវអនុវត្ត) និងការបន្តកិច្ចសន្យាដកប្រាក់ ត្រូវធ្វើឡើងយ៉ាងច្រើនចំនួន ០៧ ដង។

(ង) នៅពេលដែលការបន្តកិច្ចសន្យាដកប្រាក់ត្រូវបានធ្វើឡើង ដោយយោងតាមកថាខ័ណ្ឌ(ខ)ខាងលើទាក់ទងនឹងរូបិយវត្ថុក្នុងស្រុកត្រូវបានគណនាឡើងវិញ ដោយផ្អែកលើអត្រាប្តូរប្រាក់ថ្មី ដែលបានកំណត់ស្របតាមតារាងកម្មវិធីទី៤ និងត្រូវបានកែសម្រួលយោងតាមមាត្រា៧.២.៥(ខ) ហើយអត្រាការប្រាក់ថ្មីដែលត្រូវអនុវត្តចំពោះរូបិយប័ណ្ណដុល្លារអាមេរិកក្រោមការបន្តកិច្ចសន្យាដកប្រាក់នោះ ត្រូវបានគណនា ដោយយោងតាមមាត្រា៧.២.៤(ខ)។

(ច) ក្នុងករណីការដកប្រាក់ណាមួយ បានធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ទាក់ទងទៅនឹងចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌ IMF នោះ ការបន្តកិច្ចសន្យាដកប្រាក់អាចធ្វើបានតែម្តងគត់ ប៉ុន្តែមានលក្ខខណ្ឌ ប្រសិនបើពិចារណាឃើញថាមានការចាំបាច់ និងត្រឹមត្រូវ និងជាកម្មវត្ថុនៃការអនុម័តដោយ ELDMB នៅក្នុងករណីនីមួយៗ នោះការបន្តកិច្ចសន្យាដកប្រាក់ អាចធ្វើបានចំនួនបីដងជាប់ៗគ្នា។

៧.៣.៣ ការទិញមកវិញមុនកាលបរិច្ឆេទឥណប្រតិទានៈ រវាងភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និង ភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗ។ ភាគីស្នើសុំការដោះដូររូបិយប័ណ្ណមានសិទ្ធិគ្រប់ពេលទាំងអស់ក្នុងការទិញត្រឡប់មកវិញមុនកាលបរិច្ឆេទឥណប្រតិទាន ដោយត្រូវជូនដំណឹងជាមុនក្នុងរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណ តាមមធ្យោបាយទូរគមនាគមន៍យថាភូត។ ការទិញមកវិញនូវរូបិយវត្ថុក្នុងស្រុកទាំងអស់ ឬមួយផ្នែកមុនកាលបរិច្ឆេទឥណប្រតិទាន ដែលបានរក្សាទុកដោយភាគីផ្តល់ការដោះដូរ គឺពុំត្រូវបានធ្វើការពិន័យអ្វីទាំងអស់ (ហៅថា **"ការទិញមកវិញមុនឥណប្រតិទាន"**)។ ប្រសិនបើការទិញយកមកវិញមុនឥណប្រតិទានណាមួយ ត្រូវបានធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នោះការទិញយកវិញមុនឥណប្រតិទាននេះ នឹងត្រូវធ្វើចំពោះគ្រប់ភាគីផ្តល់ការដោះដូរទាំងអស់ស្មើៗគ្នា ដោយផ្អែកលើមូលដ្ឋានសមាមាត្រទៅតាមទំហំរូបិយប័ណ្ណដុល្លារអាមេរិកនៅសុពល

ភាពរបស់ភាគីផ្តល់ការដោះដូររូបិយប័ណ្ណនីមួយៗ។ រាល់ការទិញយកវិញមុនឥណប្រតិទានត្រូវធ្វើឡើងជាមួយគ្នានឹងចំនួនការប្រាក់បង្គរ គិតដល់កាលបរិច្ឆេទនៃការទិញយកវិញមុនឥណប្រតិទាននេះ ហើយការជូនដំណឹងដែលផ្តល់ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ស្របតាមការលើកឡើងខាងលើ ត្រូវមានបញ្ជាក់ពីការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ជាក់លាក់ដែលទាក់ទងទៅនឹងការទិញយកវិញមុនឥណប្រតិទាន និង ចំនួនដែលត្រូវទិញ។ បទបញ្ញត្តិពាក់ព័ន្ធនៃមាត្រា៧.២.៤ ៧.២.៥ និង ៧.២.៦ ត្រូវអនុវត្តដូចដែលបានកែប្រែលើការទិញយកវិញមុនឥណប្រតិទានណាមួយ ដែលមានចែងក្នុងពេលនេះលើការទិញយកវិញមុនឥណ-ប្រតិទាន នៅក្រោមមាត្រា៧.៣.៣។ អត្រាការប្រាក់ដែលពាក់ព័ន្ធនឹងការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ដែលត្រូវទិញយកវិញនោះ ត្រូវធ្វើការកែតម្រូវ ដោយប្រើប្រាស់អត្រាការប្រាក់ទាបជាងពេលអនុវត្តពីដំបូង និង អត្រាតាមទីផ្សារ (ដូចកំណត់ខាងក្រោម) នៅត្រង់ពេលនៃការទិញយកវិញមុនឥណប្រតិទាន។

"អត្រាតាមទីផ្សារ" សំដៅដល់អត្រា LIBOR នៅពេលបិទទីផ្សារ សម្រាប់ប្រាក់បញ្ញើដុល្លារអាមេរិកនៅអំឡុងពេលជាក់លាក់មួយ ដែលបានផ្សព្វផ្សាយដោយសមាគមធនាគារិកចក្រភពអង់គ្លេស នៅម៉ោង១១:០០ព្រឹក ម៉ោងនៅទីក្រុងឡុងដ៍ ឬក្នុងករណីដែលមិនមានអត្រាការប្រាក់បែបនេះ នោះគឺជាការធ្វើអាំងទែប៉ូឡាស្យុងលីនេអ៊ែ រវាងអត្រាLIBORពីរ ដែលមានរយៈពេលជិតបំផុត សម្រាប់ប្រាក់បញ្ញើដុល្លារអាមេរិក ក្នុងកំឡុងពេលពីរថ្ងៃនៃថ្ងៃធ្វើការនៅទីក្រុងឡុងដ៍ មុនកាលបរិច្ឆេទកំណត់នៃការទិញយកវិញមុនឥណប្រតិទាននេះ។

៧.៣.៤ ការទូទាត់ពន្ធ: គ្រប់ការទូទាត់ដែលធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណនៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ត្រូវធ្វើឡើងដោយគ្មានការកាត់ទុក ឬការដកចេញនូវពន្ធអាករ ឬកម្រៃផ្សេងៗរបស់រដ្ឋាភិបាល សម្រាប់ពេលបច្ចុប្បន្ន ឬពេលអនាគតដែលកំណត់យកដោយ ឬក្នុងនាមប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ អាជ្ញាធរដែលពាក់ព័ន្ធពុំមានអំណាចយកពន្ធឡើយ។ ក្នុងករណីដែលការកាត់ទុក ឬដកចេញនូវពន្ធអាករ ឬកម្រៃផ្សេងៗរបស់រដ្ឋ ត្រូវបានកំណត់ដោយច្បាប់ នោះភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវទូទាត់បន្ថែមនូវចំនួនទឹកប្រាក់ដែលចាំបាច់ ដើម្បីបង្គ្រប់ចំនួនទឹកប្រាក់ដែលត្រូវទទួលដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ដែលកំណត់ថា គ្មានការកាត់ទុក ឬការដកចេញនូវពន្ធអ្វីឡើយ។

មាត្រា៨ .. ការដកខ្លួនចេញពីការចូលរួមក្នុងយន្តការ CMIM

៨.១ វិធានទូទៅលើការដកខ្លួនចេញ - ការអនុម័តរបស់ ELDMB

ជាគោលការណ៍ ពេលប្រតិបត្តិតាមកិច្ចព្រមព្រៀង CMIM នេះ ភាគី CMIM នីមួយៗ ក្លាយជាសមាជិក និងជាអ្នកចូលរួមនៃយន្តការ CMIM ដែលបង្កើតឡើងនេះ និង អាចដកខ្លួនចេញពីការចូលរួមចំពោះសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់ ដោយៈ (a) ដាក់លិខិតពីការដកខ្លួនចេញដោយបង្ហាញ និងពន្យល់អំពីមូលហេតុនៃការដកខ្លួន ភ្ជាប់ជាមួយនូវឯកសារ និងភស្តុតាងគាំទ្រគ្រប់គ្រាន់ ទៅឱ្យគ្រប់សមាជិកផ្សេងទៀតទាំងអស់នៃ ELDMB នៅត្រឹមពេលបោះឆ្នោតសម្រាប់សំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ និង(b) ទទួលបានការអនុម័តនៃ ELDMB ចំពោះសំណើសុំដកខ្លួនពីការទទួលខុសត្រូវក្នុងការផ្ដល់ការគាំទ្រ ក្នុងនាមជាភាគីផ្ដល់ការដោះដូររូបិយប័ណ្ណ ឆ្លើយតបនឹងសំណើសុំដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ។

៨.២ ការដកខ្លួនចេញក្រោមកាលៈទេសៈពិសេស

ភាគី CMIM នីមួយៗ អាចដកខ្លួនចេញពីការទទួលខុសត្រូវក្នុងការចូលរួមផ្ដល់ការគាំទ្រក្នុងនាមជាភាគីផ្ដល់ការដោះដូររូបិយប័ណ្ណ ទៅនឹងសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់មួយបាន នៅពេលដែលដាក់លិខិតដកខ្លួនចេញ ទៅឱ្យគ្រប់សមាជិកផ្សេងទៀតនៃ ELDMB ដែលជាសេចក្ដីថ្លែងពន្យល់ ភ្ជាប់ជាមួយនឹងឯកសារគាំទ្រគ្រប់គ្រាន់ និងភស្តុតាងពីកាលៈទេសៈពាក់ព័ន្ធ នៅត្រឹមពេលបោះឆ្នោតសម្រាប់សំណើសុំកិច្ចព្រមព្រៀងដោះដូររូបិយប័ណ្ណជាក់លាក់ណាមួយ ដោយមិនចាំបាច់មានការអនុម័តពី ELDMB ក្នុងកាលៈទេសៈដូចខាងក្រោម :

(a) ភាគី CMIM ដែលមានបំណងដកខ្លួនពីការចូលរួម កំពុងជួបប្រទះការលំបាកជាច្រើនក្នុងការរក្សាជញ្ជីងទូទាត់ប្រកបដោយចីរភាព និង/ឬ មានសភាពតានតឹងចំពោះស្ថានភាពទុនបំរុងរបស់ខ្លួន

(b) មិនមានវិធានការណ៍សុវត្ថិភាពគ្រប់គ្រាន់ទាក់ទងទៅនឹង ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ឬមានវិធានការសុវត្ថិភាពគ្រប់គ្រាន់ប៉ុន្តែមិនអាចធ្វើឱ្យមានចីរភាព ឬមិនអាចអនុវត្តឱ្យបានសមស្របទាក់ទងទៅនឹងភាគីស្នើសុំការដោះដូររូបិយប័ណ្ណនោះ

(c) ព្រឹត្តិការណ៍វិសាមញ្ញ ឬការកើតឡើងនៃករណីប្រធានសក្ដិភាមៗ ដូចជា សង្គ្រាម សភាពប្រហាក់ប្រហែលសង្គ្រាម ឬគ្រោះមហន្តរាយធម្មជាតិ ដែលហួសពីការត្រួតត្រារបស់ភាគី CMIM ដែលដកខ្លួន និងមានឥទ្ធិពលរារាំងដល់ភាគី CMIM ដែលដកខ្លួន មិនឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនបាននៅក្រោមកិច្ចព្រមព្រៀង CMIM និងយន្តការ CMIM នេះ និង/ឬ

(d) ភាគី CMIM ដែលដកខ្លួន ប្រឈមមុខនឹងកំហិតព្រំដែនផ្លូវច្បាប់ក្នុងស្រុក ដែលរារាំង ភាគី CMIM ដែលដកខ្លួន មិនឱ្យផ្ដល់រូបិយប័ណ្ណដុល្លារអាមេរិក ទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណ។

៨.៣ ពេលវេលានៃការដកខ្លួន

រាល់ការដកខ្លួនដែលធ្វើឡើងស្របតាមមាត្រា៨នេះ ត្រូវតែធ្វើឡើងយ៉ាងយូរនៅត្រឹមពេលបោះឆ្នោតដោយ ELDMB ទាក់ទងនឹងសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់មួយ ដែលធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណមួយ ដើម្បីឱ្យភាគី CMIM ដែលដកខ្លួនត្រូវបានអនុញ្ញាតឱ្យរួចផុតពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការចូលរួមជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ទាក់ទងនឹងសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់នោះ។

៨.៤ វិបាកនៃការដកខ្លួន

(ឥ) យោងតាមបទបញ្ញត្តិនៃមាត្រា៨នេះ ប្រសិនបើភាគី CMIM មួយ បានដកខ្លួនពីការចូលរួមនឹងសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់មួយ នោះភាគី CMIM ដែលដកខ្លួនគ្មានសិទ្ធិបោះឆ្នោតពាក់ព័ន្ធនឹងបញ្ហាកម្រិតប្រតិបត្តិ ដែលត្រូវសម្រេចដោយ ELDMB ទាក់ទងនឹងប្រតិបត្តិការដោះដូរជាក់លាក់នោះ ដោយហេតុថា ភាគី CMIM ដកខ្លួននឹងមិនចូលរួមជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណទេ។

(ខ) ក្នុងករណីដែលមានភាគី CMIM ណាមួយបានដកខ្លួន លើសំណើសុំការដោះដូររូបិយប័ណ្ណជាក់លាក់មួយ នោះចំនួនទឹកប្រាក់ដែលត្រូវបានធ្វើវិភាជន៍ទៅឱ្យភាគី CMIM ដកខ្លួននោះ ត្រូវបានរួមចំណែកផ្តល់ដោយភាគី CMIM ដែលនៅសល់ ក្នុងនាមជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ដោយផ្អែកលើមូលដ្ឋានសមាមាត្រ ដែលត្រូវកំណត់ដោយអនុលោមតាមទំហំវិភាគទាន CMIM របស់ភាគីដែលនៅសល់នីមួយៗនោះ ក៏ប៉ុន្តែទោះក្នុងករណីណាក៏ដោយ គ្មានភាគី CMIM ណាមួយ ត្រូវបានតម្រូវឱ្យរួមវិភាគទានលើសពីចំនួនវិភាគទាន CMIM សរុបរបស់ភាគី CMIM នីមួយៗ ដូចបានបញ្ជាក់ក្នុងតារាងកម្មវិធីទី១ឡើយ។

<u>**មាត្រា៩ .- ការធានា និង តំណាង**</u>

ភាគី CMIM នីមួយៗ ធានា និងតំណាងឱ្យភាគី CMIM ផ្សេងទៀត ដូចខាងក្រោម: មានប្រសិទ្ធិភាពនៅថ្ងៃដែលបានកំណត់ចូលជាធរមាន និង ភាគីស្នើសុំការដោះដូររូបិយប័ណ្ណនីមួយៗយល់ព្រមថា ខ្លួនត្រូវបានគេចាត់ទុកជាតំណាង និង បានផ្តល់ការធានាចំពោះភាគី CMIM ផ្សេងទៀត រាល់ពេលនៃការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ ត្រូវបានធ្វើឡើងយោងតាមសំណើសុំការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹងខ្លួនឯង និងប្រទេស/តំបន់ស្នើសុំការដោះដូរ:

៩.១ ខ្លួនមានសិទ្ធិអំណាចពេញលេញក្នុងការចុះកិច្ចសន្យា និងអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀង CMIM នេះ និងចាត់រាល់វិធានការ ដើម្បីអនុញ្ញាតឱ្យអនុវត្តប្រតិបត្តិការដោះដូររូបិយប័ណ្ណ ដែលត្រូវអនុវត្តស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ និង

៩.២ កិច្ចព្រមព្រៀង CMIM នេះ និងការអនុវត្តភាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងនេះ មិនបំពានច្បាប់ ឬការដាក់កំហិតណាមួយឡើយ និងគ្មានការបង្អាក់ផ្នែកច្បាប់ និងបទបញ្ញត្តិដែលអាចមានប៉ះពាល់ដល់នីត្យានុកូលភាព សុពលភាព និងភាពអាចប្រតិបត្តិបាននៃកិច្ចព្រមព្រៀង CMIM នេះ ឬកាតព្វកិច្ចនៃភាគី CMIM ឬមានផលប៉ះពាល់អាក្រក់ទៅលើការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

មាត្រា១០.- លក្ខខណ្ឌដែលមានកន្លងមក

១០.១ លក្ខខណ្ឌដែលមានកន្លងមកសម្រាប់ការដកប្រាក់ ឬការបន្តកិច្ចសន្យាការដកប្រាក់

ជាលក្ខខណ្ឌមានពីមុន ចំពោះភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដែលត្រូវបានផ្តល់សិទ្ធិចំពោះការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ណាមួយ ស្របតាមកិច្ចព្រមព្រៀង CMIM នេះ លក្ខខណ្ឌដែលកំណត់ក្នុងមាត្រា១០.១ ត្រូវបានបំពេញនៅត្រឹមពេលបោះឆ្នោតនៃ ELDMB និងនៅត្រឹមកាលបរិច្ឆេទកំណត់អត្រាការប្រាក់ប៉ុណ្ណោះ។

១០.១.១ ការបានទទួលលិខិតមកពីរដ្ឋាភិបាលពាក់ព័ន្ធ: ភាគី CMIM នីមួយៗ ដែលត្រូវបានរំពឹងទុកថាជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ បានទទួលលិខិតមកពីតំណាងរដ្ឋាភិបាលពាក់ព័ន្ធនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ តាមរយៈបណ្តាប្រទេសសម្របសម្រួលដែលលិខិតនោះមានទម្រង់ និងមាតិកាដូចបានកំណត់ក្នុងតារាងកម្មវិធីទី៥ ដោយមានការសម្របសម្រួលជាមួយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដែលបញ្ជាក់ពីការថាក់វិធានចាំបាច់ និងត្រឹមត្រូវ ដើម្បីឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណ អាចអនុវត្តតាមកាតព្វកិច្ចរូបិយវត្ថុដែលនៅមានសុពលភាពរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀង CMIM ។

១០.១.២ បានទទួលលិខិតសន្យាមកពីរដ្ឋាភិបាលពាក់ព័ន្ធ: ភាគី CMIM នីមួយៗ ត្រូវបានរំពឹងថាជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ បានទទួលលិខិតសន្យាមកពីតំណាងរដ្ឋាភិបាលពាក់ព័ន្ធ តាមរយៈបណ្តាប្រទេសសម្របសម្រួល ដែលលិខិតនោះមានទម្រង់ និង មាតិកាដូចបានកំណត់ក្នុងតារាងកម្មវិធីទី៦ និង ធ្វើការសន្យាដូចខាងក្រោម :

(ក) ដរាបណាកាតព្វកិច្ចរូបិយវត្ថុរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នៅមានសុពលភាព រដ្ឋាភិបាលនឹងមិនដាក់ការត្រួតពិនិត្យលើលំហូរចេញនៃដើមទុន ដែលអាចធ្វើឱ្យមានការរាំងស្ទះចំពោះ ការអនុវត្តកាតព្វកិច្ចរូបិយវត្ថុណាមួយ នៅក្រោមកិច្ចព្រមព្រៀង CMIM ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ លើកលែងតែបានផ្តល់ក្នុងកម្មវិធីដែលត្រូវបានយល់ព្រមរវាងរដ្ឋាភិបាល និង IMF

(ខ) ដរាបណាដែលកិច្ចព្រមព្រៀង CMIM នៅជាធរមាន រដ្ឋាភិបាលត្រូវអនុវត្តតាមកម្មវិធី IMF ប្រសិនបើកម្មវិធី IMF នោះនៅមានអត្ថិភាព និង

(c) ដរាបណាកិច្ចព្រមព្រៀង CMIM នៅជាធរមាន រដ្ឋាភិបាលត្រូវចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ពីគោលនយោបាយ និងការពិនិត្យឡើងវិញនៃសេដ្ឋកិច្ចអាស៊ានបូកបី។

១០.១.៣ ការផ្តល់មតិផ្នែកច្បាប់: ភាគី CMIM នីមួយៗ ដែលត្រូវបានរំពឹងទុកថាជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ បានទទួលមតិពីផ្នែកច្បាប់យ៉ាងពេញចិត្តតាមរយៈបណ្តាប្រទេសសម្របសម្រួល មកពីក្រសួងឬភ្នាក់ងាររដ្ឋាភិបាលនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ដែលលិខិតនោះមានទម្រង់ និងមាតិកាដូចបានកំណត់ក្នុងតារាងកម្មវិធីទី៧ (ជាមួយការកែប្រែយកលំនាំតាមគុណសម្បត្តិគ្រប់គ្រាន់ និង/ឬ ការលើកលែងក្នុងការពិចារណាលើកាលៈទេសៈនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ក្នុងគ្រប់ករណី គឺកម្មវត្ថុនៃការទទួលយល់ព្រមពីភាគីផ្តល់ការដោះដូររូបិយប័ណ្ណ) ជាមួយនឹងការគោរពទៅនឹងនីត្យានុកូលភាព សុពលភាពតាមអំណាចនៃច្បាប់ និងការប្រតិបត្តិនៃបទបញ្ញត្តិរបស់កិច្ចព្រមព្រៀង CMIM ដែលពាក់ព័ន្ធនឹងប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណ។

១០.១.៤ ការដាក់របាយការណ៍វិសាមញ្ញស្តីពីមូលហេតុ និងប្រវត្តិនៃព្រឹត្តិការណ៍ពាក់-ព័ន្ធដែលត្រូវបានស្នើសុំឱ្យមានការគាំទ្រ: តាមរយៈបណ្តាប្រទេសសម្របសម្រួល ភាគី CMIM នីមួយៗ ដែលរំពឹងថាជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ បានទទួលរបាយការណ៍វិសាមញ្ញពីភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដែលមាតិកានៃរបាយការណ៍នោះ យ៉ាងហោចណាស់ ត្រូវមានដូចខាងក្រោម:

(a) ការពន្យល់ និងទិន្នន័យស្ថិតិពាក់ព័ន្ធទៅនឹងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន

(b) ការពន្យល់ និងទិន្នន័យស្ថិតិពាក់ព័ន្ធនៃមូលហេតុ និងប្រវត្តិនៃកាលៈទេសៈពាក់ព័ន្ធ (ដូចមាននៅក្នុងចំណុច(i)នៃមាត្រា១ខាងលើ) ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណកំពុងជួបប្រទះ

(c) ការពន្យល់ (រាប់បញ្ចូលទាំងទិន្នន័យស្ថិតិពាក់ព័ន្ធ និងពត៌មានពីការព្យាករណ៍ និងទិសដៅទៅមុខ) នៃផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ក្នុងការដោះស្រាយស្ថានភាពនេះ

(d) ការពន្យល់ (រាប់បញ្ចូលទាំងទិន្នន័យស្ថិតិពាក់ព័ន្ធ) នៃលទ្ធភាពកំណើនសេដ្ឋកិច្ចរយៈពេលខ្លី

(e) ការពន្យល់ (រាប់បញ្ចូលទិន្នន័យស្ថិតិ ឬតួលេខពាក់ព័ន្ធ) នៃទុនបំរុងអន្តរជាតិ និងស្ថានភាពសាច់ប្រាក់បរទេស និង

(f) ការពន្យល់ (រាប់បញ្ចូលទិន្នន័យស្ថិតិ ឬតួរលេខពាក់ព័ន្ធ) នៃបំណុលបរទេសរយៈពេលវែង/ខ្លី។

១០.១.៥ បានពិនិត្យឡើងវិញលើស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធ: ភាគី CMIM នីមួយៗដែលត្រូវបានរំពឹងទុកថាជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ត្រូវតែពិនិត្យទៅតាមជំហានៗមុននៃការបោះឆ្នោត ដូចដែលបានកំណត់ក្នុងបទបញ្ញត្តិនៃមាត្រា៩.២.២ បានធ្វើការពិនិត្យឡើងវិញចប់សព្វគ្រប់ចំពោះស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ដោយផ្អែកលើ:

(a) គ្រប់ពត៌មាន និងទិន្នន័យ ដែលត្រូវផ្តល់ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ

(b) ការធ្វើវិភាគដោយភាគីទី៣ (ដូចជាអង្គភាពដំណើរការឃ្លាំមើល (នៅពេលត្រូវបានបង្កើតឡើងតាមមាត្រា១៨) ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ ឬស្ថាប័នមានសមត្ថកិច្ចស្រដៀងគ្នា) ពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ប្រសិនបើចាំបាច់និងអាចរកបាន និង

(c) តាមវិសាលភាពនៃច្បាប់ដែលបានអនុញ្ញាត ដល់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ពត៌មានផ្សេងៗដែលភាគីផ្តល់ការដោះដូររូបិយប័ណ្ណ អាចតម្រូវដោយមានហេតុផលត្រឹមត្រូវ អំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ។

១០.១.៦ គ្មានព្រឹត្តិការណ៍ខកខាន: គ្មានព្រឹត្តិការណ៍ខកខានណាមួយកើតឡើង ឬកំពុងបន្ត ឬបណ្តាលមកការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ណាមួយទេ។ ដើម្បីចៀសវាងការមន្ទិល លក្ខខណ្ឌមានពីមុននេះ ត្រូវអនុវត្តចំពោះការខកខានណាមួយ ដើម្បីរក្សាការធានា និងការជំនួស ក្នុងមាត្រា៩ ដែលក្លាយជាការពិត និងត្រឹមត្រូវ ឬស្របតាមការព្រមព្រៀង ក្នុងមាត្រា១១ ដែលកើតឡើងមុនការដកប្រាក់ ឬ ការបន្តកិច្ចសន្យាដកប្រាក់ពាក់ព័ន្ធ រាប់បញ្ចូលទាំងការចូលរួមក្នុងកិច្ចប្រជុំណាមួយ ឬទាំងអស់នៃការពិគ្រោះយោបល់លើគោលនយោបាយ និងការពិនិត្យឡើងវិញនៃសេដ្ឋកិច្ចអាស៊ានបូកបី ដែលធ្វើឡើងមុនការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ពាក់ព័ន្ធ។

១០.១.៧ គ្មានដាក់ការត្រួតពិនិត្យលើលំហូរចេញនៃដើមទុន ពាក់ព័ន្ធនឹងការអនុវត្តនៃកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀង CMIM: ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ មិនត្រូវដាក់ការត្រួតពិនិត្យណាមួយលើលំហូរចេញនៃដើមទុន ដែលអាចមានផលមិនល្អដល់ការអនុវត្តកាតព្វកិច្ចរូបិយវត្ថុនៅក្រោមកិច្ចព្រមព្រៀង CMIM នេះ លើកលែងតែបានផ្តល់នៅក្នុងកម្មវិធីណាមួយ ដែលព្រមព្រៀងរវាងភាគី CMIM ពាក់ព័ន្ធ និង IMF។

១០.១.៨ **រក្សាការបើកចំហរទុន:** ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណ បានពិនិត្យ និងបានចាត់វិធានការសមរម្យ ដើម្បីអាចមានលទ្ធភាពប្រើប្រាស់ហិរញ្ញប្បទានទីផ្សារឯកជន និង បានរក្សាកម្រិតហិរញ្ញប្បទានដែលកំពុងមានឱ្យបានសមស្រប។

១០.១.៩ ការបង្ហាញភស្តុតាងដែលបំពេញគ្រប់លក្ខខណ្ឌទាំងអស់: ភាគីCMIM នីមួយៗ ដែលរំពឹងថាមានសន្ទឹកឆ្នោតមានប្រសិទ្ធិភាព តាមរយៈបណ្តាប្រទេសសម្របសម្រួលបានទទួលគ្រប់ឯកសារ និងភស្តុតាងដែលពួកគេបានស្នើសុំ ដើម្បីបញ្ជាក់ថាគ្រប់លក្ខខណ្ឌដែលត្រូវអនុវត្តដូចបានកំណត់ក្នុងមាត្រា១០ ត្រូវបានបំពេញ។

១០.២ លក្ខខណ្ឌមានពីមុនបន្ថែមទៀតដែលត្រូវអនុវត្តសម្រាប់តែចំនួនទឹកប្រាក់ ដែលមិនភ្ជាប់នឹងលក្ខខណ្ឌរបស់ IMF

ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវអនុវត្តលក្ខខណ្ឌមានពីមុន សំរាប់ចំនួនទឹកប្រាក់ដែលមិនភ្ជាប់ទៅនឹងលក្ខខណ្ឌរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ បានចាត់វិធានការដើមានសង្គតិភាព និងបានអនុវត្តវិធានការសេដ្ឋកិច្ចរឹងមាំ ដើម្បីទប់ទល់នឹងសម្ពាធធ្លាក់ចុះខុសប្រក្រតីនៃទុនបំរុងអន្តរជាតិរបស់ខ្លួន។

១០.៣ លក្ខខណ្ឌមានពីមុនបន្ថែមទៀត (មិនអាចអនុវត្តចំពោះចំនួនទឹកប្រាក់ ដែលមិនភ្ជាប់នឹងលក្ខខណ្ឌរបស់ IMF)

លក្ខខណ្ឌមានពីមុនបន្ថែមទៀត (ប៉ុន្តែមិនអនុវត្តចំពោះចំនួនទឹកប្រាក់ដែលមិនភ្ជាប់នឹងលក្ខខណ្ឌ IMF) លក្ខខណ្ឌមានពីមុន ដែលបានកំណត់ខាងក្រោមក្នុងមាត្រា ១០.៣ ត្រូវបានទទួលយក។

១០.៣.១ កំពុងមានកម្មវិធី IMF

កម្មវិធី IMF :

(ក) មានរួចហើយ និងកំពុងដំណើរការតាមផែនការ ឬ

(ខ) តាមការវិនិច្ឆ័យរបស់ ELDMB នឹងត្រូវបង្កើតកម្មវិធី IMF នាពេលអនាគតដ៏ខ្លី ទោះយ៉ាងណាក៏ដោយ ប្រសិនបើកម្មវិធី IMF មិនត្រូវបានបង្កើតឡើងក្នុងអំឡុងពេលសមស្របមួយ ដូចការវិនិច្ឆ័យដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណនីមួយៗ នោះភាគីផ្តល់ការដោះដូររូបិយប័ណ្ណនីមួយៗ មានសិទ្ធិជំទាស់នឹងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដើម្បីតម្រូវឱ្យមានការទិញយកវិញមុនកាលប្រតិទាន នៃរូបិយប័ណ្ណដុល្លារអាមេរិក ដែលបានទិញពីភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ បន្ទាប់ពីការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ដែលពាក់ព័ន្ធ។

១០.៣.២ សង្គតភាពជាមួយកម្មវិធី IMF: ការផតប្រាក់ ឬការបន្តពេលនៃការផត ប្រាក់ពាក់ព័ន្ធ មានសង្គតភាពជាមួយកម្មវិធី IMF ដែលកំពុងមាន ឬត្រូវបានរំពឹងថានឹងត្រូវ បង្កើតឡើង ដូចមានចែងក្នុងមាត្រា១០.៣.១។

១០.៣.៣ ការពិនិត្យឡើងវិញនៃកម្មវិធី IMF: ELDMB បានពិនិត្យឡើងវិញចប់សព្វ គ្រប់ចំពោះសេចក្តីលម្អិតនៃកម្មវិធី IMF ដែលពាក់ព័ន្ធ ដោយផ្អែកលើការពន្យល់ ផ្តល់ដោយ ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និងយោងទៅលើពត៌មានដែលទទួលបានពី IMF។

១០.៤ ការលើកលែងនៃលក្ខខណ្ឌដែលមានពីមុន

បណ្តាប្រទេសសម្របសម្រួល តាមរយៈការសម្រេចនៃ ELDMB អាចធ្វើការលើកលែង លក្ខខណ្ឌដែលមានពីមុនមួយ ឬច្រើន ដោយធ្វើលិខិតជាលាយល័ក្សអក្សរ ដូចមានចែងក្នុង មាត្រា១០ ដោយមាន ឬគ្មានការតម្រូវឱ្យប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ បំពេញ លក្ខខណ្ឌបន្ថែម ហើយការលើកលែងនេះត្រូវមានប្រសិទ្ធិភាព លើគ្រប់បណ្តាភាគី CMIM ទាំងអស់។

<u>មាត្រា១១ .. លក្ខខណ្ឌដែលត្រូវគោរពតាម</u>

នៅពេលដែលកិច្ចព្រមព្រៀង CMIM នៅជាធរមាន ភាគី CMIM នីមួយៗ ត្រូវគោរព និងបំពេលតាមលក្ខខណ្ឌ ដូចខាងក្រោមៈ

១១.១ ការដាក់របាយការណ៍ឃ្លាំមើលតាមកាលកំណត់

អ្នកចូលរួម CMI នីមួយៗ ត្រូវផ្តល់ឱ្យបណ្តាប្រទេសសម្របសម្រួលនូវរបាយការណ៍ ត្រឹមត្រូវ សម្រាប់កិច្ចពិគ្រោះយោបល់ពីគោលនយោបាយ និង ការពិនិត្យឡើងវិញនៃសេដ្ឋកិច្ច អាស៊ានបូកបី ដល់អ្នកចូលរួម CMI ដូចគ្នា។ ដើម្បីចៀសវាងការមន្ទិល របាយការណ៍ដែល ត្រូវដាក់ដោយប្រទេសចិន មិនត្រូវបញ្ចូលបញ្ហាដែលពាក់ព័ន្ធនឹងហុងកុងប្រទេសចិនទេ ហើយ ក្នុងករណីរបាយការណ៍របស់ហុងកុងប្រទេសចិនវិញ ដោយសារតែមិនមែនជាសមាជិកនៃកិច្ច ពិគ្រោះយោបល់អំពីគោលនយោបាយ និងការពិនិត្យឡើងវិញនៃសេដ្ឋកិច្ចអាស៊ានបូកបីនោះ របាយការណ៍ដែលបានលើកឡើងខាងលើនេះ ត្រូវដាក់ដោយហុងកុងប្រទេសចិនខ្លួនឯងទៅឱ្យ អ្នកចូលរួម CMI តាមរយៈបណ្តាប្រទេសសម្របសម្រួល។

១១.២ ការចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពីគោលនយោបាយ និងការពិនិត្យឡើង វិញនៃសេដ្ឋកិច្ច

អ្នកចូលរួម CMI នីមួយៗ ត្រូវចូលរួមក្នុងកិច្ចពិគ្រោះយោបល់ពីគោលនយោបាយ និង ការពិនិត្យឡើងវិញនៃសេដ្ឋកិច្ចអាស៊ានបូកបី។ ដើម្បីចៀសវាងការមន្ទិល ហុងកុងប្រទេសចិន ត្រូវបានតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវនេះបន្ថែមលើការអនុវត្តតាម ដោយប្រទេសចិន។

១១.៣ ការបំពេញតាមកម្មវិធី IMF ដែលកំពុងអនុវត្ត

អ្នកចូលរួម CMI នីមួយៗ ត្រូវបំពេញ និងអនុវត្តតាមកម្មវិធី IMF នោះ ប្រសិនបើអ្នកចូលរួម CMI នោះមានកម្មវិធី IMF កំពុងដំណើរការ។ ដើម្បីចៀសវាងការមន្ទិល លក្ខខណ្ឌតម្រូវនេះ មិនអនុវត្តចំពោះហុងកុងប្រទេសចិនទេ។ ហុងកុងប្រទេសចិនមិនមែនជាសមាជិករបស់ IMF ទេ ហើយការគាំទ្រដែលផ្តល់ចំពោះហុងកុងប្រទេសចិន ស្របតាមកិច្ចព្រមព្រៀង CMIM នេះ មានកម្រិតត្រឹមចំនួនទឹកប្រាក់ដែលមិនភ្ជាប់នឹងលក្ខខណ្ឌរបស់ IMF ប៉ុណ្ណោះ ដែលអាចអនុវត្តបានចំពោះហុងកុងប្រទេសចិន ដូចបានចែងក្នុងមាត្រា៦.៣។

១១.៤ លក្ខខណ្ឌពិសេសពាក់ព័ន្ធនឹងកាតព្វកិច្ចរូបិយវត្ថុនៅមានសុពលភាព

នៅពេលកាតព្វកិច្ចរូបិយវត្ថុណាមួយ នៃភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅមានសុពលភាព ដែលស្ថិតនៅក្រោម ឬទាក់ទងនឹងកិច្ចព្រមព្រៀង CMIM នេះ ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណនោះ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១១.៤.១ ផ្ញើរបាយការណ៍តាមការស្នើសុំ

នៅពេលណាដែលភាគីផ្តល់ការដោះដូររូបិយប័ណ្ណស្នើសុំរបាយការណ៍ ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវផ្តល់ដោយគ្មានលក្ខខណ្ឌជាបន្ទាន់ទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណ នូវរបាយការណ៍ស្តីពី៖

(a) ទុនបំរុងអន្តរជាតិរបស់ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ

(b) ការកើនឡើង ឬធ្លាក់ចុះនៃប្រភេទទុនបំរុងរបស់ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង

(c) ពត៌មានផ្សេងទៀតៗពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលត្រូវបានស្នើសុំយ៉ាងសមហេតុផល ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណ។

ដើម្បីចៀសវាងការមន្ទិល លក្ខខណ្ឌតម្រូវនេះត្រូវអនុវត្តដាច់ដោយឡែកពីគ្នា រវាងប្រទេសចិន និងហុងកុងប្រទេសចិន។

១១.៤.២ ការរក្សាកម្រិតទុនបំរុងអន្តរជាតិសម្រាប់រយៈពេលបីខែនៃការនាំចូល៖

ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ គ្រប់ពេលវេលាត្រូវរក្សាទុនបម្រុងអន្តរជាតិដែលអាចប្រើប្រាស់បាន នៅត្រឹមកំរិតមួយដែលមិនតិចជាងចំនួនបានកំណត់។

សម្រាប់គោលដៅនៃមាត្រានេះ៖

(a) "ទុនបំរុងអន្តរជាតិអាចប្រើប្រាស់បាន" សំដៅដល់ទុនបំរុងអន្តរជាតិដុលផ្លូវការ ដក ការកាន់កាប់រូបិយប័ណ្ណដែលមិនអាចប្តូរបាន និង ប្រាក់បញ្ញើនៅសាខា និងបុត្រសម្ព័ន្ធនៃធនាគារ នៅបរទេស ដែលមានទីស្នាក់ការធំនៅក្នុងប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ។

(b) "ទុនបំរុងអន្តរជាតិដុលផ្លូវការ" សំដៅដល់ឥណទេយ្យចារឹកជារូបិយប័ណ្ណទាំងអស់ រាប់បញ្ចូលទាំង រូបិយវត្ថុជាមាស ការកាន់កាប់សិទ្ធិដកប្រាក់ពិសេស (ដែលបានបោះផ្សាយ ដោយ IMF) និងការដាក់ទុនបំរុងនៃប្រទេស/តំបន់ស្នើសុំការដោះដូរ រូបិយប័ណ្ណនៅក្នុង IMF ហើយមិនរាប់បញ្ចូលនូវការចូលរួមនៅក្នុងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងបំណុលលើនិវេសនជននៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ។

(c) "ចំនួនកំណត់" គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនាដោយរូបមន្ត ដូចខាងក្រោម៖

X x 3

ដែល X ជាតម្លៃមធ្យមនៃការនាំចូលប្រចាំខែដោយប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ សម្រាប់រយៈពេល៦(ប្រាំមួយ)ខែថ្មីៗនេះ ដូចបានកំណត់ក្នុងការបោះផ្សាយនៃ "ស្ថិតិហិរញ្ញវត្ថុអន្តរជាតិ" ដែលបានបោះពុម្ពនាពេលថ្មីៗបំផុត ដោយ IMF នៅក្នុងពេលដែលមានសំណើសុំការដោះដូររូបិយប័ណ្ណ សម្រាប់ការដកប្រាក់លើកទី១ ហើយនៅពេលដែលតម្លៃនៃការនាំចូលប្រចាំខែចេញផ្សាយនៅក្នុង"ស្ថិតិហិរញ្ញវត្ថុអន្តរជាតិ" ត្រូវបានកំណត់ជារូបិយវត្ថុក្នុងស្រុក ចំនួនទឹកប្រាក់នោះត្រូវប្តូរទៅជារូបិយប័ណ្ណដុល្លារអាមេរិក តាមអត្រាប្តូរប្រាក់ដែលអាចអនុវត្តបាន ដូចបានកំណត់ ដោយអនុលោមតាមតារាងកម្មវិធីទី៤។

ដើម្បីចៀសវាងការមន្ទិល លក្ខខណ្ឌតម្រូវនេះត្រូវអនុវត្តដាច់ដោយឡែកពីគ្នា រវាងប្រទេសចិន និងហុងកុងប្រទេសចិន។

១១.៤.៣ ការរក្សាទុនបំរុងអន្តរជាតិធៀបនឹងបំណុលបរទេសរយៈពេលខ្លី៖ ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណនៅគ្រប់ពេលទាំងអស់ ត្រូវរក្សាកម្រិតទុនបំរុងអន្តរជាតិ អាចប្រើប្រាស់បានឱ្យលើសពីបំណុលរយៈពេលខ្លីបីខែ (**"បំណុលរយៈពេលខ្លីបីខែ"**)។ សម្រាប់គោលបំណងនៃមាត្រានេះ បំណុលរយៈពេលខ្លីបីខែ មានន័យថា ជាចំនួនដែលស្មើនឹងមួយភាគបួន (១/៤) (ប៉ុន្តែមិនមែនបីដងនៃមួយភាគដប់ពីរ(១/១២)ទេ) នៃចំនួនប្រាក់ដើមនៅជំពាក់នៃបំណុលជាក់ស្តែងនាពេលបច្ចុប្បន្ន (ប៉ុន្តែពុំមែនជាបំណុលអាចព្យាករណ៍បានទេ) ដែល៖ (i) និវេសនជននៃប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ជំពាក់អនិវាសនជននិង (ii) មានឥណប្រតិទានដើមត្រឹម ០១ ឆ្នាំ ឬតិចជាងនេះ។

១១.៤.៤ ការសន្យាអវិជ្ជមាន

ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬ ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដោយគ្មានការយល់ព្រមពីភាគីផ្តល់ការដោះដូររូបិយប័ណ្ណ មិនត្រូវបង្កើត នាំមកនូវ ឬទទួលកាន់កាប់ថ្មីនូវនិក្ខេបការសន្យា សិទ្ធិដកទ្រព្យសម្បត្តិកូនបំណុល ទទួលភ័ណ្ឌ ឬ ភាពជំពាក់ណាមួយផ្សេងទៀត ដើម្បីធានាភាពជាប់បំណុលបរទេសដោយផ្ទាល់នៃរដ្ឋាភិបាលរបស់ខ្លួន (ក្រៅពីបំណុលដែលទូទាត់ជារូបិយវត្ថុក្នុងស្រុក)។ លុះត្រាតែគ្រប់កាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ត្រូវបានធានាស្មើៗគ្នា តែយ៉ាងណាក៏ដោយ បទបញ្ញត្តិនៅខាងមុខគេដែលបានចែងក្នុងមាត្រា១១.៤.៤ នេះ មិនត្រូវអនុវត្តចំពោះ:

(a) សិទ្ធិដកទ្រព្យសម្បត្តិណាមួយ ដែលកើតឡើងនៅពេលទិញទ្រព្យសម្បត្តិនោះ ដែលជាការធានាសម្រាប់ការទូទាត់សងចំពោះតម្លៃទិញនៃទ្រព្យសម្បត្តិនោះ ឬការធានាសម្រាប់ការទូទាត់បំណុលដែលបានកើតឡើង សម្រាប់ការធ្វើហិរញ្ញប្បទានដល់ការទិញទ្រព្យសម្បត្តិនោះឬ

(b) ការប្រាក់ពីមូលប័ត្រតំណាងទ្រព្យសម្បត្តិណាមួយ នៃដំណើរប្រតិបត្តិការសាមញ្ញរបស់ខ្លួន និងការធានាបំណុលដែលមានឥណប្រតិទានមិនលើសពីមួយឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលត្រូវបានធ្វើឡើងដំបូង។

១១.៤.៥ ភាពស្មើភាពគ្នា: ភាគីស្នើសុំការដោះដូររូបិយប័ណ្ណត្រូវធានាថា កាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ជាកាតព្វកិច្ចបំណុលផ្ទាល់កម្រិតខ្ពស់ ដែលយ៉ាងហោចណាស់ មានចំណាត់ថ្នាក់ស្មើភាពគ្នាចំពោះសិទ្ធិទូទាត់ជាមួយនឹងកាតព្វកិច្ចបំណុលផ្ទាល់កម្រិតខ្ពស់ ដែលគ្មានការធានាផ្សេងទៀត ដែលមាននាពេលបច្ចុប្បន្ន ឬក្នុងពេលអនាគត ដែលកើតចេញពីភាពជាប់បំណុលបរទេសណាមួយរបស់ខ្លួន លើកលែងតែកាតព្វកិច្ចដែលមានអាទិភាពដោយប្រតិបត្តិការនៃច្បាប់ (ក្រៅពីច្បាប់ទាំងឡាយណាដែល ត្រូវបានអនុម័តក្រោយកាលបរិច្ឆេទនៃកិច្ចព្រមព្រៀង CMIM នេះ) ឬដោយអនុលោមតាមមាត្រា១១.៤.៤។

១១.៤.៦ គ្មានការដាក់ការត្រួតពិនិត្យលើលំហូរចេញនៃមូលធន ពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀង CMIM នេះ: ប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ មិនត្រូវដាក់ការត្រួតពិនិត្យលំហូរចេញនៃមូលធនណាមួយ ដែលអាចមានឥទ្ធិពលអវិជ្ជមានលើការអនុវត្តកាតព្វកិច្ចរូបិយវត្ថុ កើតឡើងក្រោម ឬពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង CMIM នេះទេ លើកលែងតែបានផ្តល់សម្រាប់កម្មវិធីណាមួយ ដែលបានព្រមព្រៀងគ្នារវាងប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធ និងIMF។

១១.៤.៧ កាតព្វកិច្ចនៃការធ្វើលិខិតជូនដំណឹង: ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវធ្វើលិខិតជូនដំណឹងភ្លាមៗទៅឱ្យភាគីផ្តល់ការដោះដូររូបិយប័ណ្ណ អំពីព្រឹត្តិការណ៍ណាមួយ នៅពេលបានដឹងពីការកើតឡើង ដូចខាងក្រោម:

(a) ភាគីស្នើសុំការដោះដូររូបិយប័ណ្ណមិនអាចទូទាត់សងនូវចំនួនទឹកប្រាក់ណាមួយ ដែលដល់កាលកំណត់ ស្របតាមកិច្ចព្រមព្រៀងជាមួយម្ចាស់ឥណទានរបស់ខ្លួន

(b) ភាគីស្នើសុំការដោះដូររូបិយប័ណ្ណត្រូវបានបដិសេធជាផ្លូវការ ក្នុងការមិនផ្តល់នូវមធ្យោបាយឥណទាន កម្ចី ឬទម្រង់ការហិរញ្ញប្បទានផ្សេងទៀត ឬពន្យាពេល ឬបន្តកិច្ចសន្យានៃឥណទាន ឬកម្ចីទាំងនោះ ដោយរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាលណាមួយ ឬដោយធនាគារអន្តរជាតិសម្រាប់ការស្ថាបនាឡើងវិញនិងការអភិវឌ្ឍ (ធនាគារពិភពលោក) ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ឬ អង្គការអន្តរជាតិផ្សេងៗទៀត។

(c) ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ធ្វើការទូទាត់សងដោយឥតចេតនា មុនកាលបរិច្ឆេទដើម ទៅឱ្យរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាលណាមួយ ឬ ទៅឱ្យធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ឬ ស្ថាប័នអន្តរជាតិផ្សេងទៀត

(d) រាល់ការកែប្រែច្បាប់ វិធាន បទបញ្ញត្តិ សេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច ការពិត ឬកាលៈទេសៈដែលនឹង ឬអាចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ឬប្រែប្រួលដល់លទ្ធភាពរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដើម្បីអនុវត្ត (x) កាតព្វកិច្ចរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ឬ (y) វិធានការណ៍កែតម្រូវ ដែលខ្លួនមានគម្រោងអនុវត្តដើម្បីឆ្លើយតបនឹងបញ្ហា ឬ

(e) ព្រឹត្តិការណ៍ណាមួយបានកើតឡើង ដែលនឹងធ្វើឱ្យមានការរំលោភលើការសន្យាការធានា កាតព្វកិច្ច កិច្ចព្រមព្រៀង និងការប្រតិបត្តិនានា ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀង CMIM នេះ រួមទាំងព្រឹត្តិការណ៍ដូចបានរៀបរាប់ក្នុងមាត្រា១២.២ នៃកិច្ចព្រមព្រៀង CMIM នេះ បានកើតឡើង។

<u>មាត្រា១២ .. ការពន្លឿនប្រតិបត្តិការ</u>

១២.១ ការពន្លឿនប្រតិបត្តិការដោយផ្អែកលើព្រឹត្តិការណ៍វិសាមញ្ញ

ក្នុងករណីដែលប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និងប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ មានសង្គ្រាម ឬស្ថិតក្នុងស្ថានភាពស្រដៀងនឹងសង្គ្រាមរវាងគ្នា ឬក្នុងករណីដែលអង្គការអន្តរជាតិណាមួយដែលភាគីស្នើសុំការដោះដូររូបិយប័ណ្ណ និងភាគីផ្តល់ការដោះដូរ

រូបិយប័ណ្ណ ជាសមាជិក បានដាក់ទណ្ឌកម្ម ឬការរារាំងប្រឆាំងនឹងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ឬប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណនោះ ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ដោយធ្វើការជូនដំណឹងជាមុនទៅភាគីស្នើសុំការដោះដូររូបិយប័ណ្ណ យ៉ាងតិច១០ថ្ងៃនៃថ្ងៃធ្វើការ អាច (១) លុបចោលសិទ្ធិរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណដែលពាក់ព័ន្ធ ដើម្បីទិញរូបិយប័ណ្ណដុល្លារអាមេរិក ស្របតាមកិច្ចព្រមព្រៀង CMIM នេះ ដែលខណៈ និងសិទ្ធិនោះលែងមានសុពលភាពភ្លាមៗតែម្តង និង/ឬ (២) ប្រកាសថា កាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដើម្បីទិញយកវិញនូវរូបិយវត្ថុក្នុងស្រុកទល់នឹងរូបិយប័ណ្ណដុល្លារអាមេរិក ជាមួយនឹងការទូទាត់សងនៃការប្រាក់បង្គរ ដែលពាក់ព័ន្ធនឹងចំនួនទឹកប្រាក់បង្គរផ្សេងៗទៀត ឬចំនួនទឹកប្រាក់នៅមានសុពលភាព ឬទាក់ទងនឹងប្រតិបត្តិការដោះដូររូបិយប័ណ្ណ ឬប្រតិបត្តិការផ្សេងទៀតស្របតាមកិច្ចព្រមព្រៀង CMIM នេះ ត្រូវដល់កាលកំណត់ និងត្រូវទូទាត់សងភ្លាម ហើយការទូទាត់នេះត្រូវដល់ពេលកំណត់ និងត្រូវធ្វើឡើងភ្លាមតែម្តង។ ក្នុងការទូទាត់នៃការទិញយកវិញនេះ ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ ត្រូវបានតម្រូវឱ្យអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅពេលដែលភាគីស្នើសុំការដោះដូររូបិយប័ណ្ណបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនប៉ុណ្ណោះ។

១២.២ ការពន្លឿនប្រតិបត្តិការដោយសារការខកខាន

១២.២.១ ភាពខកខានជាក់លាក់

ប្រសិនបើព្រឹត្តិការណ៍ ឬកាលៈទេសៈណាមួយដូចបានរៀបរាប់ខាងក្រោមកើតឡើង និងកំពុងបន្តចំពោះភាគីស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ នូវព្រឹត្តិការណ៍ ឬកាលៈទេសៈបែបនោះ ត្រូវចាត់ថា ជាភាពខកខាន(“***ភាពខកខាន***”)ដែលធ្វើឡើងដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ:

១២.២.១.១: ការមិនទូទាត់សង: ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ មិនបានទូទាត់សងបំណុលតាមកាលកំណត់ខាងលើនូវចំនួនដែលត្រូវទូទាត់សងពាក់ព័ន្ធនឹងប្រតិបត្តិការដោះដូររូបិយប័ណ្ណណាមួយ (មានន័យថា ការផកប្រាក់ ឬការបន្តកិច្ចសន្យាផកប្រាក់) ដែលចូលជាធរមានស្របតាមកិច្ចព្រមព្រៀង CMIM នេះ ក្នុងទម្រង់ជារូបិយប័ណ្ណ ដែលមានកាតព្វកិច្ចទូទាត់សងត្រូវធ្វើឡើងយ៉ាងប្រញាប់ ដូចបានកំណត់ក្នុងព្រឹត្តិការណ៍ខកខានហើយនឹងមិនកើតឡើងក្រោមបទបញ្ញត្តនេះទេ ប្រសិនបើការទូទាត់ត្រូវបានធ្វើឡើងជារូបិយប័ណ្ណដូចបានកំណត់ជាមុន ក្នុងរយៈពេលមិនយឺតជាង ០៣ ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីពេលដល់កាលកំណត់នោះ។

១២.២.១.២ ការមិនអនុវត្តតាមកាតព្វកិច្ចផ្សេងទៀត

(a) នៅពេលមានការតម្រូវឱ្យអនុវត្តតាមបទបញ្ញត្តិណាមួយ ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ មិនបានអនុវត្តតាមបទបញ្ញត្តិមួយ ឬច្រើននៃកិច្ចព្រមព្រៀងCMIMនេះ ឬក៏ឯកសារផ្សេងទៀត ដែលបានផ្តល់ឱ្យដោយ ឬក្នុងនាមនៃភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោម ឬទាក់ទងនឹងកិច្ចព្រមព្រៀងCMIMនេះ ក្រៅពីបទបញ្ញត្តិដែលត្រូវបានយោងដោយឡែកក្នុងមាត្រា១២.២.១.១ ឬ

(b) ភាគីស្នើសុំការដោះដូររូបិយប័ណ្ណចាត់វិធានការណាមួយ ឬធ្វើការលុបចោលណាមួយ ដែលនឹងនាំឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណនោះមិនអនុវត្តតាមបទបញ្ញត្តិណាមួយ ឬបទបញ្ញត្តិនៃកិច្ចព្រមព្រៀង CMIM នេះ ឬក៏ឯកសារផ្សេងទៀត ដែលត្រូវបានផ្តល់ឱ្យដោយ ឬក្នុងនាមភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ក្រោមឬទាក់ទងជាមួយកិច្ចព្រមព្រៀង CMIM នេះ។

ថ្វីបើមានបទបញ្ញត្តិដូចខាងលើក៏ដោយ គ្មានភាពខកខាន ក្រោម(a) ឬ (b)ខាងលើ នឹងត្រូវបានចាត់ទុកថាបានកើតឡើងឡើយ ប្រសិនបើការខកខានដែលពាក់ព័ន្ធក្នុងការអនុវត្តតាមនេះ ឬ សកម្មភាពឬការលុបចោលដែលនាំឱ្យមានការមិនអនុវត្តតាមនេះ អាចដោះស្រាយបានក្នុងរយៈពេល ៥ ថ្ងៃនៃថ្ងៃធ្វើការ ភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទដែលបណ្តាប្រទេសសម្របសម្រួល ផ្តល់លិខិតទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណពាក់ព័ន្ធ អំពីឬកាលបរិច្ឆេទ ដែលភាគីស្នើសុំការដោះដូររូបិយប័ណ្ណ បានដឹងពីការខកខានក្នុងការអនុវត្តតាម ឬ អំពីសកម្មភាព ឬការលុបចោលដែលនាំឱ្យមានការមិនអនុវត្តតាម។

១២.២.១.៣ ការយល់ខុស: ប្រសិនបើការយល់ខុស ឬសេចក្តីថ្លែងណាមួយដែលត្រូវបានធ្វើឡើង ឬត្រូវចាត់ទុកថានឹងធ្វើឡើង ដោយប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្នុងកិច្ចព្រមព្រៀងCMIMនេះ ឬនៅក្នុងឯកសារផ្សេងទៀតដែលបានផ្តល់ឱ្យដោយ ឬក្នុងនាមប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណ នៅក្រោមឬទាក់ទងនឹងកិច្ចព្រមព្រៀង CMIM នេះ គឺជាឬមានភស្តុតាងបង្ហាញថា ជាភាពមិនត្រឹមត្រូវ ឬភាពនាំឱ្យយល់ខុស ដែលធ្វើឱ្យមានភាពខកខានដោយប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណដែលធ្វើឱ្យមានការយល់ខុស ឬសេចក្តីថ្លែងដែលមិនត្រឹមត្រូវ ឬនាំឱ្យយល់ខុស។

១២.២.២ ប្រសិទ្ធិភាព

នៅពេលណាមួយ បន្ទាប់ពីមានការកើតឡើងនៃភាពខកខាន ប្រទេសសម្របសម្រួលតាមរយៈការយល់ព្រមរបស់ ELDMB អាចផ្តល់លិខិតទៅឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណដែលជាអ្នកបង្កើតភាពខកខាននោះ (១) លុបចោលសិទ្ធិរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ

ពាក់ព័ន្ធលើការទិញរូបិយប័ណ្ណដុល្លារអាមេរិក ស្របតាមកិច្ចព្រមព្រៀង CMIM នេះ ដែលខណៈនោះសិទ្ធិនេះលែងមានសុពលភាពភ្លាមតែម្តង និង/ឬ (២) ប្រកាសថា កាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដើម្បីទិញយកវិញនូវរូបិយវត្ថុក្នុងស្រុកទល់នឹងរូបិយប័ណ្ណដុល្លារអាមេរិក ជាមួយនឹងការទូទាត់សងនៃការប្រាក់បង្គរពាក់ព័ន្ធ និងចំនួនទឹកប្រាក់បង្គរផ្សេងៗទៀត ឬចំនួនទឹកប្រាក់នៅមានសុពលភាព នៅក្រោម ឬទាក់ទងនឹងប្រតិបត្តិការដោះដូររូបិយប័ណ្ណ ឬប្រតិបត្តិការផ្សេងទៀតស្របតាមកិច្ចព្រមព្រៀង CMIM នេះ ត្រូវដល់កាលកំណត់ និងត្រូវទូទាត់សងភ្លាម ហើយដែលការទូទាត់នេះត្រូវដល់កាលកំណត់ និងធ្វើឡើងភ្លាមតែម្តង។

១២.២.៣ ការលើកលែងនៃភាពខកខាន

តាមរយៈការអនុម័តរបស់ ELDMB បណ្តាប្រទេសសម្របសម្រួលអាចលើកលែង ជាលាយលក្ខណ៍អក្សរពីភាពខកខាន ដែលកំណត់ថាប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ និង/ឬភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ដែលមាន ឬគ្មានការទាមទារឱ្យប្រទេស/តំបន់ស្នើសុំការដោះដូររូបិយប័ណ្ណ ទទួលយកលក្ខខណ្ឌបន្ថែម ហើយរាល់ការលើកលែងដែលត្រូវបានធ្វើឡើងស្របតាមបញ្ញត្តិនេះ ត្រូវអនុវត្តទៅលើគ្រប់ភាគីទាំងអស់នៃ CMIM។

<u>**មាត្រា១៣.- ការបញ្ឈប់សមាជិកភាពនៅក្នុងយន្តការ CMIM; ការបញ្ចូលជាសមាជិកភាពវិញ**</u>

១៣.១ នីតិវិធីនៃការបញ្ឈប់

ភាគី CMIM នីមួយៗ អាចបញ្ឈប់ការចូលរួមរបស់ខ្លួនក្នុងយន្តការ CMIM នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ដោយការផ្តល់លិខិតបញ្ជាក់ពីបំណងនេះ ទៅបណ្តាប្រទេសសម្របសម្រួល ដូចគ្នាដែលថាការបញ្ឈប់នោះមិនត្រូវសម្រាលឬលើកលែងអោយភាគី CMIM ដែលបញ្ឈប់នោះពីកាតព្វកិច្ចរបស់ខ្លួនជាភាគីមួយនៃCMIM ឬជាភាគីផ្តល់ការដោះដូររូបិយប័ណ្ណទាក់ទងនឹងសំណើសុំការដោះដូររូបិយប័ណ្ណណាមួយ ដែលត្រូវបានបោះឆ្នោតសម្រេចយ៉ាងត្រឹមត្រូវ បន្ទាប់ពីពេលដែលភាគី CMIM ដែលបញ្ឈប់នោះ ផ្តល់លិខិតពីបំណងខ្លួនក្នុងការបញ្ឈប់ការចូលរួមរបស់ខ្លួន (**"ប្រតិបត្តិការសេសសល់"**)។ លិខិតនៃការបញ្ឈប់ដែលធ្វើឡើងដោយភាគីមួយនៃ CMIM ដែលជាធនាគារកណ្តាល ក៏ដូចជាលិខិតនៃការបញ្ឈប់ដែលធ្វើឡើងដោយភាគីមួយនៃ CMIM ដែលជាក្រសួងហិរញ្ញវត្ថុនៃប្រទេសដូចគ្នានោះ ហើយក៏មានលក្ខណៈផ្ទុយទៅវិញដែរ។

១៣.២ វិបាកនៃការបញ្ឈប់

ក្នុងករណីដែលភាគី CMIM ណាមួយបានបញ្ឈប់សមាជិកភាពរបស់ខ្លួនក្នុងយន្តការ CMIM ស្របតាមមាត្រា១៣.១ សមាជិកនោះ មិនអាចធ្វើការដក់ប្រាក់ ឬបន្តកិច្ចសន្យាដក

ប្រាក់ណាមួយបានឡើយ និងគ្មានសិទ្ធិបោះឆ្នោតទាក់ទងនឹងយន្តការ CMIM ឬកិច្ចព្រមព្រៀង CMIM នេះទេ (ក្រៅតែពីប្រតិបត្តិការសេសសល់ណាមួយ) លុះត្រាតែ និងរហូតដល់មានការបញ្ចូលសមាជិកភាពរបស់ភាគីនោះឡើងវិញ ដោយអនុលោមតាមមាត្រា១៣.៣ ខាងក្រោម។ ក្នុងករណីដែលកាតព្វកិច្ចណាមួយរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ក្រោមប្រតិបត្តិការដោះដូររូបិយប័ណ្ណត្រូវបានអនុវត្តក្រោមកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងកាតព្វកិច្ចរូបិយវត្ថុណាមួយ ដែលនៅតែមានសុពលភាពដល់ពេលដែលមានការបញ្ឈប់កិច្ចព្រមព្រៀង CMIM ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណនោះ គ្រប់លក្ខខណ្ឌទាំងអស់នៃកិច្ចព្រមព្រៀង CMIM នេះ (លើកលែងតែលក្ខខណ្ឌដែលផ្តល់សិទ្ធិឱ្យភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ក្នុងការដកប្រាក់ ឬបន្តកិច្ចសន្យាដកប្រាក់) ត្រូវបន្តអនុវត្តរហូតដល់កាតព្វកិច្ចនោះ ត្រូវបានបំពេញ និងទូទាត់សងគ្រប់ចំនួន ដោយភាគីស្នើសុំការដោះដូររូបិយប័ណ្ណ។

១៣.៣ ការបញ្ចូលជាសមាជិកភាពឡើងវិញ

ប្រសិនបើភាគី CMIM ័មួយ បានបញ្ឈប់សមាជិកភាពរបស់ខ្លួនក្នុងយន្តការ CMIM បន្ទាប់ពីរយៈពេលមួយឆ្នាំ បានស្វែងរកឱ្យមានការបញ្ចូលសមាជិកភាពនោះឡើងវិញ នោះ MLDMB ត្រូវធ្វើការបោះឆ្នោតដើម្បីអនុញ្ញាតឱ្យភាគី CMIM នោះ ចូលជា សមាជិកឡើងវិញនៃយន្តការ CMIM។ ចាប់ពីកាលបរិច្ឆេទនៃអនុម័តរបស់ MLDMB ភាគី CMIM ត្រូវបានបញ្ចូលជាសមាជិកភាពឡើងវិញ ភាគីនោះត្រូវមានសិទ្ធិចូលរួមក្នុងយន្តការ CMIM ក៏ដូចជាអនុវត្តសិទ្ធិបោះឆ្នោតក្នុងនាមជាសមាជិកបោះឆ្នោតមួយនៃ MLDMB និង ELDMB ស្របតាមលក្ខខណ្ឌដែលត្រូវបានកែប្រែ ឬធ្វើវិសោធនកម្ម ពីពេលមួយទៅពេលមួយ ដោយ MLDMB បើមិនដូច្នោះ លក្ខខណ្ឌទាំងនោះនឹងអាចអនុវត្តបានចំពោះភាគី CMIM បើសិនភាគីនោះមិនបានបញ្ឈប់ជាសមាជិកភាពរបស់ខ្លួនក្នុងយន្តការ CMIM។ ថ្វីបើមានការចែងដូចខាងលើក៏ដោយ ភាគី CMIM ណាមួយ ដែលបានបញ្ឈប់សមាជិកភាពរបស់ខ្លួន អាចស្វែងរកការបញ្ចូលសមាជិកភាពឡើងវិញ មុនរយៈពេលកន្លងផុតមួយឆ្នាំ ដោយផ្អែកលើអនុសាសន៍អនុគ្រោះនៃ ELDMB និងបន្ទាប់ពីនោះដោយការអនុម័តជាឯកច្ឆ័ននៃ MLDMB។

<u>មាត្រា១៤.- លិខិត</u>

ភាសាដែលត្រូវបានប្រើប្រាស់ក្នុងគ្រប់ឯកសារ និងលិខិតទាំងអស់ ដែលធ្វើឡើងរវាងបណ្តាភាគី CMIM ស្របតាម និងទាក់ទងនឹងកិច្ចព្រមព្រៀង CMIM នេះ ត្រូវធ្វើឡើងជាភាសាអង់គ្លេស។ រាល់លិខិតសំណើការផ្តល់ការយល់ស្រប ឯកសារ ឬទំនាក់ទំនងផ្សេងទៀតដែលត្រូវបានដាក់ដោយភាគីមួយនៃ CMIM ទៅភាគីផ្សេងទៀត នៅក្រោម ឬទាក់ទងនឹងកិច្ចព្រមព្រៀង CMIM នេះ ត្រូវធ្វើជាលាយល័ក្ខអក្សរ ផ្ញើតាមយន្តហោះ ទូរគមនាគមន៍

យថាភូត ឬប្រគល់ដោយផ្ទាល់ខ្លួន (លុះត្រាតែមានការកំណត់ផ្សេង ក្នុងបទបញ្ញត្តិនៃកិច្ចព្រមព្រៀង CMIM នេះ ក្នុងការដាក់កម្រិតចំពោះវិធីសាស្ត្រទំនាក់ទំនង) ត្រូវធ្វើសេចក្តីយោងដល់កិច្ចព្រមព្រៀង CMIM នេះ និងត្រូវបានចាត់ទុកថា បានឱ្យ ឬផ្ញើរឱ្យ នៅពេលដែលបានប្រគល់ទៅឱ្យភាគី CMIM (ឬ បណ្តាភាគី CMIM) ដែលបានកំណត់ថាជាអ្នកទទួល។

លើកលែងតែការចែងដូចខាងក្រោម រាល់ទំនាក់ទំនងពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង CMIM នេះ នឹងត្រូវបានចាត់ទុកថា ត្រូវបានឱ្យៈ (ក)ប្រសិនបើត្រូវបានប្រគល់ដោយផ្ទាល់ដៃ ឬផ្ញើរតាមយន្តហោះ គឺនៅពេលមានការប្រគល់ (ខ)ប្រសិនបើផ្ញើរតាមទូរសារ គឺនៅពេលដែលទូរសារនោះត្រូវបានទទួលដោយនិយោជិតទទួលខុសត្រូវម្នាក់ ក្នុងទម្រង់អាចអានបាន (មានការព្រមព្រៀងថា ការបង្ហាញភស្តុតាងពីការទទួល នឹងត្រូវទទួល បន្ទុកដោយអ្នកផ្ញើរ និងមិនត្រូវផ្អែកលើរបាយការណ៍បញ្ជូនចេញពីម៉ាស៊ីនទូរសាររបស់អ្នកផ្ញើរ) និង (គ) ប្រសិនបើតាមរយៈ SWIFT គឺនៅពេលមានការប្រគល់។ បើការទទួលបាន ប៉ះចំថ្ងៃដែលមិនមែនជាថ្ងៃធ្វើការ ឬបន្ទាប់ពីម៉ោងធ្វើការនៅកន្លែងនៃការទទួល នោះទំនាក់ទំនងតាមរបៀបរបាយ ដែលមានចែងខាងលើ នឹងត្រូវចាត់ទុកថា បានឱ្យនៅថ្ងៃធ្វើការបន្ទាប់នៅទីកន្លែងនោះ។

លិខិតណាមួយដែលបានតម្រូវឱ្យផ្តល់ទៅភាគី CMIM ណាមួយ នៅក្រោម ឬទាក់ទងនឹងបទបញ្ញត្តិនៃកិច្ចព្រមព្រៀង CMIM នេះ ត្រូវបានប្រគល់ទៅឱ្យភាគី CMIM នោះ តាមអាស័យដ្ឋាន និង/ឬ លេខទូរសារដែលបានបង្ហាញសម្រាប់ភាគី CMIM នោះ ក្នុងតារាងកម្មវិធីទី៩។

មាត្រា១៥ .. ការរក្សាការសម្ងាត់

លើកលែងតែកម្រិតនៃការបង្ហាញពត៌មានណាមួយ ដែលតម្រូវដោយច្បាប់ និងបទបញ្ញត្តិ ដែលអាចអនុវត្តបានចំពោះខ្លួន ឬដោយដីការបស់តុលាការនៃយុត្តាធិការដែលមានសមត្ថកិច្ច ឬប្រសិនបើមានភាពចាំបាច់សម្រាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀង CMIM នេះ ភាគី CMIM នីមួយៗ ត្រូវធ្វើប្រព្រឹត្តកម្មមាតិការនៃកិច្ចព្រមព្រៀងCMIMនេះ និងប្រតិបត្តិការដោះដូររូបិយប័ណ្ណណាមួយ ដែលត្រូវបានអនុវត្ត ឬពិចារណាស្របតាមកិច្ចព្រមព្រៀងនេះ ជាមួយឯកសារនានា និងពត៌មានពាក់ព័ន្ធនឹងឯកសារទាំងនោះ ថាជាពត៌មានសម្ងាត់ នឹងត្រូវរក្សាឱ្យបានត្រឹមត្រូវដើម្បីបង្ការ និងចៀសវាងការបង្ហាញពត៌មានទាំងនោះជាសាធារណៈ។ ទោះយ៉ាងណាក៏ដោយ មានលក្ខខណ្ឌថា កាតព្វកិច្ច នៅក្រោមមាត្រា១៥ នេះ ត្រូវលើកលែងមិនអនុវត្តចំពោះរាល់ព័ត៌មានដែលលេចឮដល់សាធារណៈ ក្រៅពីការរំលោភដោយភាគី CMIM ណាមួយ ទៅលើកិច្ចព្រមព្រៀង CMIM នេះ ហើយភាគី CMIM នីមួយៗអាចផ្តល់ពត៌មាននោះទៅឱ្យទីប្រឹក្សាវិជ្ជាជីវៈ និងមន្ត្រីរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការផ្តល់ប្រឹក្សា និងក្នុងការ

ជួយចំពោះភាគី CMIM ទាក់ទងនឹងការងារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង CMIM ដែលជាអ្នកធ្វើឱ្យមានការដឹងពីភាពសម្ងាត់នៃពត៌មាននោះ និងត្រូវមានកាតព្វកិច្ចឱ្យរក្សាការសម្ងាត់នោះ។

មាត្រា១៦ .- ការធ្វើវិសោធនកម្ម

គ្មានការធ្វើវិសោធនកម្មណាមួយចំពោះកិច្ចព្រមព្រៀង CMIM នេះ អាចយកជាបានការឡើយ លុះត្រាតែវិសោធនកម្មនេះត្រូវបានធ្វើឡើង និងផ្តល់ការយល់ព្រមជាលាយលក្ខអក្សរដោយភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ។

មាត្រា១៧ .- កាលកំណត់នៃការពិនិត្យឡើងវិញនៃយន្តការ CMIM និងរចនាសម្ព័ន្ធរបស់ CMIM

ក្នុងរយៈពេលមួយឆ្នាំ មុនពេលបញ្ចប់នៃអំឡុងពេលប្រាំឆ្នាំជាប់គ្នានីមួយៗ គិតចាប់ពីថ្ងៃចូលជាធរមាន (ដូចកំណត់ខាងក្រោម) បណ្តាភាគី CMIM ត្រូវរួមគ្នាធ្វើការពិនិត្យឡើងវិញជាមូលដ្ឋាននៃយន្តការ CMIM និងលក្ខខណ្ឌគន្លឹះនៃកិច្ចព្រមព្រៀង CMIM នេះ (ការពិនិត្យឡើងវិញនីមួយៗ ហៅថា **"ការពិនិត្យឡើងវិញរយៈពេលប្រាំឆ្នាំ"**) រាប់បញ្ចូលទាំងទំហំសរុបនៃយន្តការ CMIM ចំនួនទឹកប្រាក់ភាគីទាន CMIM របស់ភាគី CMIM នីមួយៗ ចំនួនទឹកប្រាក់**អតិបរមា**នៃការដោះដូររូបិយប័ណ្ណ លក្ខខណ្ឌនៃការទិញ និងលក់ និងការងារផ្សេងទៀត ដែលត្រូវបានចាត់ទុកថាមានការពាក់ព័ន្ធ និង/ឬ មានការចាំបាច់ ដើម្បីធានាថា យន្តការ CMIM និងកិច្ចព្រមព្រៀង CMIM នេះ នៅតែមានលក្ខណៈ បច្ចុប្បន្នភាព និងឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវកាលៈទេសៈជាក់ស្តែងរបស់បណ្តាភាគី CMIM ក៏ដូចជាស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ដែលមាននៅពេលធ្វើការពិនិត្យឡើងវិញរយៈពេលប្រាំឆ្នាំ ដែលពាក់ព័ន្ធ។ ទោះបីមានការចែងខាងលើនេះក៏ដោយ ការពិនិត្យ ឡើងវិញជាលក្ខណៈពិសេស អាចត្រូវបានធ្វើឡើងនៅពេលចាំបាច់ ឬគិតថាចាំបាច់ បន្ទាប់ពីមានការអនុម័តជាឯកច្ឆ័នដោយ MLDMB។

មាត្រា១៨ .- បង្កើតអង្គភាពដំណើរការឃ្លាំមើល

១៨.១ អង្គភាពដំណើរការឃ្លាំមើលមួយក្រោម CMIM (**"អង្គភាពឃ្លាំមើល CMIM"**) ត្រូវបានបង្កើតឡើងដោយបណ្តាភាគី CMIM។

១៨.២ អង្គភាពឃ្លាំមើល CMIM នឹងត្រូវបានកំណត់ជ្រើសរើសដោយក្រុមអ្នកធ្វើការសម្រេចរបស់ CMIM ហើយមុខងាររបស់អង្គភាពនេះ គឺត្រូវៈ

(a) តាមដាន វាយតម្លៃ និងរាយការណ៍អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងភាពរឹងមាំហិរញ្ញវត្ថុ របស់ភាគី CMIM ទាំងអស់ និង

(b) វាយតម្លៃបញ្ហាម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលអាចកើតឡើង ចំពោះភាគី CMIM ណាមួយ ដើម្បីជួយឱ្យបានទាន់ពេល ក្នុងការរៀបចំអនុសាសន៍ជាគោលនយោបាយសម្រាប់កាត់បន្ថយហានិភ័យនោះ។ (ការតាមដាននោះ ត្រូវធ្វើរហូតដល់ពេលក្រោយការដក

ប្រាក់តាមគ្រប់សំណើសុំដោះដូររូបិយប័ណ្ណទាំងអស់ និងត្រូវធានាថា កិច្ចសន្យានៃការឱ្យខ្ចី ត្រូវបានបំពេញ ក្នុងចំណោមលក្ខខណ្ឌផ្សេងទៀត។)

មាត្រា១៩ .. កាលបរិច្ឆេទចូលជាធរមាន

១៩.១ ភាគី CMIM នីមួយៗ ត្រូវប្រគល់ទំព័រហត្ថលេខាដែលបានចុះរួចនៃកិច្ចព្រមព្រៀង CMIM ទៅឱ្យគ្រប់ភាគី CMIM ផ្សេងទៀត (ប្រសិនបើពាក់ព័ន្ធ គឺប្រគល់ឱ្យជាមួយនឹងលិខិតមួយដែលបញ្ជាក់ថា សច្ចាប័នផ្ទៃក្នុង ត្រូវបានតម្រូវឱ្យធ្វើសម្រាប់ ភាគី CMIM នេះ) ឆាប់ៗតាមដែលអាចអនុវត្តបាន និងត្រូវធ្វើលិខិតភ្ជាមទៅភាគី CMIM នីមួយៗ ជាលាយល័ក្ខអក្សរនៅពេលបានបំពេញការផ្តល់សច្ចាប័នផ្ទៃក្នុងរបស់ខ្លួន ដែលចាំបាច់សំរាប់ការអនុវត្តកិច្ចព្រមព្រៀង CMIM នេះ។

១៩.២ កិច្ចព្រមព្រៀង CMIM នេះ ត្រូវចូលជាធរមាននៅកាលបរិច្ឆេទចុងក្រោយនៃរយះពេល ៩០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលភាគី CMIM នៃប្រទេសចិន ជប៉ុន កូរ៉េ និងបណ្តាប្រទេសអាស៊ានចំនួនប្រាំ ឬច្រើនជាងនេះ បានប្រតិបត្តិ និងប្រគល់កិច្ចព្រមព្រៀង CMIM នេះ និងតាមវិសាលភាពនៃការអនុវត្ត និងបានបំពេញនូវរាល់ដំណើរការនៃការផ្តល់សច្ចាប័នផ្ទៃក្នុងសម្រាប់ការអនុវត្តកិច្ចព្រមព្រៀង CMIM នេះ (កាលបរិច្ឆេទចូលជាធរមាន)។

១៩.៣ កិច្ចព្រមព្រៀង CMIM នេះត្រូវចូលជាធរមានចំពោះបណ្តាភាគី CMIM ដែលបានបញ្ចប់ដំណើរការផ្តល់សច្ចាប័នផ្ទៃក្នុងរបស់ខ្លួនរួចរាល់ និងបានប្រតិបត្តិកិច្ចព្រមព្រៀង CMIM នេះ នៅកាលបរិច្ឆេទចូលជាធរមាន ហើយភាគី CMIM ដែលអនុវត្ត និងប្រគល់កិច្ចព្រមព្រៀង CMIM នេះ និងបញ្ចាប់ដំណើការផ្តល់សច្ចាប័នផ្ទៃក្នុងរបស់ខ្លួន បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាន ត្រូវបានចាត់ទុកថា ក្លាយជាភាគីមួយនៃកិច្ចព្រមព្រៀង CMIM នេះ នៅកាលបរិច្ឆេទជាក់ស្តែងនោះ។

មាត្រា២០ .. សមភាគី

២០.១ កិច្ចព្រមព្រៀង CMIM នេះអាចត្រូវបានធ្វើដោយសំណៅដើមមួយចំនួន និងដោយភាគីនីមួយៗដាច់ដោយឡែកពីគ្នា។

២០.២ សំណៅនីមួយៗ ត្រូវបានបង្កើតជាច្បាប់ដើមនៃកិច្ចព្រមព្រៀង CMIM នេះ ប៉ុន្តែ គ្រប់សំណៅទាំងអស់រួមគ្នា បង្កើតបានជាកិច្ចព្រមព្រៀងមួយ និងមានតម្លៃដូចគ្នា។

មាត្រា២១ .. ច្បាប់គ្រប់គ្រង និង យុត្តាធិការ

កិច្ចព្រមព្រៀងCMIMនេះ ត្រូវបានគ្រប់គ្រង និងបង្កើតឡើង ស្របតាមច្បាប់នៃប្រទេសអង់គ្លេស និងរាល់ជំលោះដែលកើតឡើង នៅក្រោម ឬទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ត្រូវជាកម្មវត្ថុនៃយុត្តាធិការមិនផ្តាច់មុខនៃតុលាការពាក់ព័ន្ធនៃប្រទេសអង់គ្លេស ដែលភាគីនីមួយៗ នៃ

CMIM ស្ម័គ្រចិត្តដាក់បណ្តឹងទៅទីនោះ ប៉ុន្តែមានលក្ខខណ្ឌដែលថា ជំលោះណាមួយពាក់ព័ន្ធនឹងប្រតិបត្តិការដោះដូររូបិយប័ណ្ណ ដែលចុះកិច្ចសន្យាដោយ និងរវាងភាគីផ្តល់ការដោះដូររូបិយប័ណ្ណ និងភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ស្របតាមកិច្ចព្រមព្រៀង CMIM នេះ ត្រូវអាស្រ័យលើយុត្តាធិការនៃតុលាការពាក់ព័ន្ធ របស់ប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ។

មាត្រា២២.- ការលើកលែងអភ័យឯកសិទ្ធិ

ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ យល់ព្រមដោយពុំអាចបដិសេធបាន ប្រសិនបើសកម្មភាព ឬបណ្តឹងតតិយុត្តិណាមួយ (ទោះបីជាដីកា ឬការលើកលែងអន្តរកាល ការអនុវត្តជាក់លាក់ ការទាញយកផលពីដី ការខូចខាត ឬ ផ្សេងៗទៀត) ដែលកើតឡើងពី ឬទាក់ទងនឹងកាតព្វកិច្ចរបស់ខ្លួនចំពោះភាគីផ្តល់ការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ដែលត្រូវអនុវត្តគ្រប់កន្លែង ដែលភាគីស្នើសុំការដោះដូររូបិយប័ណ្ណមាន ឬដែលអាចមាន៖ អភ័យឯកសិទ្ធិពីយុត្តាធិការនៃតុលាការ ឬសាលាក្តីណាមួយ ឬពីដំណើរការតតិយុត្តិ (រាប់បញ្ចូលទាំង សេវា ឬ លិខិតនៃដំណើរការ និងរាល់ដំណើរការសម្រាប់ប្រតិបត្តិនៃការផ្តល់រង្វាន់ ឬការវិនិច្ឆ័យ រួមទាំងការភ្ជាប់ជូនមុនការកាត់ក្តី និងការភ្ជាប់ក្នុងប្រតិបត្តិការ) ចំពោះខ្លួនឯង ឬទ្រព្យសម្បត្តិរបស់ខ្លួន នោះភាគីស្នើសុំការដោះដូររូបិយប័ណ្ណ លើកលែងដោយគ្មានកែប្រែនូវរាល់បណ្តឹងចំពោះអភ័យឯកសិទ្ធិដែលអនុញ្ញាតដោយច្បាប់នៃយុត្តាធិការនោះ លើកលែងតែចំពោះទ្រព្យសកម្មរបស់ខ្លួន [1] ដែលត្រូវបានបើកចំហចំពោះការប្រើប្រាស់របស់សាធារណជន ឬរដ្ឋាភិបាល កំណត់ពន្យល់ពេលបច្ចុប្បន្ន ឬនាពេលអនាគត នៃបេសសកកម្មដូចកំណត់ក្នុងអនុសញ្ញាក្រុង Vienna ស្តីពីទំនាក់ទំនងការទូត ដែលបានចុះហត្ថលេខាក្នុងឆ្នាំ ១៩៦៣ កំណត់ពន្យល់របស់កុងស៊ុលដូចបានកំណត់ក្នុងអនុសញ្ញា Vienna ស្តីពី ទំនាក់ទំនងកុងស៊ុល ដែលត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ ១៩៦៣ ឬ ទ្រព្យសម្បត្តិយោធា ឬទ្រព្យសកម្មផ្សេងទៀតដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋាភិបាល និងជាកម្មវត្ថុនៃការរឹតត្បិតចំពោះភាពមិនអាចដកចេញបានសាធារណៈ និងការរឹបអូសទ្រព្យសម្បត្តិរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់ខ្លួនចំពោះភាគីផ្តល់កិច្ចព្រមព្រៀងដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ។

---

[1] ដូចមានក្នុងឧបសម្ព័ន្ធ១៣០៥ និង១៣០៧ នៃក្រមស៊ីវិល និងពាណិជ្ជកម្មនៃប្រទេសថៃ
និងទ្រព្យសកម្មផ្សេងទៀតដែលជាផ្នែកមួយនៃកម្មសិទ្ធិរបស់សាធារណៈ ឬទ្រព្យសម្បត្តិនៃរដ្ឋាភិបាល
និងដោយយោងតាមការកំណត់ដែលមិនអាចប្តូរបាននៃកម្មសិទ្ធិសាធារណៈ
និងការរឹបអូសនៃទ្រព្យសម្បត្តិរបស់រដ្ឋាភិបាល

មាត្រា២៣.- ការទូទាត់សំណង

ចំពោះប្រតិបត្តិការដោះដូររូបិយប័ណ្ណដែលចូលជាធរមាន ក្រោមកិច្ចព្រមព្រៀង CMIM នេះ ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ត្រូវសង និងកាន់កាប់ដោយគ្មានគ្រោះថ្នាក់ ចំពោះភាគីផ្តល់ការដោះដូររូបិយប័ណ្ណនៃភ្នាក់ងារ ប្រធាន (director) មន្ត្រី ឬនិយោជិក (ដែលជាបុគ្គលដែលត្រូវទូទាត់ (indemnified person) ដែលជា (ភាគីដែលត្រូវទូទាត់ (indemnified party)) ពី និង ចំពោះរាល់បំណុល ភាតព្វកិច្ច ការខាតបង់ ការបំផ្លេចបំផ្លាញ ការដាក់ទណ្ឌកម្ម ការកាត់ក្តី តម្លៃដើម ការចំណាយ ឬការចំណាយប្រាក់នៃអ្វីដែលអាចត្រូវមានការពាក់ពន្ធ ឬទទួលរងដោយ ឬអះអាងការពារ ភាគីដែលត្រូវទូទាត់ដែលពាក់ព័ន្ធនឹង ឬកើតឡើងក្រៅពីកិច្ចព្រមព្រៀង CMIM នេះ ឬរាល់ប្រតិបត្តិការកិច្ចព្រមព្រៀងដោះដូររូបិយប័ណ្ណនៅក្រោម ឬសកម្មភាពទាំងឡាយណាដែលបានចាត់វិធានការ ឬលប់ដោយភាគី ដែលត្រូវទូទាត់ដែលទាក់ទងជាមួយកិច្ចព្រមព្រៀង CMIM នេះ ឬរាល់ប្រតិបត្តិការទាំងឡាយណា នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ដែលរាប់បញ្ចូលទាំង គ្មានការកំណត់រាល់សកម្មភាពដែលបានចាត់វិធានការ ឬលុប ទាក់ទងជាមួយនឹងយន្តការនៃកិច្ចព្រមព្រៀង CMIM នេះ មុនកាលបរិច្ឆេទមានប្រសិទ្ធិភាពនៃកិច្ចព្រមព្រៀង CMIM នេះ ដោយភាគីដែលត្រូវទូទាត់។ ភាគីស្នើសុំកិច្ចប្រមព្រៀងដោះដូររូបិយប័ណ្ណ ទោះយ៉ាងណាក៏ មិនត្រូវមានបំណុលសម្រាប់ចំណែកណាមួយនៃចំនួននេះ ដែលជាលទ្ធផលពីការធ្វេសប្រហែសទាំងស្រុង ឬធ្វើខុសដោយតាំងចិត្តនៃភាគីត្រូវទូទាត់។

មាត្រា២៤.- គ្មានការលើកលែង

គ្មានការខកខាន ពន្យារពេល ឬការទប់ស្កាត់ ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណក្នុងអនុវត្តរាល់សិទ្ធិ ឬការបង្ការដែលបង្ករចំពោះភាគីផ្តល់ការដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM នេះ ត្រូវប្រតិបត្តិជាការលើកលែង (waiver) ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណនៃសិទ្ធិ ឬការបង្ការទុកនោះ នឹងមិនត្រូវការអនុវត្ត (exercise) ទាំងមូល ឬផ្នែកណាមួយនៃសិទ្ធិ ឬការបង្ការទុក ដែលប្រតិបត្តិជាការលើកលែងមួយនៃរាល់សិទ្ធិ ឬការបង្ការទុក។ សិទ្ធិ និងការបង្ការ ដែលបានផ្តល់ឱ្យ គឺបង្គរ (cumulative) និងមិនដាច់ឡែក (exclusive) នៃរាល់សិទ្ធិ ឬ ការបង្ការទុកដែលផ្តល់ដោយច្បាប់។

ដើម្បីធ្វើជាសាក្សី ភាគីនីមួយៗដែលបានទទួលការអនុញ្ញាតយ៉ាងត្រឹមត្រូវពីរដ្ឋាភិបាលនៃប្រទេសសមាជិករៀងៗខ្លួន បានចុះហត្ថលេខាធ្វើជាតំណាងក្នុងការប្រតិបត្តិលើកិច្ចព្រមព្រៀង CMIM នេះ មានដូចខាងក្រោមៈ

<u>ប្រទេសព្រុយណេដារុសសាឡាំ :</u> ក្រសួងហិរញ្ញវត្ថុ ដោយ : .... ឈ្មោះ : ឋានៈ : រដ្ឋមន្ត្រីហិរញ្ញវត្ថុ II	ក្រុមប្រឹក្សាភិបាលរូបិយប័ណ្ណ និង រូបិយវត្ថុ ប្រទេសព្រុយណេដែលលើវត្តនាទីជាភ្នាក់ងារ សម្រាប់រដ្ឋាភិបាលនៃព្រះរុកណា The Sultan and Yang Dipertuan នៃប្រទេសព្រុយណេ ដារុសសាឡាំតំណាងដោយក្រសួងហិរញ្ញវត្ថុ ដោយ : .... ឈ្មោះ : ឋានៈ :នាយកប្រតិបត្តិក្រុមប្រឹក្សាភិបាលរូបិយប័ណ្ណ និងរូបិយវត្ថុព្រុយណេ
<u>ប្រទេសកម្ពុជា:</u> ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយ: .... ឈ្មោះ: គាត ឈន់ ឋានៈ: ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	ធនាគារជាតិនៃកម្ពុជា ដោយ : .... ឈ្មោះ: ជា ចាន់តូ ឋានៈ : ទេសាភិបាល
<u>ប្រទេសឥណ្ឌូនេស៊ី:</u> ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ដោយ: .... ឈ្មោះ: Sri Mulyani Indrawati ឋានៈ : រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃសាធារណរដ្ឋឥណ្ឌូនេស៊ី	ធនាគារឥណ្ឌូនេស៊ី ដោយ: .... ឈ្មោះ : Darmin Nasution ឋានៈ : ទេសាភិបាលស្តីទី
<u>សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ:</u> ក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដោយ: .... ឈ្មោះ: H.E Mr. Somdy Douangdy ឋានៈ: រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃសាធារណរដ្ឋប្រមានិតប្រជាធិបតេយ្យឡាវ	ធនាគារនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដោយ: .... ឈ្មោះ: Phouphet Khamphoun Vong ឋានៈ: ទេសាភិបាល
<u>ប្រទេសម៉ាឡេស៊ី:</u>	

រដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី តំណាង ដោយក្រសួងហិរញ្ញវត្ថុ ដោយៈ .... ឈ្មោះ:Dato' Seri Ahmad Husni ឋានៈ : រដ្ឋមន្ត្រីហិរញ្ញវត្ថុ II	ធនាគារណាហ្គារ៉ាម៉ាឡេស៊ី ដោយៈ .... ឈ្មោះ : Zeti Akhtar Aziz ឋានៈ : ទេសាភិបាល
ប្រទេសមីយ៉ាន់ម៉ា: ក្រសួងសេដ្ឋកិច្ច និងចំណូល ដោយៈ .... ឈ្មោះ:ឧត្តមសេនីទោ Hla Tun ឋានៈ : រដ្ឋមន្ត្រី	ធនាគារកណ្តាលមីយ៉ាន់ម៉ា ដោយ : .... ឈ្មោះ : Than Nyein ឋានៈ : ទេសាភិបាល
ប្រទេសហ្វីលីពីន: ក្រសួងហិរញ្ញវត្ថុ ដោយៈ .... ឈ្មោះ: Margarito B. Teves ឋានៈ : Secretary	ធនាគារកណ្តាលនៃហ្វីលីពីន ដោយៈ .... ឈ្មោះ : Amando M. Tetangco, Jr. ឋានៈ : ទេសាភិបាល
ប្រទេសសិង្ហបុរី: ក្រសួងហិរញ្ញវត្ថុ,សម្រាប់ និងក្នុងនាម រដ្ឋាភិបាលនៃសិង្ហបុរី ដោយៈ .... ឈ្មោះ: Tharman Shanmuga ratnam ឋានៈ:: រដ្ឋមន្ត្រីហិរញ្ញវត្ថុ	អាជ្ញាធររូបិយវត្ថុសិង្ហបុរី ដោយៈ .... ឈ្មោះ : Heng Swee Keat ឋានៈ : នាយកគ្រប់គ្រង
ប្រទេសថៃ: ក្រសួងហិរញ្ញវត្ថុ ដោយៈ .... ឈ្មោះ :Korn Chatikavanij	ធនាគារថៃ ដោយៈ .... ឈ្មោះ : Tarisa Watanagase

ឋានៈ : រដ្ឋមន្ត្រីហិរញ្ញវត្ថុ	ឋានៈ : ទេសាភិបាល
<u>ប្រទេសវៀតណាមៈ</u> ក្រសួងហិរញ្ញវត្ថុ ដោយៈ .... ឈ្មោះ: Vu Van Ninh ឋានៈ : រដ្ឋមន្ត្រីហិរញ្ញវត្ថុ	ធនាគាររដ្ឋវៀតណាម ដោយ : .... ឈ្មោះ: Nguyen Van Giau ឋានៈ : ទេសាភិបាល
<u>សាធារណរដ្ឋប្រជាមានិតចិនៈ</u> ក្រសួងហិរញ្ញវត្ថុ ដោយៈ .... ឈ្មោះ: Xuren Xie ឋានៈ : រដ្ឋមន្ត្រី	ធនាគារប្រជាជនចិន ដោយៈ .... ឈ្មោះ : Xiao Chuan Zhou ឋានៈ : ទេសាភិបាល
	<u>ហុងកុងប្រទេសចិនៈ</u> អាជ្ញាធររូបិយវត្ថុនៃហុងកុងប្រទេសចិន សម្រាប់ការទទួលខុសត្រូវលើមូលនិធិ ដោះដូរ (Exchange Fund) ដោយៈ .... ឈ្មោះ :Mr. Norman T.L Chan ឋានៈ : អាជ្ញាធររូបិយវត្ថុ
<u>ប្រទេសជប៉ុនៈ</u> ក្រសួងហិរញ្ញវត្ថុ ដោយៈ .... ឈ្មោះ : Hirohisa Fujii ឋានៈ : រដ្ឋមន្ត្រីហិរញ្ញវត្ថុ	ធនាគារជប៉ុន ជាភ្នាក់ងារសម្រាប់រដ្ឋមន្ត្រីហិរញ្ញវត្ថុនៃប្រទេសជប៉ុន ដោយៈ .... ឈ្មោះ : Masaaki Shirakawa ឋានៈ : ទេសាភិបាល

សាធារណរដ្ឋកូរ៉េ:	
ក្រសួងហិរញ្ញវត្ថុ	ធនាគារកូរ៉េ
ដោយ:	ដោយ: ....
ឈ្មោះ: Jeung-Hyun Yoon	ឈ្មោះ : Seongtae Lee
ឋានៈ : រដ្ឋមន្ត្រី	ឋានៈ : ទេសាភិបាល

តារាងកម្មវិធីទី១

ការរួមចំណែក CMIM, ការបែងចែកពហុគុណ និងអំណាចបោះឆ្នោត

	ការរួមចំណែកហិរញ្ញវត្ថុ				ការទិញពហុគុណ	សន្លឹកឆ្នោតមូលដ្ឋាន	បោះឆ្នោតដោយផ្អែកលើការរួមចំណែក	អំណាចបោះឆ្នោតសរុប	
	ដុល្លារ (មួយពាន់លាន)		(%)			(ចំនួនសន្លឹកឆ្នោត)	(ចំនួនសន្លឹកឆ្នោត)	(ចំនួនសន្លឹកឆ្នោត)	(%)
ចិន*	38.40	ចិន (មិនរាប់បញ្ចូលហុងកុងប្រទេសចិន) 34.2	32.0	28.50	0.5	1.60	34.20	35.8	25.43
		ហុងកុងប្រទេសចិន 4.2		3.50	2.5	0	4.20	4.2	2.98
ជប៉ុន	38.40		32.00		0.5	1.60	38.40	40.00	28.41
កូរ៉េ	19.20		16.00		1	1.60	19.20	20.80	14.77
បូក ៣	**96.00**		**80.00**			**4.80**	**96.00**	**100.80**	**71.59**
ឥណ្ឌូនេស៊ី	4.77		3.97		2.5	1.60	4.77	6.37	4.52
ថៃ	4.77		3.97		2.5	1.60	4.77	6.37	4.52
ម៉ាឡេស៊ី	4.77		3.97		2.5	1.60	4.77	6.37	4.52
សិង្ហបុរី	4.77		3.97		2.5	1.60	4.77	6.37	4.52
ហ្វីលីពីន	3.68		3.07		2.5	1.60	3.68	5.28	3.75
វៀតណាម	1.00		0.83		5	1.60	1.00	2.60	1.85
កម្ពុជា	0.12		0.10		5	1.60	0.12	1.72	1.22
ភូមា	0.06		0.05		5	1.60	0.06	1.66	1.18
ប្រ៊ុយណេ	0.03		0.02		5	1.60	0.03	1.63	1.16
ឡាវ PDR	0.03		0.02		5	1.60	0.03	1.63	1.16
អាស៊ាន	**24.00**		**20.00**			**16.00**	**24.00**	**40.00**	**28.41**
សរុប	**120.00**		**100.00**			**20.80**	**120.00**	**140.80**	**100.00**

តារាងកម្មវិធីទី២

ក្រុមអ្នកធ្វើសេចក្តីសម្រេចចិត្ត និង

គោលការណ៍នៃការធ្វើសេចក្តីសម្រេចរបស់ CMIM

យោងតាមបទបញ្ញត្តិនៃមាត្រា៤ ការធ្វើសេចក្តីសម្រេចនៃយន្តការ CMIM ត្រូវធ្វើឡើងដូចខាងក្រោមៈ

(១) រចនាសម្ព័ន្ធនៃការធ្វើសេចក្តីសម្រេចមានពីរថ្នាក់

ការធ្វើសេចក្តីសម្រេចដោយក្រុមអ្នកធ្វើសេចក្តីសម្រេចរបស់ CMIM ត្រូវបែងចែកជាពីរថ្នាក់ ដូចខាងក្រោមៈ

(ក) បញ្ហាគោលការណ៍សំខាន់ៗ

បញ្ហាគោលការណ៍សំខាន់ៗ ត្រូវសម្រេចដោយក្រុមអ្នកធ្វើការសម្រេចកម្រិតនយោបាយថ្នាក់រដ្ឋមន្ត្រី (MLDMB)។

ការអនុម័តនៃសេចក្តីសម្រេចណាមួយ ដែលត្រូវបានចាត់ទុកថា ជាបញ្ហាគោលការណ៍សំខាន់ ត្រូវមានប្រសិទ្ធិភាព លុះត្រាតែបញ្ហានេះត្រូវបានផ្តល់ការយល់ព្រមជាឯកច្ឆ័ន្ទ ដោយសមាជិកនៃ MLDMB ដោយមានការពិគ្រោះយោបល់ជាមុននៅក្នុង ELDMB។ បញ្ហាគោល-ការណ៍សំខាន់ៗ ចាំបាច់ត្រូវដាក់ឱ្យពិភាក្សាល្អិតល្អន់ដោយថ្នាក់ ELDMB មុននឹងដាក់អោយរដ្ឋមន្ត្រីអនុម័ត។

ដូចបានបង្ហាញនៅក្នុងតួសេចក្តីនៃកិច្ចព្រមព្រៀង CMIM បញ្ហាគោលការណ៍សំខាន់ៗ គឺជាបញ្ហាកំរិតគោលនយោបាយថ្នាក់រដ្ឋមន្ត្រី ដែលពាក់ព័ន្ធនឹងយន្តការ CMIM និងកិច្ចព្រម-ព្រៀង CMIM នេះ ដោយរាប់បញ្ចូលទាំងការពិនិត្យឡើងវិញ និងការកំណត់ថាតើ ត្រូវធ្វើការកែតម្រូវលក្ខខណ្ឌជាមូលដ្ឋាន ដូចជា ទំហំនៃយន្តការ CMIM ភាគទាន CMIM របស់ភាគី CMIM នីមួយៗ ទំហំទឹកប្រាក់អតិបរមានៃការដោះដូររូបិយប័ណ្ណដែលត្រូវអនុវត្ត ចំពោះការដកប្រាក់ និងការបន្តកិច្ចសន្យាដកប្រាក់ដែលត្រូវបានធ្វើឡើងនៅក្រោមយន្តការ CMIM លក្ខខណ្ឌនៃការចូលរួមក្នុងយន្តការ CMIM លក្ខខណ្ឌអនុញ្ញាតឱ្យចូលរួមឡើងវិញសម្រាប់សមាជិក ដែលស្វែងរកការបញ្ចូលសមាជិកភាពជាថ្មី លក្ខខណ្ឌមូលដ្ឋាននៃការលក់ និងទិញ និងការងារផ្សេងៗទៀត ដែល MLDMB ព្រមព្រៀងគ្នា កំណត់ថាជាបញ្ហាគោលការណ៍សំខាន់ៗ ដោយធ្វើការសម្រេចជាឯកច្ឆ័ន្ទ ពីពេលមួយទៅពេលមួយ។

(ខ) បញ្ហាកម្រិតប្រតិបត្តិ

បញ្ហាកម្រិតប្រតិបត្តិ ត្រូវសម្រេចដោយក្រុមអ្នកធ្វើការសំរេចថ្នាក់អនុរដ្ឋមន្ត្រី (ELDMB)។ រាល់ការសម្រេចរបស់ ELDMB ពាក់ព័ន្ធនឹងបញ្ហាកម្រិតប្រតិបត្តិ មានប្រសិទ្ធិភាពអនុវត្តបាន ប្រសិនបើមានការអនុម័តដោយសំលេងយ៉ាងតិចពីរភាគបី(២/៣) នៃសំលេងឆ្នោតប្រសិទ្ធិភាព។ សំលេងឆ្នោតសរុបរបស់ក្រសួងហិរញ្ញវត្ថុ និងធនាគារកណ្តាល ដែលតំណាងឱ្យប្រទេសនីមួយៗ នៃអាស៊ានបូកបី (ពោលគឺ ចំនួនសំលេងដែលត្រូវបានបែងចែកឱ្យប្រទេសអាស៊ានបូកបី ដូចមានក្នុងតារាងកម្មវិធីទី១) គឺត្រូវបោះឆ្នោតជាលក្ខណៈឯកភាព ហើយមិនត្រូវបំបែកពីគ្នាចំពោះបញ្ហាណាមួយឡើយ។ មុននឹងធ្វើការបោះឆ្នោតប្រតិភូមកពីប្រទេសអាស៊ានបូកបីនីមួយៗ ដែលរួមមានអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារកណ្តាល ពីប្រទេសនោះ ត្រូវមានការព្រមព្រៀងគ្នា ថាតើ សំលេងឆ្នោតឯកភាព នឹងត្រូវបោះគាំទ្រ ឬបោះជំទាស់ ចំពោះសំណើជាក់លាក់ដែលត្រូវការសម្រេច។ ដើម្បីការចៀសវាងការមន្ទិល សំលេងឆ្នោតរបស់ប្រទេសចិន និងហុងកុងនៃប្រទេសចិន ត្រូវបោះដោយឡែកពីគ្នា។

ដូចបានបង្ហាញនៅក្នុងកូសេចក្តីនៃកិច្ចព្រមព្រៀង CMIM **បញ្ហាកម្រិតប្រតិបត្តិ** គឺបញ្ហាដែលពាក់ព័ន្ធនឹង: (i) ការអនុម័តលើការដកប្រាក់សម្រាប់ភាគីស្នើសុំដោះដូររូបិយប័ណ្ណ នៅក្រោមកិច្ចព្រមព្រៀង CMIM និងយន្តការ CMIM នេះ (ii) ការអនុម័តលើការបន្តកិច្ចសន្យាដកប្រាក់ (iii) ការលើកលែងនៃលក្ខខណ្ឌដែលមានពីមុន ស្របតាមមាត្រាទី១០ និងការលើកលែងពីការសន្យាណាមួយក្រោមមាត្រាទី១១ (iv) ការប្រកាសអំពីភាពខកខាន (v) ការលើកលែងនៃភាពខកខាន និង (vi) ការអនុម័តលើការដកខ្លួនចេញស្របតាមមាត្រា ៨.១ ក្នុងលក្ខខណ្ឌដែលថា ការបោះឆ្នោតសម្រាប់បញ្ហានៅក្នុងចំណុច (i) ឬ (ii) (តាមករណីជាក់-ស្តែង) និង (vi) ត្រូវបានធ្វើឡើងនៅពេលដំណាលគ្នា ប៉ុន្តែទោះយ៉ាងណាក៏ដោយ គឺត្រូវធ្វើបន្ទាប់ពីការបោះឆ្នោតសម្រាប់បញ្ហានៅក្នុងចំណុច (iii)។

ប្រសិនបើ ការណែនាំឱ្យបោះឆ្នោតរបស់តំណាងក្រសួងហិរញ្ញវត្ថុ និងតំណាងធនាគារកណ្តាលនៃប្រទេសតែមួយ មានភាពខុសគ្នា តំណាងទាំងនោះត្រូវបានចាត់ទុកថា បានធ្វើអនុប្បវាទមិនចូលបោះឆ្នោត ប៉ុន្តែបទបញ្ញត្តិនេះមិនអនុវត្តចំពោះហុងកុង នៃប្រទេសចិនទេ។

(២). ការកោះប្រជុំ

ការកោះប្រជុំនៃ MLDMB និង ELDMB ត្រូវបានធ្វើឡើងដោយអនុលោមដូចខាងក្រោម:

(a) កិច្ចប្រជុំ MLDMB

ការប្រជុំនៃ MLDMB ត្រូវបានកោះ និងរៀបចំធ្វើ ក្នុងខែឧសភាជារៀងរាល់ឆ្នាំ ហើយការប្រជុំបន្ថែមនៃ MLDMB អាចត្រូវបានកោះនៅពេលដែលសមាជិកនៃ MLDMB កំណត់ថា មានភាពចាំបាច់ និង/ឬ ចង់ឱ្យមានការប្រជុំ។

(៦) កិច្ចប្រជុំនៃ ELDMB

ទោះជាការប្រជុំទល់មុខក្តី ការប្រជុំក្នុងទម្រង់ជាសន្និសីទតាមទូរគមនាគមន៍ក្តី ឬការប្រជុំដែលធ្វើឡើងដោយការប្តូរគ្នានូវសារគមនាគមន៍ជាលាយលក្ខអក្សរក្តី នោះកិច្ចប្រជុំ ELDMB ត្រូវបានកោះ នៅពេលមាន និងតាមការស្នើសុំរបស់បណ្តាប្រទេសសម្របសម្រួលដែលពាក់ព័ន្ធ ដើម្បីរៀបចំដំណើរការធ្វើសេចក្តីសម្រេចណាមួយ ដែល ELDMB ត្រូវធ្វើ ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង CMIM នេះ។

(៣) ទម្រង់នៃកិច្ចប្រជុំ

រាល់ការសម្រេចដែលធ្វើឡើងដោយ MLDMB ពាក់ព័ន្ធនឹងបញ្ហាគោលការណ៍សំខាន់ៗ ត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំទល់មុខ។

ជាគោលការណ៍ ការសម្រេចដែលត្រូវបានធ្វើឡើងដោយ ELDMB ពាក់ព័ន្ធនឹងបញ្ហាកម្រិតប្រតិបត្តិ គួរធ្វើឡើងនៅក្នុងកិច្ចប្រជុំទល់មុខគ្នា។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើប្រទេសអាស៊ានបូកបីមួយ ឬច្រើន ពិនិត្យឃើញថា ខ្លួនមិនអាចមានលទ្ធភាព ឬមានការពិបាកក្នុងការបញ្ជូន ឬរៀបចំឱ្យតំណាងឱ្យចូលរួមការប្រជុំនោះ បណ្តាប្រទេសសម្របសម្រួលអាចរៀបចំឱ្យមានកិច្ចប្រជុំពាក់ព័ន្ធនៃ ELDMB ដោយសន្និសីទទូរគមនាគមន៍ និង/ឬ រៀបចំការងារពាក់ព័ន្ធដែលត្រូវស្នើឡើង ដាក់ឱ្យពិភាក្សា និងដាក់ឱ្យបោះឆ្នោតជាលាយល័ក្ខអក្សរ។

តារាងកម្មវិធីទី៣

ទម្រង់លិខិតសន្យា

ក្បាលលិខិតរបស់ធនាគារកណ្តាលពាក់ព័ន្ធ

លិខិតសន្យារបស់

(ឈ្មោះធនាគារកណ្តាលពាក់ព័ន្ធ)

(កាលបរិច្ឆេទ)

ដោយយោងតាមកិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ ចុះថ្ងៃទី (...) (តទៅនេះហៅថា "កិច្ចព្រមព្រៀង CMIM") លិខិតនេះគឺជាការអះអាងបញ្ជាក់ថា (ឈ្មោះរបស់ធនាគារកណ្តាលពាក់ព័ន្ធ) សន្យារួមភាគទានទូវចំនួនទឹកប្រាក់សរុបរហូតដល់[2] (បញ្ចូលចំនួនទឹកប្រាក់ភាគទាន CMIM សរុប) ដុល្លារ រួមជាមួយធនាគារកណ្តាលផ្សេងទៀតនៃប្រទេសអាស៊ានបូកបី និងហុងកុងនៃប្រទេសចិន តាមសំណើរបស់ភាគីនីមួយៗ ក្រោមកិច្ចព្រមព្រៀង CMIM។ ការសន្យារបស់ (ឈ្មោះរបស់ធនាគារកណ្តាលពាក់ព័ន្ធ) ត្រូវបង់តាមលក្ខខណ្ឌដូចខាងក្រោម៖

(A) សំណើសុំដោះដូររូបិយប័ណ្ណសម្រាប់ការដកប្រាក់ និងការបន្តកិច្ចសន្យាដកប្រាក់ ត្រូវបានអនុម័តតាមរបៀបដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង CMIM និង

(B) ការធ្វើវិភាជនីនៃចំនួនទឹកប្រាក់ដែលបានសន្យា សម្រាប់ប្រតិបត្តិការដោះដូររូបិយប័ណ្ណនីមួយៗ ត្រូវបានសម្រេចដោយផ្អែកលើមូលដ្ឋានសមាមាត្រ ស្របតាមការសន្យារបស់ (ឈ្មោះធនាគារកណ្តាលពាក់ព័ន្ធ) ទាក់ទងនឹងទំហំទឹកប្រាក់សរុបនៃយន្តការ CMIM នៅក្រោមកិច្ចព្រមព្រៀង CMIM។

លុះត្រាតែមានការកំណត់ផ្សេង វាក្យស័ព្ទដែលសរសេរជាអក្សរពុម្ពប្រើនៅទីនេះ មានអត្ថន័យជាធម្មតា នៅក្នុងកិច្ចព្រមព្រៀង CMIM។

---

[2] កំណត់ពន្យល់៖ ដើម្បីជៀសវាងការមន្ទិល ការប្រើឃ្លា "រហូតដល់" បង្ហាញថា ចំនួនទឹកប្រាក់នៃការរួមភាគទានហិរញ្ញវត្ថុសរុបដែលបានបង្ហាញសម្រាប់ប្រទេសនីមួយៗក្នុងតារាងកម្មវិធីទី១ គឺជាចំនួនទឹកប្រាក់អតិបរមា ហើយចំនួនទឹកប្រាក់ជាក់ស្តែងដែលរួមភាគទានដោយធនាគារកណ្តាល ដែលពាក់ព័ន្ធ និងដែលនៅមានសុពលភាព អាចមានចំនួនតិចជាងចំនួនទឹកប្រាក់នៃការរួមភាគទានហិរញ្ញវត្ថុសរុបអតិបរមារបស់ប្រទេសដែលពាក់ព័ន្ធ ឬហុងកុង ក្នុងកម្រិតដែលថា ចំនួនទឹកប្រាក់នៃសំណើសុំដោះដូររូបិយប័ណ្ណ ដែលគេត្រូវផ្តល់ឱ្យ និងដែលនៅមានសុពលភាពមានចំនួនតិចជាងចំនួនទឹកប្រាក់ភាគទាន CMIM សរុប។

លិខិតសន្យានេះ ត្រូវបានគ្រប់គ្រង និងបង្កើតឡើង ស្របតាមច្បាប់នៃប្រទេសអង់គ្លេស និងត្រូវចូលជាធរមាននៅ (កាលបរិច្ឆេទ) និងនៅតែមានប្រសិទ្ធិភាព ដរាបណាកិច្ចព្រម-ព្រៀង CMIM នៅជាធរមាន ហើយ (ឈ្មោះធនាគារកណ្តាលពាក់ព័ន្ធ) គឺជាភាគីនៃកិច្ច-ព្រមព្រៀង CMIM។

(ហត្ថលេខារបស់ធនាគារកណ្តាលពាក់ព័ន្ធ)

តារាងកម្មវិធីទី៤
ការកំណត់អត្រាប្តូរប្រាក់បរទេស

អត្រាប្តូរប្រាក់នៃរូបិយប័ណ្ណដុល្លារអាមេរិក ធៀបនឹងរូបិយប័ណ្ណក្នុងស្រុក ដែលអាចអនុវត្តចំពោះការគណនាស្ថានភាពរូបិយប័ណ្ណក្នុងស្រុក សម្រាប់ការដកប្រាក់ដាក់លាក់ណាមួយ ក៏ដូចជាការបន្តកិច្ចសន្យាដកប្រាក់នីមួយៗ និងសម្រាប់គណនាការទូទាត់សងផ្សេងទៀតដែលទាក់ទងនឹង ឬដែលកើតឡើងចេញពីការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ណាមួយ ត្រូវកំណត់ដោយភាគីផ្តល់ការដោះដូររូបិយប័ណ្ណពាក់ព័ន្ធ ដោយផ្អែកលើនៃអត្រាប្តូរប្រាក់ដែលផ្តល់ដោយទីភ្នាក់ងារ Reuters (ដូចបង្ហាញនៅលើទំព័រ សម្រាប់រូបិយប័ណ្ណក្នុងស្រុកពាក់ព័ន្ធ) ឬផ្តល់ដោយប្រភពនៃអត្រាប្តូរប្រាក់ផ្សេងទៀតដូចខាងក្រោម ដែលត្រូវបានផ្សាយរយៈពេលពីរ (២)ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទកំណត់អត្រាការប្រាក់នៃការដកប្រាក់ ឬការបន្តកិច្ចសន្យាដកប្រាក់ដែលពាក់ព័ន្ធ។ ទំព័រ និងផ្ទាំងពត៌មាននៃសារពត៌មាន Reuters ដែលពាក់ព័ន្ធសម្រាប់រូបិយប័ណ្ណក្នុងស្រុកនីមួយៗ មានបង្ហាញដូចខាងក្រោមៈ

ប្រ៊ុយណេដារុសសាឡាំៈ

រូបិយប័ណ្ណៈ ដុល្លារប្រ៊ុយណេ (BND)

ទំព័រៈ សេវា Bloomberg – WCV – Brunei Spot (BND CRNCY HP <GO>)

ផ្ទាំងពត៌មានបង្ហាញនៅម៉ោងៈ ៧:០០ ព្រឹក ម៉ោងនៅប្រ៊ុយណេដារុសសាឡាំ

កម្ពុជាៈ

រូបិយប័ណ្ណៈ រៀល (KHR)

ទំព័រៈ www.nbc.org.kh (NBC ផ្សាយ)

ផ្ទាំងពត៌មានបង្ហាញនៅម៉ោងៈ (ពេលវេលា)

ឥណ្ឌូនេស៊ីៈ

រូបិយប័ណ្ណៈ Rupiah (IDR)

ទំព័រៈ ទំព័រ BIXY របស់ Reuter

ផ្ទាំងពត៌មានបង្ហាញនៅម៉ោងៈ ១២:០០ រសៀល ម៉ោងនៅហ្សាកាតា

សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ:

រូបិយប័ណ្ណ: គីប (LAK)

ទំព័រ: ទំព័រ Reuter LABOL01

ថ្លៃងពត៌មានបង្ហាញនៅម៉ោង: ៩:០០ ព្រឹក ម៉ោងនៅវៀងច័ន្ទ

ម៉ាឡេស៊ី:

រូបិយប័ណ្ណ: រីងហ្គីត (RM) (MYR)

ទំព័រ: ទំព័រ MYRFIX2 របស់ Reuter

ថ្លៃងពត៌មានបង្ហាញនៅម៉ោង: ១១:០០ ព្រឹក ម៉ោងនៅម៉ាឡេស៊ី

មីយ៉ាន់ម៉ា:

រូបិយប័ណ្ណ: ក្យ៉ាត [(K) (mmk)]

ទំព័រ: ទំព័រ MFTB របស់ Reuter

ថ្លៃងពត៌មានបង្ហាញនៅម៉ោង: ៩:០០ ព្រឹក

ហ្វីលីពីន:

រូបិយប័ណ្ណ: ប៉េសូ (PHP)

ទំព័រ: ទំព័រ PDSPES01 របស់ Reuter

ថ្លៃងពត៌មានបង្ហាញនៅម៉ោង : ៩:០០ ព្រឹក

សិង្ហបុរី:

រូបិយប័ណ្ណ: ដុល្លារសង្ហបុរី (SGD)

ទំព័រ: ទំព័រ ABSIRFIX01 របស់ Reuter

ថ្លៃងពត៌មានបង្ហាញនៅម៉ោង : ១១:០០ ព្រឹក ម៉ោងនៅសិង្ហបុរី

ថៃឡង់ដ៍:

រូបិយប័ណ្ណ: បាត (THB)

ទំព័រ: ទំព័រ THBFIX=TH របស់ Reuter

(អត្រា Spot មធ្យម ត្រូវបានកំណត់ដោយការកាត់ចោលនូវអត្រាខ្ពស់បំផុតចំនួន២៥% អត្រាទាបបំផុតចំនួន ២៥% ហើយធ្វើមធ្យមភាគទៅលើអត្រា Spot ដែលនៅសល់ ដែលដកស្រង់ដោយធនាគារចូលរួម នៅចន្លោះម៉ោង ១០:០០-១១:៤៥ព្រឹក ម៉ោងនៅបាងកក)
ផ្ទាំងពត៌មានបង្ហាញនៅម៉ោង: ១១:០០ ព្រឹក (ម៉ោងនៅបាងកក)

វៀតណាម:
រូបិយប័ណ្ណ: ដុង (VND)
ទំព័រ: ទំព័រ SBOV របស់ Reuter
ផ្ទាំងពត៌មានបង្ហាញនៅម៉ោង: ៩:២០ ព្រឹក

សាធារណរដ្ឋប្រជាមានិតចិន:
រូបិយប័ណ្ណ: Yuan/Renminbi [(RMB) (CNY)]
ទំព័រ: ទំព័រ SAEC របស់ Reuter
ផ្ទាំងពត៌មានបង្ហាញនៅម៉ោង: ១១:០០ ព្រឹក ម៉ោងនៅប៉េកាំង

ហុងកុងនៃប្រទេសចិន:
រូបិយប័ណ្ណ: ដុល្លារហុងកុង (HKD)
ទំព័រ: ទំព័រ HKDFIX= របស់ Reuter
(ការកំណត់ប្រចាំថ្ងៃ ផ្តល់ឱ្យដោយសមាគមទីផ្សាររតនាគារ (Treasury Market Association))
ផ្ទាំងពត៌មានបង្ហាញនៅម៉ោង: ១១:១៥ ព្រឹក ម៉ោងនៅហុងកុង

ជប៉ុន:
រូបិយប័ណ្ណ: យ៉េន (JPY)
ទំព័រ: ទំព័រ TTSB=J របស់ Reuter
(មធ្យមភាគនៃអត្រាទិញ និងអត្រាលក់ ដែលត្រូវបានគណនាដោយកាត់ក្បៀស ២ខ្ទង់)
ផ្ទាំងពត៌មានបង្ហាញនៅម៉ោង: ១១:០០ ព្រឹក ម៉ោងនៅតូក្យូ

<u>*សាធារណវត្ថុយ៉ះ*</u>

រូបិយប័ណ្ណៈ គូរៀនវ៉ុន (KRW)

ទំព័រៈ ទំព័រ KFTC18 របស់ Reuter

(អត្រាមធ្យមនៃទីផ្សារ (market weighted average rate) ផ្តល់ដោយ ក្រុមហ៊ុនសេវាជើងសាររូបិយវត្ថុទីក្រុងសេអ៊ូល , (Seoul Money Brokerage Services, Ltd))

ផ្ទាំងពត៌មានបង្ហាញនៅម៉ោងៈ ៩:០០ ព្រឹក ម៉ោងនៅសេអ៊ូល

ឧបសម្ព័ន្ធទី៥

ទម្រង់នៃលិខិតទទួលស្គាល់របស់រដ្ឋាភិបាល

(ក្បាលលិខិតរបស់ក្រសួងនៃរដ្ឋាភិបាលដែលពាក់ព័ន្ធ)

(កាលបរិច្ឆេទ)

(ពត៌មានទំនាក់ទំនង)

(ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ)

គោរពជូន (..)

លិខិតនេះ យោងដល់កិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (កិច្ចព្រមព្រៀង CMIM) ចុះថ្ងៃទី(....) ដែល(ឈ្មោះរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) ជាភាគីមួយ។ ពាក្យសរសេរជាអក្សរពុម្ពដែលប្រើប្រាស់នៅទីនេះដោយគ្មានកំណត់និយមន័យ ត្រូវមានអត្ថន័យដូចការកំណត់ក្នុងកិច្ចព្រមព្រៀង CMIM។

ដោយយោងតាមមាត្រា១០.១.១ នៃកិច្ចព្រមព្រៀង CMIM លិខិតនេះមានបំណងបញ្ជាក់អំពីការគាំទ្ររបស់រដ្ឋាភិបាលនៃ (ប្រទេស/តំបន់ផ្តល់ការដោះដូររូបិយប័ណ្ណ) ចំពោះ (ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) ដែលចុះកិច្ចសន្យាធ្វើប្រតិបត្តិការដោះដូររូបិយប័ណ្ណទ្វេភាគីនៅក្រោមកិច្ចព្រមព្រៀង CMIM។

តាមរយៈនេះ ខ្ញុំសូមបញ្ជាក់ថារដ្ឋាភិបាលនៃ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ត្រូវចាត់រាល់វិធានការណ៍ចាំបាច់ និងត្រឹមត្រូវ ដោយមានការសម្របសម្រួលជាមួយ (ភាគីស្នើសុំដោះដូររូបិយប័ណ្ណ) ដើម្បីអាចឱ្យ (ភាគីស្នើសុំដោះដូររូបិយប័ណ្ណ) អនុវត្តតាមកាតព្វកិច្ចរូបិយវត្ថុដែលនៅមានសុពលភាពទាំងអស់របស់ខ្លួន ស្របតាមប្រតិបត្តិការដោះដូររូបិយប័ណ្ណទ្វេភាគី នៅក្រោមកិច្ចព្រមព្រៀងCMIM។

ដោយការគោរពដ៏ខ្ពង់ខ្ពស់

(តំណាងមានសិទ្ធិ ថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុក

ឬថ្នាក់ខ្ពស់ជាង)

ភាពវាងកម្មវិធីទី៦

ទម្រង់លិខិតសន្យារបស់រដ្ឋាភិបាល

លិខិតសន្យារបស់រដ្ឋាភិបាលនៃ

(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)

(ក្បាលលិខិតនៃក្រសួងរបស់រដ្ឋាភិបាលពាក់ព័ន្ធ)

(កាលបរិច្ឆេទ)

(ព័ត៌មានទំនាក់ទំនង)

(ភាគីផ្តល់កិច្ចព្រមព្រៀងដោះដូររូបិយប័ណ្ណ)

គោរពជូន (.....)

លិខិតនេះ យោងដល់កិច្ចប្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (កិច្ចព្រមព្រៀង CMIM) ចុះថ្ងៃទី(....) ដែល(ឈ្មោះរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) ជាភាគីមួយនៃកិច្ចព្រមព្រៀងនេះ។ ពាក្យសរសេរជាអក្សរពុម្ពដែលប្រើប្រាស់នៅទីនេះ មិនមានកំណត់និយមន័យ ត្រូវមានអត្ថន័យដូចការកំណត់ក្នុងកិច្ចព្រមព្រៀង CMIM។

ដោយយោងតាមមាត្រា១០.១.២ នៃកិច្ចព្រមព្រៀង CMIM រដ្ឋាភិបាលនៃ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) (ហៅថា "រដ្ឋាភិបាល") យល់ព្រមដូចតទៅនេះ ថា:

(A) ដរាបណាដែលកាតព្វកិច្ចរូបិយវត្ថុរបស់ (ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) នៅក្រោមកិច្ចព្រមព្រៀង CMIM នៅមានសុពលភាព រដ្ឋាភិបាលនឹងមិនដាក់ការត្រិះពិនិត្យលើលំហូរចេញនៃមូលធន ដែលអាចធ្វើឱ្យមានការរាំងស្ទះចំពោះការអនុវត្តកាតព្វកិច្ចរូបិយវត្ថុណាមួយនៅក្រោមកិច្ចព្រមព្រៀង CMIM ដោយ(ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) លើកលែងតែបានផ្តល់ក្នុងកម្មវិធីដែលត្រូវបានយល់ព្រមរវាងរដ្ឋាភិបាល និងមូលនិធិរូបិយវត្ថុអន្តរជាតិ ("IFM")។

(B) ដរាបណាដែលកិច្ចព្រមព្រៀង CMIM នៅជាធរមាន រដ្ឋាភិបាលត្រូវអនុវត្តតាមកម្មវិធី IMF (ដូចបានកំណត់ក្នុងកិច្ចព្រមព្រៀង CMIM) ប្រសិនបើកម្មវិធី IMF នោះ នៅមានអត្ថិភាព។

(C) ដរាបណាដែលកិច្ចព្រមព្រៀង CMIM នៅជាធរមាន រដ្ឋាភិបាលត្រូវចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពីគោលនយោបាយ និងការពិនិត្យឡើងវិញនៃសេដ្ឋកិច្ចអាស៊ានបូកបី

ដោយគោរពដ៏ខ្ពង់ខ្ពស់

(តំណាងមានសិទ្ធិ ថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុក

ឬថ្នាក់ខ្ពស់ជាង)

ឧបសម្ព័ន្ធទី៧

ទម្រង់នៃការផ្តល់មតិផ្នែកច្បាប់

ការផ្តល់មតិផ្នែកច្បាប់របស់ (ក្រសួងពាក់ព័ន្ធ) នៃ

(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)

(ក្បាលលិខិតនៃក្រសួងពាក់ព័ន្ធនៃតំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)

(កាលបរិច្ឆេទ)

(ពត៌មានទំនាក់ទំនង)

(ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ)

គោរពជូន (...)

លិខិតនេះ យោងដល់កិច្ចព្រមព្រៀងពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ(កិច្ចព្រមព្រៀង CMIM) ចុះថ្ងៃទី (....) ដែល (ឈ្មោះរបស់ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) ជាភាគីមួយនៃកិច្ចព្រមព្រៀងនេះ។

ពាក្យសរសេរជាអក្សរពុម្ពដែលប្រើប្រាស់នៅទីនេះដោយគ្មានកំណត់និយមន័យ ត្រូវមានអត្ថន័យដូចការកំណត់ក្នុងកិច្ចព្រមព្រៀង CMIM។

ខ្ញុំជា( ) នៃ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) និងបានដើរតួជាទីប្រឹក្សាឱ្យ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ទាក់ទងនឹងការអនុវត្ត និងការទទួលស្គាល់នៃកិច្ចព្រមព្រៀង CMIM ដោយ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)។

ខ្ញុំបានពិនិត្យលើចំណុចដូចខាងក្រោម រួមទាំងចំណុចផ្សេងៗទៀតផងដែរ:

(១) រដ្ឋធម្មនុញ្ញនៃ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ដែលនៅជាធរមាននៅត្រឹមថ្ងៃចេញលិខិតនេះ (ហៅថា "រដ្ឋធម្មនុញ្ញ")

(២) ច្បាប់ បទបញ្ញត្តិ និង ឯកសារនានា ដែលខ្ញុំគិតថា មានភាពចាំបាច់ ឬត្រូវមាន និង

(៣) កិច្ចព្រមព្រៀង CMIM។

ដោយផ្អែកលើការពិនិត្យមើលនេះ ខ្ញុំមានមតិ ដូចខាងក្រោម:

(A) (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណរូបិយប័ណ្ណ) មានសិទ្ធិអំណាចពេញលេញ (i) ដើម្បីបំពេញកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀង CMIM (ii) ដើម្បីអនុវត្ត និងទទួលស្គាល់

កិច្ចព្រមព្រៀង CMIM (iii) ដើម្បីអនុវត្តតាមបទបញ្ញត្តនៃកិច្ចព្រមព្រៀង និង (iv) ដើម្បីអនុវត្តកាតព្វកិច្ចដែលត្រូវបានបង្ហាញថាជាចំណងចំពោះ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ក្នុងកិច្ចព្រមព្រៀង CMIM។

(B) កិច្ចព្រមព្រៀង CMIM ត្រូវបានអនុវត្ត និងទទួលស្គាល់យ៉ាងត្រឹមត្រូវដោយ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) និងបង្កើតនូវកាតព្វកិច្ចដែលមានលក្ខណៈស្របច្បាប់ មានសុពលភាព និងមានចំណង ដល់(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ដែលកាតព្វកិច្ចនេះមានលក្ខណៈបង្ខំឱ្យអនុវត្តដោយអនុលោមតាមលក្ខខណ្ឌរបស់កិច្ចព្រមព្រៀង ហើយកាតព្វកិច្ចហិរញ្ញវត្ថុរបស់ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) នៅក្រោមកិច្ចព្រមព្រៀងនេះ គឺជា និង នឹងបង្កើតជា ភាពជាប់បំណុលទូទៅផ្ទាល់និងគ្មានលក្ខខណ្ឌ ដល់(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ហើយកាតព្វកិច្ចហិរញ្ញវត្ថុនោះនឹងមានចំណាត់ថ្នាក់យ៉ាងហោចណាស់ស្មើគ្នានឹងបំណុលទូទៅផ្ទាល់ និងគ្មានលក្ខខណ្ឌ ហើយមានកម្រិតខ្ពស់ និងគ្មានការធានា ដែល(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)មាន នាពេលបច្ចុប្បន្ន ឬក្នុងពេលអនាគត។

(C) ក្នុងគោលបំណងដើម្បីធ្វើឱ្យគ្រប់កាតព្វកិច្ចទាំងអស់របស់ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ក្រោមកិច្ចព្រមព្រៀងនេះ មានសុពលភាព មានចំណង និងមានលក្ខណៈបង្ខំឱ្យអនុវត្ត ដោយអនុលោមតាមលក្ខខណ្ឌពាក់ព័ន្ធនីមួយៗ នោះរាល់ការអនុញ្ញាត និងការសម្រេចនានារបស់រដ្ឋាភិបាលដែលតម្រូវឱ្យមានសម្រាប់ ឬទាក់ទងនឹងការអនុវត្ត ការទទួលស្គាល់ និងការធ្វើឱ្យបានសម្រេចនៃកិច្ចព្រមព្រៀង CMIM ត្រូវបានធ្វើឡើងដោយអនុវត្តយ៉ាងត្រឹមត្រូវ និងតឹងរ៉ឹង ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ដែលពាក់ព័ន្ធរបស់(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) និងស្របតាមកិច្ចព្រមព្រៀង បទបញ្ញត្តិ ឬលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនានា ដែលនៅជាធរមាន និងមានប្រសិទ្ធិភាពអនុវត្តពេញលេញ។

(D) ការអនុវត្ត និងការទទួលស្គាល់នៃកិច្ចព្រមព្រៀង CMIM ការធ្វើឱ្យបានសម្រេចដោយ (តំបន់/ប្រទេសស្នើសុំដោះដូររូបិយប័ណ្ណ) ចំពោះកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រម-ព្រៀងនេះ និងការអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងដោយ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ត្រូវបានផ្តល់ការអនុញ្ញាតយ៉ាងត្រឹមត្រូវតាមរយៈការចាត់គ្រប់វិធានការណ៍ដែលចាំបាច់ទាំងអស់របស់(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) និង មិន ហើយនឹងមិនៈ

(i) បំពានបទបញ្ញត្តនៃរដ្ឋធម្មនុញ្ញ ឬច្បាប់ វិធាន បទបញ្ញត្តិ បទបញ្ជា សេចក្តីវិនិច្ឆ័យ ក្រឹត្យ ដំណោះស្រាយ ការកំណត់ ឬការសម្រេចដោយ តុលាការ ឬអាជ្ញាធរ

ផ្នែកច្បាប់ រដ្ឋបាល ឬរដ្ឋាភិបាល ឬស្ថាប័នមានសមត្ថកិច្ចចំពោះ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ឬ

(ii) មានទំនាស់ ឬមានអសង្គតិភាពជាមួយ ឬនាំឱ្យមានការបំពានលើលក្ខខណ្ឌ ការសន្យា បទបញ្ញត្ត ការបង្កើតឱ្យមានភាពខកខាន នៃកិច្ចព្រមព្រៀងណាមួយ ឬ កិច្ចសន្យាផ្សេងទៀត យន្តការ ឬកាតព្វកិច្ចនៃយន្តការនោះដែល (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) គឺជាភាគីមួយ ឬតាមរយៈយន្តការនោះ ភាគី ឬទ្រព្យសម្បត្តិ ទ្រព្យសកម្ម ឬចំណូលរបស់ភាគីអាចមានចំណាង ឬប៉ះពាល់។

(E) មន្ត្រីនៃ(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ដែលអនុវត្តកិច្ចព្រមព្រៀង CMIM និង គ្រប់ប្រតិវេទន៍ និងឯកសារផ្សេងទៀត ដែលតម្រូវឱ្យមានក្រោម ឬមានការពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ ត្រូវបានផ្តល់ការអនុញ្ញាតយ៉ាងពេញលេញ ដើម្បីអនុវត្តកិច្ចព្រមព្រៀង ប្រតិវេទន៍ និងឯកសារទាំងនោះ សម្រាប់ និងក្នុងនាម (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)។

(F) គ្មានព្រឹត្តិការណ៍ខកខាន ឬព្រឹត្តិការណ៍ផ្សេងទៀតដែលនឹងបង្កើតជាព្រឹត្តិការណ៍ខកខាន (ដោយមានការផ្តល់និវេទន៍ និង/ឬ ដោយពេលវេលាកន្លងផុត) បានកើតឡើង និងកំពុងបន្ត ដោយមិនបានចាត់វិធានការណ៍ដោះស្រាយឡើយ ហើយក៏គ្មានព្រឹត្តិការណ៍ខកខាន ឬព្រឹត្តិការណ៍ផ្សេងទៀតដូចបានលើកឡើង នឹងកើតចេញពីការចាត់វិធានការណ៍ក្រោមកិច្ចព្រម-ព្រៀង CMIM និងក្រោមកិច្ចព្រមព្រៀងផ្សេងទៀតដែល(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) បានអនុវត្ត។

(G) គ្មានបណ្តឹង ឬ បណ្តឹងរដ្ឋបាលឬមជ្ឈត្តកម្មណាមួយ កំពុងដំណើរការ ឬ កំពុងរង់ចាំការបាត់ការ នៅតុលាការ សាលាក្តី មជ្ឈត្តករ ឬអាជ្ញាធររដ្ឋាភិបាលឡើយ ឬតាមការយល់ដឹងរបស់ខ្ញុំ បណ្តឹងទាំងនោះគ្មានការគំរាមកំហែងចំពោះ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ឬគ្មានការគំរាមកំហែងចំពោះទ្រព្យសម្បត្តិ ទ្រព្យសកម្ម ឬចំណូល របស់ខ្លួន ដែលនឹងប៉ះពាល់យ៉ាងខ្លាំងដល់លទ្ធភាពរបស់(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងCMIM។

(H) (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) គឺមិនមានភាពខកខាន ដូចបានយោងក្នុងកថាខណ្ឌ (D)(i) នៃការផ្តល់មតិនេះ ហើយក៏មិនមានភាពខកខាន ដូចបានយោងក្នុងកថាខណ្ឌ (D)(ii) នៃការផ្តល់មតិនេះដែរ ដែលក្នុងករណីណាមួយក៏ដោយ គឺជាភាពខកខានដែលអាចមានផលអាក្រក់ទៅលើទ្រព្យសម្បត្តិ ទ្រព្យសកម្ម ចំណូល ឬលក្ខខណ្ឌហិរញ្ញវត្ថុរបស់(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ឬលើលទ្ធភាពរបស់(តំបន់/ប្រទេសស្នើសុំ

ការដោះដូររូបិយប័ណ្ណ) ក្នុងការអនុវត្តយ៉ាងត្រឹមត្រូវ និងការសង្កេតចំពោះកាតព្វកិច្ចរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀង CMIM។

(I) (ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ) ត្រូវបានផ្តល់ការអនុញ្ញាតយ៉ាងត្រឹមត្រូវ ដើម្បីអនុវត្តតាមលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា១១ នៃកិច្ចព្រមព្រៀង CMIM ក្នុងនាម (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)។

(J) មិនមានភាពចាំបាច់ ដើម្បីធានាឱ្យបាននូវ នីត្យានុកូលភាព សុពលភាព ភាពអាចអនុវត្តបាន ឬភាពអាចទទួលយកបាន នៃកិច្ចព្រមព្រៀង CMIM នៅក្នុង (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ដែលកិច្ចព្រមព្រៀង CMIM នេះ ឬឯកសារផ្សេងទៀត ត្រូវបានតំកល់ទុក កត់ត្រា ឬចុះបញ្ជីទុក នៅតុលាការ ឬអាជ្ញាធរ នៅក្នុង (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) នោះទេ ឬដែលពន្ធប្រថាប់ត្រា ពន្ធចុះបញ្ជី ឬពន្ធប្រហាក់-ប្រហែល ត្រូវបានទូទាត់ ទាក់ទងនឹងកិច្ចព្រមព្រៀង ឬឯកសារទាំងនោះ។

យោបល់នេះត្រូវបានកម្រិតត្រឹមកិច្ចការនៃច្បាប់របស់ (តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ) ហើយខ្ញុំមិនធ្វើការទាមទារដើម្បីផ្តល់មតិចំពោះសំណួរណាមួយដែលកើតឡើងក្រោមច្បាប់នៃយុត្តាធិការណាមួយ ក្រៅពី(តំបន់/ប្រទេសស្នើសុំការដោះដូររូបិយប័ណ្ណ)នេះទេ។ ក្រៅពី(ភាគីផ្តល់ការដោះដូររូបិយប័ណ្ណ) បុគ្គលផ្សេងអាចមិនមានការទុកចិត្តលើមតិនេះទេ។

ដោយគោរពដ៏ខ្ពង់ខ្ពស់

(ឈ្មោះ)

(   ) នៃ (តំបន់/ប្រទេសស្នើសុំការ

ដោះដូររូបិយប័ណ្ណ)

តារាងកម្មវិធីទី៨

គំនូសបំព្រួញសង្ខេប

ប្រតិវេទន៍អំពីសំណើសុំការដោះដូររូបិយប័ណ្ណ ជូនទៅបណ្តាប្រទេសសម្របសម្រួល (មាត្រា៥.២.១)

↓

បណ្តាប្រទេសសម្របសម្រួលបញ្ជូនប្រតិវេទន៍អំពីសំណើសុំការដោះដូររូបិយប័ណ្ណនេះ ក្នុងរយៈពេលពីរថ្ងៃ (នៃថ្ងៃធ្វើការ) (មាត្រា៥.២.១)

↓

ធ្វើការសម្របសម្រួល ពីពេលមួយទៅពេលមួយ (មាត្រា៥.២.២)

↓

បណ្តាប្រទេសសម្របសម្រួល កោះប្រជុំដើម្បីបោះឆ្នោតសម្រេច (មាត្រា៥.២.៣)

↓

ការបោះឆ្នោតត្រូវធ្វើក្នុងរយៈពេលមួយសប្តាហ៍/ពីរសប្តាហ៍ (មាត្រា៧.១.៣)
ចំពោះប្រតិវេទន៍អំពីសំណើសុំការដោះដូររូបិយប័ណ្ណ និងចំពោះដកខ្លួនចេញក្រោមមាត្រា៨.១
និងការលើកលែងលក្ខខណ្ឌមានពីមុនក្រោមមាត្រា១០.៤ (ប្រសិនបើមាន)

↓

បណ្តាប្រទេសសម្របសម្រួល ត្រូវជូនដំណឹងបន្ទាន់អំពីលទ្ធផលនៃការបោះឆ្នោត
លទ្ធផលនៃវិភាជន៍ និងការណែនាំអំពីការអនុវត្តការដោះដូររូបិយប័ណ្ណ (មាត្រា៥.២.៣)

↓

អនុវត្តនីការដោះដូររូបិយប័ណ្ណទ្វេភាគី ក្នុងរយៈពេលមួយសប្តាហ៍ (មាត្រា៥.៣.២ និង៧.១.២)
(*រយៈពេលមួយសប្តាហ៍នេះ ត្រូវរាប់បញ្ចូលនូវរយៈពេលនៃការធ្វើប្រតិវេទន៍ ដូចខាងក្រោម)

ភាគីស្នើសុំការដោះដូររូបិយប័ណ្ណ ប្រតិវេទន៍សម្រាប់ការដកប្រាក់/ការបន្តកិច្ចសន្យាដកប្រាក់
ត្រូវធ្វើមុនរយៈពេល ៣ ថ្ងៃនៃថ្ងៃធ្វើការ (មាត្រា៧.៣.១/៧.៣.២)

កាលបរិច្ឆេទកំណត់ការប្រាក់ - កាលបរិច្ឆេទដកប្រាក់ / ការបន្តកិច្ចសន្យាដកប្រាក់ (មាត្រា៧.២.៣)
ការកំណត់អត្រាប្តូរប្រាក់ ត្រូវធ្វើក្នុងរយៈពេល ២ ថ្ងៃនៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទកំណត់ការប្រាក់
(មាត្រា៧.២.២(ខ)/ ៧.៣.២(ខ))

ការកំណត់អត្រាការប្រាក់ ត្រូវធ្វើក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការនៅទីក្រុងឡុងដ៏
មុនកាលបរិច្ឆេទកំណត់ការប្រាក់ (មាត្រា៧.២.៤)

ប្រតិវេទន៍នៃការដកខ្លួន (មាត្រា៨.១ ឬ ៨.២)

ដោយមានការផ្លាស់ប្តូរដ៏ចាំបាច់ត្រូវបានធ្វើឡើង នោះត្រូវអនុវត្តបាន ចំពោះការបន្តកិច្ចសន្យាដកប្រាក់ (មាត្រា៧.៣.២(ខ))

តារាងកម្មវិធីទី៩
ពត៌មានទំនាក់ទំនងសម្រាប់ការជូនដំណឹង

ប្រ៊ុយណេដារ៉ុសសាឡាំ

សម្រាប់ធនាគារកណ្តាលៈ

Attn: Chief Executive Officer, Brunei Currency and Monetary Board
Address: Ministry of Finance, Bandar Seri Begawan, BB3910, Brunei Darussalam.

Fax: +673 2 382232

Swift: N/A

សម្រាប់ក្រសួងហិរញ្ញវត្ថុៈ

Attn: Director, Research and International Division
Address: Ministry of Finance, Bandar Seri Begawan, BB3910, Brunei Darussalam

Fax: +673 2 383854

Swift: N/A

កម្ពុជាៈ

សម្រាប់ធនាគារកណ្តាលៈ

Attn: Ms. Nguon Sokha, Deputy Director General
Address: P.O Box 25 or 22-24 Preah Norodom Blvd, Phnom Penh, Cambodia

Fax: 855-23 426-117

Swift:

សម្រាប់ក្រសួងហិរញ្ញវត្ថុៈ

Attn: Mr. Ly Se, First Deputy Director,
Department of Economic Integration and ASEAN,
Ministry of Economy and Finance, Cambodia
Address: Ministry of Economy and Finance, St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia.

Fax: (855) 23 724374

Swift: N/A

<u>ឥណ្ឌូនេស៊ី:</u>

សម្រាប់ធនាគារកណ្តាល:

Attn: Director of International Directorate Bank Indonesia
Address: Syafruddin Prawiranegara Building, 4th Fl
Jl. M.H Thamrin No. 2, Jakarta 10350 Indonesia

Fax: 62-21-2311529

Swift: INDOIDJA

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Director of Centre for International Cooperation Policy
Fiscal Policy Office
Ministry of Finance of the Republic of Indonesia
Address: R.M. Noto Hamiprodjo Building, 7th Floor
Jl. Dr. Wahidin No. 1 Jakarta 10710, Indonesia

Fax: +62 21 3454205

Swift:

<u>សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ:</u>

សម្រាប់ធនាគារកណ្តាល:

Attn: Phengsy Phnegmoung, Director of ASEAN Division of International Relations, the Bank of Lao PDR
Address: Yonet Road P.O.Box 19, Vientiane Lao PDR

Fax: 85621 264313

Swift: LPDRLALA

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Director-General
Fiscal Policy Department, Ministry of Finance, Lao PDR
Address: 23 Singha Road, Vientiane, Lao PDR, P.O Box 46

Fax: (856-21) 412408

Swift:

ម៉ាឡេស៊ី:

សម្រាប់ធនាគារកណ្តាល:

Attn: Director, International Department
Address: Level 13, Block A, Bank Negara Malaysia, Jalan Dato' Onn. 50480 Kuala Lumpur

Fax: 603 2692 6762

Swift: BNMAMYKL

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Undersecretary, Economics & International Division
Address: Ministry of Finance, Level 9, Centre Block, Federal Government Administrative Centre, No. 5, Persiaran Perdana, Precinct 2, 62592 Putrajaya, MALAYSIA.

Fax: 603 8882 3881

Swift: N/A

មីយ៉ាន់ម៉ា:

សម្រាប់ធនាគារកណ្តាល:

Attn: Central Bank of Myanmar
Address: Building (26), Nay Pyi Taw, Myanmar

Fax: 95-1-543743
95-67-410193

Swift: CBMYMMMY

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Ministry of Finance and Revenue
Address: Building 26, Nai Pyi Taw, Myanmar

Fax: 95-67-410189

Swift: N/A

ហ្វីលីពីន:

សម្រាប់ធនាគារកណ្តាល:

Attn: Diwa C. Guinigundo
Deputy Governor

Monetary Stability Sector
Address: Office of the Deputy Governor
Monetary Stability Sector Bangko Sentral ng Pilipinas
A. Mabini St., Malate 1004, Manila, Philippines

Fax: 632 527 5878
Swift: N/A

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Ms. Rosalia V. de Leon
OIC-Undersecretary
Address: 6/F International Finance Group, Department of Finance, DOF Bldg.. BSP Complex, Roxas Blvd., Manila, Philippines

Fax: 632 524 5137

Swift: N/A

សិង្ហបុរី:

សម្រាប់ធនាគារកណ្តាល:

Attn: Mr. Leong Sing Chiong
Address: 10 Shenton Way, MAS Building, Singapore 079117

Fax: (65) 6323-0845

Swift: MASGSGSG

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Director (Economic Programmes/International Relations)
Address: The Treasury, 100 High Street, #10-01, Singapore 179434

Fax: (65) 6337-4134

Swift: N/A

ថៃ:

សម្រាប់ធនាគារកណ្តាល:

Attn: Director, International Economics Department
Address: 273 Samsen Road, Phranakorn, Bangkok 10200, Thailand
Fax: 66 2283 5300
Swift: BOTHTHBK

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Director-General, Fiscal Policy Office [name/title]
Address: Ministry of Finance, Rama VI Road, Phayathai, Bangkok 10400
Thailand
Fax: 66 2273 9096
Swift: N/A

<u>វៀតណាម៖</u>

សម្រាប់ធនាគារកណ្តាល៖

Attn: Director General, International Cooperation Department
Address: State Bank of Vietnam, 49 Ly Thai To Street, Hanoi

Fax: (844) 3 825 0612

Swift: STBVVNVX

សម្រាប់ក្រសួងហិរញ្ញវត្ថុ៖

Attn: Director General, International Cooperation Department,
Ministry of Finance
Address: 28 Tran Hung Dao Street, Hoan Kiem Dist., Hanoi, Vietnam

Fax: 84-4-2220 8109

Swift:

<u>សាធារណរដ្ឋប្រជាមានិតចិន៖</u>

សម្រាប់ធនាគារកណ្តាល៖

Attn:	Duo Xie Director-General, International Department. People's Bank of China
Fax:	86 10 66016726
Cc:	Yong Yin Director-General, Reserve Management Department. State Administration of Foreign Exchange
Fax:	86 10 66213326
Swift:	PBOCCNBJ

សម្រាប់ក្រសួងហិរញ្ញវត្ថុ៖

Attn:	Director General, International Department. Ministry of Finance, China
Address:	Sanlihe St., Xichengqu, Beijing 100820, P. R. China
Fax:	86 10 68551125
Swift:	[N/A]

ហុងកុង នៃប្រទេសចិន:

សម្រាប់អាជ្ញាធររូបិយវត្ថុហុងកុង:

Attn: Executive Director (External)
Address: Hong Kong Monetary Authority, 55/F, Two International Finance Centre, 8 Finance Street, Central, Hong Kong

Fax: +852 2878 8260

Swift: HKMAHKHH .

ជប៉ុន:

សម្រាប់ធនាគារកណ្តាល:

Attn: Associate Director-General, Deputy Chief of Center for Monetary Cooperation in Asia, International Department, Bank of Japan
Address: 2-1-1 Nihonbashi-Hongokucho, Chuo-ku, Tokyo 103-8660, Japan

Fax: 81 3 5200 2256

Swift: BOJPJPJT

សម្រាប់ក្រសួងហិរញ្ញវត្ថុ:

Attn: Takehiko Nakao, Director-General, International Bureau, Ministry of Finance, Japan
Address: 3-1-1, Kasumigaseki, Chiyoda-ku, Tokyo 100-8940, Japan

Fax: 81 3 5251 2197

Swift:

សាធារណរដ្ឋកូរ៉េ:

សម្រាប់ធនាគារកូរ៉េ:

Attn: Director General, International Department, the Bank of Korea
Address: 110, 3-Ga, Namdaemunno, Jung-Gu, Seoul 100-794, Korea

Fax: 82 2 759 5736

Swift: BOKRKRSE

សម្រាប់ក្រសួងយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ

Attn: Director General, International Finance Bureau, Ministry of Strategy and Finance
Address: Government Complex II, 88 Gwanmoonro, Gwacheon City, Gyeonggi Province, 427-725, Korea

Fax: 822 503 9272

Swift: N/A

ត ទៅរាជកិច្ចលេខ ៤៦

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៥១០/៤០៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស ជាតូបការ ជូន៖

១-ឯកឧត្តម ស៊ីន ស៊ូប៉ើទ្តី

២-ឯកឧត្តម ប្រាក់ សុខ

៣-ឯកឧត្តម ត្វប សំ

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ជូន៖

១-ឯកឧត្តម ចាន់ អ៊ីស៊ី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣.៧.២០០៥.៤១៣ នរោត្តម សីហមុនី

លេខ: ៤៥១ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៧/២៥៦ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តម ឯក សំអុល ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបញ្ចប់មុខតំណែង ឯកឧត្តម **ចាន់ ពិសី** ពីទីប្រឹក្សាផ្ទាល់ ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ២ : ត្រូវបានតែងតាំង ឯកឧត្តម **ផាត់ ពៅស៊ាង** ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា ៣ : ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ និង សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល. ១០០៥. ៤២២

លេខ: ៤៥០ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១០

ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

...នកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **លី ជុងបែក** (LEE JUNG BAEK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៦៣ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរល.១០០៥.៤៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០

លេខ: ៣៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧
- បានទ្រង់យល់លទ្ធផលបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញដោយសម្ងាត់ នៃរដ្ឋសភា កាលពីថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១០
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម **មីន ស៊ាន** ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជ្រើសតាំងដោយរដ្ឋសភាសម្រាប់អាណត្តិថ្មី ។

មាត្រា២ : ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.១០០៥.៤៤៩

លេខៈ ៤៤៩ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១០

បានឃើញដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី រាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៦១០/៤៦៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៨ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជូ ណាមហាន** (CHO NAM HAN) ជនជាតិកូរ៉េ សញ្ជាតិអាមេរិក កើតថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៥៨ នៅក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣ រ.ល.១០០៦.៤៧១

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១០

លេខៈ ៤៧៧ ច.ល
ចំលងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១:- ត្រូវបានបញ្ចប់មុខតំណែង៖

១- ឯកឧត្តម **អ៊ិត សារិ** ពីទីប្រឹក្សា ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ។

២- ឯកឧត្តម **រស់ ឆេង** ពីទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ។

មាត្រា ២:- ត្រូវបានតែងតាំង៖

១- ឯកឧត្តម **អ៊ិត សារិ** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ រដ្ឋលេខាធិការ។

២- ឯកឧត្តម **រស់ ឆេង** ជាទីប្រឹក្សាឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ។

មាត្រា ៣:- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

មាត្រា ៤:- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១០

៣រល.១០០៦.៤៩៣

លេខៈ ៤៤៧ ច.ល

ចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ូ ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី
ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១-ឯកឧត្តម ហ៊ុយ ហាវសូ

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១-ឯកឧត្តម ហេង បូរ៉ា ២-លោក ឧត់ សុផល

៣-លោកស្រី ឆេង ពៅធីតា ៤-លោក ហាច ហ៊ាន

៥-លោក យ៉ូង ខេមរា ៦-លោក ម៉េង ហៀង

៧-លោក ចេង ហ៊ាង ៨-លោក យឹម សំអុល

គ-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** ចំពោះ :

១-លោក ឡាយ ម៉េងលី

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ចំពោះ :

១-លោក គង់ ច័ន្ទតារា ២-លោក អៀម គន្ធី

៣-លោក គុណ ជាស៊ីន

ង-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

១-លោក ឡុត សុធារា

ច-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **សេនា** ចំពោះ :

១-លោក ជាង ប៊ុននិត្ត ២-លោក សុទ្ធ សារាធ

៣-លោក និន ចណ្ណៈ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧/ល.១០០៦.៤៩៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០

លេខ: ៤៤៦ ច.ល

បានឃើញរួចចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៤៩០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកត/០៣០០/១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយរក្សាក្របខ័ណ្ឌនយោបាយដដែលរហូតមានការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម:

ល.រ	គោត្តនាម និងនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរស័ក្តិ និងថ្នាក់	ថ្ងៃខែឆ្នាំ ចូលនិវត្តន៍
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ						
១	ចាន់ សារុន	ប	១៨-០៣-១៩៤៨	រដ្ឋមន្ត្រី	ក.១.១	០១-០១-២០១០

MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

ក្រសួងអភិវឌ្ឍន៍ជនបទ						
១	សួស គង់	ប	១០-១០-១៩៥០	មន្ត្រីលេខាធិការ	ក.១.១	០១-១១-២០១០
ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល						
១	អ៊ុង ប៊ុណ្ណារ៉ា	ប	១៦-០៧-១៩៤៤	អនុមន្ត្រីលេខាធិការ	ក.១.៦	០១-០៦-២០១០

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស/រកត. ១០០៦. ៤៩៤

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០

លេខ: ៤៦៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.០០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង ប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១ :-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.០០០ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល្ល័ង្គ ខេត្តកំពង់ធំ ក្រោមល័ក្ខខ័ណ្ឌ ជួល ឬ សម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និង និយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៤៦៥ សជណ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា២ :-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

មាត្រា៣ :-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ


(CAOUTCHOUC MEKONG Co., LTD)
1:80,000
1 A 492021 1446003
2 B 489993 1446022
3 C 489993 1446377
4 D 488179 1449018
5 E 486015 1450039
6 F 484042 1450000
7 G 484000 1451984
8 H 479400 1452045
9 I 479324 1459265
10 J 491906 1454310

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៣៧. អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ និបឌិន្ទ ជូនលោកឧត្តមសេនីយ៍ត្រី សៅ ម៉ុនធឿន អនុប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង ដែលមានស្នាដៃល្អក្នុងការចុះត្រួតពិនិត្យទីតាំងធ្វើអាជីវកម្ម លក់ ឌីវីឌី និង វីស៊ីឌី ព្រមទាំងបង្ក្រាបទីតាំងលួចថតចម្លង ឌីវីឌី និង វីស៊ីឌី ជាច្រើនកន្លែង នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ទទួលបានលទ្ធផលល្អប្រសើរ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងគណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត-វីដេអូ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៣៤ .អនក្រ .បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីនគរបាលនៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុងក្រសួងមហាផ្ទៃ ចំនួន១០រូប ដែលមានស្នាដៃល្អក្នុងការ ចុះត្រួតពិនិត្យទីតាំងធ្វើអាជីវកម្ម លក់ ឌីវីឌី និង វីស៊ីឌី ព្រមទាំងបង្ក្រាបទីតាំងលួចថតចម្លង ឌីវីឌី និង វីស៊ីឌី ជាច្រើនកន្លែង នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ :

១-លោកវរសេនីយ៍ទោ អ៊ុក សំអាន នាយការិយាល័យ នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
២-លោកវរសេនីយ៍ត្រី ឈឹម ណារុំ នាយរងការិយាល័យ នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
៣-លោកវរសេនីយ៍ត្រី អ៊ុំ ឈានរិទ្ធ នាយរងការិយាល័យ នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
៤-លោកវរសេនីយ៍ត្រី សន សុខុន នាយរងការិយាល័យ នាយកដ្ឋានសន្តិសុខផ្ទៃក្នុង

ខ-មេដាយប្រាក់ការងារ :

១-លោកអនុសេនីយ៍ឯក អនន្ត មេត្តា នាយផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
២-លោកអនុសេនីយ៍ត្រី ជា សត្យា នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
៣-លោកអនុសេនីយ៍ទោ រុន សុជាតា នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
៤-លោកព្រិន្ទបាលឯក ឆេន សំនិត នាយរងផ្នែក នាយកដ្ឋានសន្តិសុខផ្ទៃក្នុង
៥-លោកព្រិន្ទបាលឯក ខិន ឫទ្ធី មន្ត្រីនគរបាល
៦-លោកព្រិន្ទបាលឯក ម៉ុម វណ្ណឌី មន្ត្រីនគរបាល

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង គណៈកម្មការអន្តរក្រសួងបង្ក្រាបបទល្មើសភាពយន្ត-វីដេអូ ត្រូវអនុវត្តអនុក្រឹត្យនេះ [illegible]។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១០
[illegible] នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង សាលាបុណ្យ សាលាឆាន់ កុដិ និងសមិទ្ធផលនានា នៅវត្តមង្គលមានលក្ខណ៍ ស្ថិតក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ៖

១-	អ្នកស្រី	**ខួច** **ភាណ្ណារ៉ា**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.០០០ ដុល្លារ
២-	លោក	**លី** **អ៊ីលាង**	សប្បុរសជននៅខេត្តតាកែវ	ថវិកា ១០.០០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តតាកែវ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន ០៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង សាលាបុណ្យ សាលាឆាន់ កុដិ និងសមិទ្ធផលនានា នៅវត្តមង្គលមានលក្ខណ៍ ស្ថិតក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដូចមាននាយនាមខាងក្រោម ៖

១-	លោក	ឡុង គន	សប្បុរសជន ថវិកា ៦៥.០០០ ដុល្លារ
២-	លោក	កែន ស៊ីថាន	សប្បុរសជន ថវិកា ៦៥.០០០ ដុល្លារ
៣-	លោកជំទាវ	សុខ សោម៉ា ភរិយាឯកឧត្តម ហុង ចញ្ញារិទ្ធ	សប្បុរសជន ថវិកា ៦៥.០០០ ដុល្លារ
៤-	លោកជំទាវ	សៀង សុខណា ភរិយាឯកឧត្តម សួរ ចាន់ធី	សប្បុរសជន ថវិកា ៦៤.០០០ ដុល្លារ
៥-	លោក	ហុក ឡាំ	សប្បុរសជន ថវិកា ៦៤.០០០ ដុល្លារ
៦-	លោកយាយ	តឹក អេងគី	សប្បុរសជន ថវិកា ៦៤.០០០ ដុល្លារ
៧-	លោកយាយ	អេង អ៊ឿ	សប្បុរសជន ថវិកា ៦៤.០០០ ដុល្លារ

៨- លោក ឆាយ សាទុធ សប្បុរសជន ថវិកា ៦៤.០០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

